មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

Cambodian Center for Human Rights

ខែកុម្ភៈ ឆ្នាំ២០១៦

# ការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា



ឧបត្ថម្ភគាំទ្រដោយសប្បុរសពីសំណាក់

សហភាពអឺរ៉ុប

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") គឺជាអង្គការមិនមែនរដ្ឋាភិបាល ("អង្គការ")មិនចូលបក្សសម្ពន្ធ ឯករាជ្យ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ទស្សនៈវិស័យរបស់ម.ស.ម.ក គឺចង់ឲ្យកម្ពុជាក្លាយជាព្រះរាជាណាចក្រមួយគ្មានអំពើហិង្សាដែលប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋាន មានសមភាព និងត្រូវបានផ្ដល់សិទ្ធិអំណាច ដើម្បីចូលរួមក្នុងលិទ្ធិប្រជាធិបតេយ្យនិងទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍប្រទេសកម្ពុជា។ យើងចង់បាននីតិរដ្ឋជាជាងនិទណ្ឌភាព ស្ថាប័នរឹងមាំជាជាងបុគ្គលខ្លាំង និងចង់បានសង្គមពហុបក្សនិយមដោយក្នុងនោះភាពចម្រុះបែបនៃសង្គមត្រូវបានទទួលយកនិងសាទរ ជាជាងព្រងើយកន្តើយឬដាក់ទណ្ឌកម្ម។ ស្លាកសញ្ញារបស់ ម.ស.ម.ក រំលេចឲ្យឃើញរូបសត្វព្រាបស ហើរចេញពីរង្វង់មូល នៃផ្ទៃមេឃពណ៌ខៀវដែលនេះជានិមិត្តរូបនៃការទាមទារសេរីភាពកម្ពុជា។

របាយការណ៍ស្តីពី "*ការទទួលបានប័ណ្ណកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា*" ("របាយការណ៍") នេះគឺជាលទ្ធផលដែលកើតចេញពីគម្រោងកំណែទម្រង់ដីធ្លីនៃម.ស.ម.ក ។ របាយការណ៍នេះបង្ហាញអំពីឧបសគ្គក្នុងការចុះបញ្ជីដីសមូហភាពសម្រាប់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា ផ្អែកលើទិន្នន័យដែលគម្រោងប្រមូលបាន។

## សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះអាចកើតឡើងបានដោយសារការគាំទ្រដោយសប្បុរសពីសហភាពអឺរ៉ុប។ ខ្លឹមសារក្នុងរបាយការណ៍នេះគឺជាការទទួលខុសត្រូវទាំងស្រុងរបស់ ម.ស.ម.ក ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ។ ម.ស.ម.ក សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅះដល់អ្នកដែលបានចូលរួមផ្តល់បទសម្ភាសដើម្បីរួមចំណែកផ្តល់ព័ត៌មានស៊ីជម្រៅសម្រាប់របាយការណ៍នេះ។

## សំណួរ និងមតិឆ្លើយតប

ប្រសិនបើអ្នកមានសំណួរឬត្រូវការព័ត៌មានបន្ថែមអំពីរបាយការណ៍នេះ ឬប្រសិនបើអ្នកចង់ផ្តល់ព័ត៌មានត្រឡប់ណាមួយ សូមផ្ញើមកកាន់ ម.ស.ម.ក តាមរយៈ info@cchrcambodia.org។ ឬ សូមទាក់ទងមកកាន់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន ផ្ទះលេខ ៧៩៨ ផ្លូវលេខ ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

អ៊ីម៉ែល៖ info@cchrcambodia.org
ទូរសព្ទ៖ +៨៥៥ (0) ២៣ ៧២៦ ៩០១
ទូរសារ៖ +៨៥៥ (0) ២៣ ៧២៦ ៩០២
គេហទំព័រ៖ www.cchrcambodia.org

# មាតិកា


មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា....i
សេចក្តីថ្លែងអំណរគុណ....i
សំណួរ និងមតិឆ្លើយតប....i
និយមន័យនិងពាក្យកាត់....iv
សេចក្តីសង្ខេប....១
១. សេចក្តីផ្តើម....៤
១.១ ទិដ្ឋភាពទូទៅនៃស្ថានភាពដីធ្លីនៅកម្ពុជា....៤
១.២ ទិដ្ឋភាពទូទៅនៃសហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា....៦
២. សិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា....១១
២. ១ ទ្រឹស្តី៖ ក្របខ័ណ្ឌ ច្បាប់សម្រាប់ការពារ....១១
២.១.១ ការការពារសិទ្ធិដីធ្លីជនជាតិដើមភាគតិចក្រោមច្បាប់អន្តរជាតិ....១១
២.១.២ ការការពារសិទ្ធិដីធ្លីជនជាតិដើមភាគតិចក្រោមច្បាប់អន្តរជាតិ....១៣
២.២ ក្នុងការអនុវត្ត៖ ការចុះបញ្ជីដីជនជាតិដើមភាគតិច....១៧
*២.២.១ ការចុះបញ្ជីដីសម្រាប់ប័ណ្ណកម្មសិទ្ធដីសហមូហភាព*....១៧
២.២.២ វិធានការការពារបណ្តោះអាសន្ន....១៨
២.២.៣ ការធ្វើផែនការប្រើប្រាស់ដីតាមវិធីសាស្ត្រចូលរួម....១៨
២.២.៤ យុទ្ធនាការពន្លឿនការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី....១៩
៣. គោលបំណង វិសាលភាព និងវិធីសាស្ត្រ....២១
៣.១. គោលបំណងនៃការស្រាវជ្រាវ....២១
៣.២ វិធីសាស្ត្រ....២១
៣.៣ វិសាលភាពនិងដែនកំហិតនៃការស្រាវជ្រាវ....២៣
៤. ឧបសគ្គក្នុងការចុះបញ្ជីដីសមូហភាព....២៥
៤.១ ដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព....២៥
៤.១.១ កង្វះខាតការយល់ដឹងអំពីដំណើរការនេះក្នុងចំណោមសហគមន៍....២៥

៤.១.២ កង្វះខាតការយល់ដឹងអំពីដំណើរការនេះក្នុងចំណោមអាជ្ញាធរមូលដ្ឋាន.....២៦
៤.១.៣ ការចំណាយពាក់ព័ន្ធ.....២៧
៤.១.៤ កង្វះខាតឆន្ទៈនយោបាយក្នុងការសម្រួលដំណើរការ.....២៨
៤.២ អាជ្ញាធរមូលដ្ឋាន.....៣០
៤.២.១ កង្វះខាតការគាំទ្រ.....៣០
៤.២.២ កង្វះខាតសមត្ថកិច្ចនិងសមត្ថភាព.....៣៣
៤.២.៣ ការស៊ុមគ្រលុំជាមួយក្រុមហ៊ុន.....៣៤
៤.២.៤ ការគាបសង្កត់ឲ្យទទួលយកកម្មសិទ្ធិដីឯកជន.....៣៤
៤.២.៥ ការធ្វើទុក្ខបុកម្នេញពីប្រព័ន្ធយុត្តិធម៌.....៣៥
៤.២.៦ ការធ្វើទុក្ខបុកម្នេញតាមទម្រង់ផ្សេងទៀត.....៣៩
៤.៣ ក្រុមហ៊ុន.....៣៩
៤.៤ សហគមន៍.....៤២
៤.៤.១ កង្វះខាតការយល់ដឹងអំពីសិទ្ធិ.....៤២
៤.៤.២កង្វះខាតទំនុកចិត្ត.....៤៥
៤.៤.៣ កង្វះខាតឯកភាព.....៤៥
៤.៥ អង្គការមិនមែនរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍.....៤៨
៥. មេរៀនថ្នាក់តំបន់.....៥២
៦. សេចក្តីសន្និដ្ឋាននិងអនុសាសន៍.....៥៧
៦.១ រាជរដ្ឋាភិបាលកម្ពុជា.....៥៨
៦.២ ក្រុមហ៊ុន.....៥៩
៦.៣ អង្គការសង្គមស៊ីវិលនិងដៃគូអភិវឌ្ឍន៍.....៦០
៦.៤ សហគមន៍.....៦១
ឯកសារយោង.....៦២

# និយមន័យនិងពាក្យកាត់

| | |
|---|---|
| សមាគមអាដហុក | សមាគមអាដហុកការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា |
| ស្ទឹងអារ៉ែង | ភូមិជំនាប់ ស្ទឹងអារ៉ែង ស្រុកថ្មបាំង ខេត្តកោះកុង |
| ក្រុមហ៊ុនបិញហ្សឿក១ | ក្រុមហ៊ុនចំការកៅស៊ូបិញហ្សឿក១ |
| ឃុំប៊ូស្រា | ឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី |
| កម្ពុជា | ព្រះរាជាណាចក្រកម្ពុជា |
| ម.ស.ម.ក | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| ភូមិចឹង | ភូមិចឹង ឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ |
| ភូមិចក់ចារ | ភូមិចក់ចារ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី |
| ម.អ.ច.ស | មជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍ |
| ប.ក.ដ.ស | ប័ណ្ណកម្មសិទ្ធិដីសមូហភាព |
| រដ្ឋធម្មនុញ្ញ | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣ (វិសោធនកម្ម) |
| សង្គមស៊ីវិល | អង្គការសង្គមស៊ីវិល |
| បទបញ្ជាលេខ០១ | បទបញ្ជាលេខ០១ ប្រកាសដោយរដ្ឋាភិបាលនៅថ្ងៃទី៧ ឧសភា ២០១២ |
| សហភាពអឺរ៉ុប | សហភាពអឺរ៉ុប |
| ការវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គម | ការវាយតម្លៃអំពីផលប៉ះពាល់បរិស្ថាន និងសង្គម |
| សម្បទានដីសេដ្ឋកិច្ច | សម្បទានដីសេដ្ឋកិច្ច |
| គោលការណ៍ណែនាំ | គោលការណ៍ណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ |
| វារីអគ្គិសនីចិន កម្ពុជា | ក្រុមហ៊ុនទំនប់វារីអគ្គិសនីសេសានក្រោម២ ចិន~កម្ពុជា |
| ក.អ.ស.ព.ន | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ |
| អនុសញ្ញាលុបបំបាត់រាល់ | អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជ |

| | |
|---|---|
| ទម្រង់នៃការរើសអើងពូជសាសន៍ | សាសន៍ |
| ក.អ.ស.ស.ស.វ | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ |
| អង្គការអោយឡូ | អង្គការពលកម្មអន្តរជាតិ |
| អនុញ្ញាអាយឡូ១៦៩ | អង្គការពលកម្មអន្តរជាតិលេខ១៦៩ ស្តីពីជនជាតិដើមភាគតិចនិងក្រុមកុលសម្ព័ន្ធ |
| ច្បាប់សិទ្ធិជនជាតិដើមភាគតិច | ច្បាប់ស្តីពីសិទ្ធិជនជាតិដើមភាគតិច |
| ក.ក.អ.ក.ជ.ភ | ក្រុមការងារអន្តរជាតិកិច្ចការជនជាតិដើមភាគតិច |
| ភូមិក្បាលរមាស | ភូមិក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង |
| ច្បាប់ភូមិបាល | ច្បាប់ភូមិបាល ២០០១ |
| ក្រសួងមហាផ្ទៃ | ក្រសួងមហាផ្ទៃ |
| ក្រសួងរៀបចំដែនដី | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ក.អ.ជ | ក្រសួងអភិវឌ្ឍន៍ជនបទ |
| អ.ភ.ខ | អង្គការភូមិខ្ញុំ |
| អង្គការ | អង្គការមិនមែនរដ្ឋាភិបាល |
| ប.ដ.ឯ | ប័ណ្ណកម្មសិទ្ធិដីឯកជន |
| ផ.ប.ដ.វ.ច | ផែនការប្រើប្រាស់ដីដោយប្រើវិធីសាស្ត្រចូលរួម |
| គម្រោង | គម្រោងកំណែទម្រង់ដីធ្លីរបស់ ម.ស.ម.ក |
| របាយការណ៍ | របាយការណ៍នេះ មានចំណងជើងថា “*ការទទួលបានប័ណ្ណកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា*” |
| រដ្ឋាភិបាល | រាជរដ្ឋាភិបាលកម្ពុជា |
| ស៊ីណូហាយជ្រូ | ក្រុមហ៊ុនស៊ីណូហាយជ្រូ (ខេមបូឌា) យូណាយធីត |
| ស.ដ.ស.ក | សម្បទានដីសង្គមកិច្ច |

| | |
|---|---|
| ក្រុមហ៊ុនសំរឹទ្ធ | ក្រុមហ៊ុនច្បាប់សំរឹទ្ធ |
| ខេស៊ីឌី | ក្រុមហ៊ុនសុកហ៊្វីនខេស៊ីឌី |
| អនុក្រឹត្យលេខ៨៣ | អនុក្រឹត្យលេខ៨៣ ស្តីពីនីតិវិធីចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច |
| ស.ប.ស.ស | សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស |
| អ.ស.ប | អង្គការសហប្រជាជាតិ |
| ស.ប.ស.ស.ជ.ភ | សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច |
| ភ.ដ.ស.ហ.ជ.ភ | ភាពជាដៃគូរវាងអង្គការសហប្រជាជាតិនិងជនជាតិដើមភាគតិច |
| អង្គការអភិរក្សសត្វព្រៃ | អង្គការសង្គមអភិរក្សសត្វព្រៃ |

# មូលន័យសង្ខេប

ក្នុងរយៈពេលបីទសវត្សចុងក្រោយនេះ ការរស់រានមានជីវិតរបស់ប្រជាជននិងវប្បធម៌របស់ជនជាតិដើមភាគតិចនៅពាសពេញពិភពលោក ត្រូវទទួលរងការគំរាមកំហែង ដោយសារតែតម្រូវការដីធ្លីនិងធនធានធម្មជាតិមានការកើនឡើងខ្លាំង។ និន្នាការសកលលោក ចំពោះភាពជាម្ចាស់ដីធ្លីលក្ខណៈឯកជន ដែលអនុញ្ញាតិឲ្យមានការធ្វើឯកជនភាវូនីយកម្មទៅលើដីនិងធនធនធម្មជាតិ ជាជាងកម្មសិទ្ធិសមូហភាព បានធ្វើឲ្យមានការបំផ្លាញជាពិសេសដល់សហគមន៍ជនជាតិដើមភាគតិច។ សម្រាប់ជនជនដើមភាគតិចជាច្រើន ការប្រើប្រាស់ដីសមូហភាពមានសារៈសំខាន់ខ្លាំងណាស់សម្រាប់វប្បធម៌ប្រពៃណី អត្តសញ្ញាណ និងជីវភាពរស់នៅរបស់ពួកគេ។ ការកើនឡើងនៃតម្រូវការទៅលើដីធ្លីនិងធនធាន រួមជាមួយនឹងការរីកចម្រើនផ្នែកហេដ្ឋារចនាសម្ព័ន្ធនិងបច្ចេកវិទ្យា បាននាំឲ្យសហគមន៍ជនជាតិដើមភាគតិចដាច់ស្រយាល ទទួលរងផលប៉ះទង្គិចជាមួយនឹងពិភពទំនើប ឈានទៅរកផលវិបាកដ៏មហន្តរាយយ៉ាងធ្ងន់ធ្ងរ។ ជាងនេះទៀត ការរើសអើងទៅលើជនជាតិដើមភាគតិចនិងការផាត់ពួកគេចេញពីការសម្រេចចិត្ត បានធ្វើឲ្យរដ្ឋាភិបាលជាតិសម្រេចអនុម័តទៅលើគម្រោងអភិវឌ្ឍន៍ធំៗដែលជារឿយៗច្រើនតែលុកលុយចូលទៅលើដីរបស់ជនជាតិដើមភាគតិច និងឈានទៅដល់ការរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច។ ហេតុដូច្នេះហើយ ការមិនបានកាន់កាប់លើដីប្រពៃណីនិងដែនដីប្រពៃណីនេះ គឺជាបញ្ហាមួយក្នុងចំណោមបញ្ហាចម្បងៗដែលជនជាតិដើមភាគតិចកំពុងប្រឈមមុខនៅជុំវិញពិភពលោក ដែលនេះជាការគំរាមកំហែងដល់អត្ថិភាពរបស់ពួកគេ។

ការគំរាមកំហែងដល់អត្ថិភាពរបស់សហគមន៍ជនជាតិដើមភាគតិចនេះ បាននាំឲ្យមានការផ្តោតយកចិត្តទុកដាក់កាន់តែច្រើនឡើង ទៅលើសិទ្ធិរបស់ជនជាតិដើមភាគតិចនៅក្នុងច្បាប់និងគោលនយោបាយអន្តរជាតិ ដោយសារតែពិភពលោកស្វែងរកការការពារវប្បធម៌និងរបៀបរស់នៅដ៏ពិសេសរបស់ពួកគេ ក៏ដូចជាសិទ្ធិបុគ្គលដែលទទួលរងការប៉ះពាល់។ ក្នុងការអះអាងអំពីភាពងាយរងគ្រោះរបស់ជនជាតិដើមភាគតិចនិងតម្រូវការរបស់ជាតិទាំងឡាយក្នុងការចាត់វិធានការដើម្បីធានាឲ្យមានការគោរពសិទ្ធិរបស់ពួកគេនោះ ក្រុមការងារអន្តរជាតិទាក់ទងនិងកិច្ចការជនជាតិដើមភាគតិចបានថ្លែងថា *"ជនជាតិដើមភាគតិច នៅតែមិនត្រូវបានគេយកចិត្តទុកដាក់នៅក្នុងសង្គម គឺពួកគេក្រីក្រ មានការអប់រំតិចតួច ស្លាប់ក្នុងវ័យក្មេង ទំនងជាធ្វើអត្តឃាដ និងជាទូទៅមានសុខភាពអន់ជាង ប្រជាជនទាំងឡាយដទៃទៀត"*[1]

នៅក្នុងប្រទេសកម្ពុជា ការរំលោភបំពានជាប្រព័ន្ធលើសិទ្ធិដីធ្លី គឺជាការរំលោភបំពានសិទ្ធិមនុស្សដែលមានសភាពរីករាលដាលខ្លាំងបំផុតនាពេលបច្ចុប្បន្ននេះ។ ជាពិសេស ជនជាតិដើមភាគតិចកំពុងបាត់បង់ដីរបស់ពួកគេក្នុងអត្រាមួយដែលត្រូវប្រកាសអាសន្ន ដោយសារតែការកាប់ឈើក្នុងព្រៃ ការទាញយកធនធាន គម្រោង

[1] ក្រុមការងារកិច្ចការជនជាតិដើមភាគតិចអន្តរជាតិ "ពិភពជនជាតិដើមភាគតិច ២០០៦" (២០០៦) http://bit.ly/21bgrsZ

ហេដ្ឋារចនាសម្ព័ន្ធក្នុងទ្រង់ទ្រាយធំ ដូចជាការសាងសង់ទំនប់ទឹកនិងប្រព័ន្ធបង្ហូរទឹក ព្រមទាំងការផ្តល់សម្បទានដីសម្រាប់ការធ្វើអាជីវកម្មកសិកម្ម។ ទោះបីជាមានការទទួលស្គាល់ភាពជាម្ចាស់ដីសមូហភាពពីសំណាក់ជនជាតិដើមភាគតិចជាគោលការណ៍ ក្នុងប្រទេសកម្ពុជាក៏ដោយ ក៏ការចុះបញ្ជីដីសមូហភាពសម្រាប់សហគមន៍ជនជាតិដើមភាគតិច ស្ទើរតែមិនមានសោះនៅក្នុងការអនុវត្តជាក់ស្តែង។ ក្នុងចំណោមសហគមន៍ជនជាតិដើមចំនួន ៤៥៥[2] មានតែសហគមន៍ចំនួន ១១ ប៉ុណ្ណោះដែលអាចបំពេញដំណើរការ និងចុះបញ្ជីដីរបស់ខ្លួនបានចប់សព្វគ្រប់។

របាយការណ៍នេះពិនិត្យមើលឧបសគ្គក្នុងការចុះបញ្ជីដីសមូហភាពសម្រាប់សហគមន៍ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា ដោយផ្អែកទៅលើទិន្នន័យដែលគម្រោងប្រមូលបាន។ របាយការណ៍នេះមានគោលបំណងលើកឡើងនូវមូលហេតុនៃកង្វះខាតក្នុងការអនុវត្តការចុះបញ្ជីដីធ្លីសហគមន៍ និងកំនត់នូវអនុសាសន៍នានាសម្រាប់ដាក់ជូនដល់អ្នកពាក់ព័ន្ធដែលអាចជួយលើកកម្ពស់ការអនុវត្តឲ្យបានប្រសើរ ដើម្បីបង្កើនការការពារសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា។

**ជំពូក១ (សេចក្តីផ្តើម)** ផ្តល់នូវទិដ្ឋភាពទូទៅសង្ខេបអំពីស្ថានភាពដីធ្លីក្នុងប្រទេសកម្ពុជា តាមរយៈការរៀបរាប់អំពីស្ថានភាពសិទ្ធិដីធ្លី មុននឹងផ្តល់នូវទិដ្ឋភាពទូទៅអំពីជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា និងការគំរាមកំហែងដែលពួកគេប្រឈមចំពោះសុវត្ថិភាពនៃការកាន់កាប់ដីធ្លី។

**ជំពូក២ (សិទ្ធិដីធ្លីជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា)** បង្ហាញអំពីស្ថានភាពសិទ្ធិដីធ្លីជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា ដោយពិនិត្យទៅលើសិទ្ធិនិងកាតព្វកិច្ចថ្នាក់ជាតិនិងអន្តរជាតិជាប់ទាក់ទងដែលអាចអនុវត្តបាន។ មានការលាតត្រដាងថា ក្នុងការអនុវត្តជាក់ស្តែង ការអនុវត្តច្បាប់ពាក់ព័ន្ធដោយភាពទន់ខ្សោយបានទុកឲ្យសហគមន៍ជនជាតិដើមភាគតិចជាច្រើនខ្វះខាតសុវត្ថិភាពកាន់កាប់ ដែលជាហេតុធ្វើឲ្យមានភាពងាយរងគ្រោះដោយសារការទន្ទ្រានចាប់ដីនិងការបាត់បង់កម្មសិទ្ធិ។

**ជំពូក៣ (គោលបំណង វិសាលភាព និងវិធីសាស្ត្រ)** បង្ហាញអំពីគោលបំណងនៃការស្រាវជ្រាវ វិធីសាស្ត្រដែលបានប្រើឧបករណ៍សម្រាប់ទទួលព័ត៌មានសម្រាប់របាយការណ៍នេះ រួមទាំងដែនកំណត់នៃការស្រាវជ្រាវនេះផងដែរ។

**ជំពូក៤ (ឧបសគ្គចំពោះការចុះបញ្ជីដីសមូហភាព)** បង្ហាញអំពីករណីសិក្សាដែលជ្រើសរើសសម្រាប់ការស្រាវជ្រាវនេះ និងបង្ហាញអំពីលទ្ធផលនៃការស្រាវជ្រាវ។ លទ្ធផល លាតត្រដាងនូវឧបសគ្គជាច្រើនក្នុងការចុះ

---

[2] នេះជាចំនួនភូមិដែលជនជាតិដើមភាគតិចរស់នៅ ដោយដកស្រង់ចេញពីសារាចរណ៍ក្នុងឆ្នាំ២០០៩ "នីតិវិធីនិងវិធីសាស្ត្រសម្រាប់អនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍និងការកំណត់អត្តសញ្ញាណកម្មសហគមន៍ជនជាតិដើមភាគតិច" ក៏ប៉ុន្តែ មានអ្នកមួយចំនួនដែលជឿថាចំនួនពិតប្រាកដ មានច្រើនជាងនេះ

បញ្ជីដីសមូហភាព ដែលបង្កឡើងដោយតួអង្គផ្សេងៗគ្នាដែលមានការពាក់ព័ន្ធនៅក្នុងដំណើរការបន្ថែមពីលើនីតិវិធីស្មុគ្រស្មាញនិងតឹងតែង ព្រមទាំងការអនុវត្តច្បាប់ដោយភាពទន់ខ្សោយ។

**ជំពូក៥ (មេរៀនថ្នាក់តំបន់)** ពិនិត្យលើករណីសិក្សាដែលចេញមកពីតំបន់អាស៊ីខាងត្បូង ដើម្បីរំលេចនូវការអនុវត្តល្អៗ ក្នុងការការពារសិទ្ធិដីធ្លីជនជាតិដើមភាគតិច និងប៉ាន់ប្រមាណអំពីភាពជាប់ទាក់ទងរបស់វានៅក្នុងបរិបទកម្ពុជា។

**ជំពូក៦ (សន្និដ្ឋាន និងអនុសាសន៍)** សង្ខេបលទ្ធផលសំខាន់ៗមួយចំនួនចេញពីការស្រាវជ្រាវនេះ ហើយផ្អែកទៅលើចំណុចទាំងអស់នេះ ផ្តល់នូវអនុសាសាន៍ជាក់លាក់មួយចំនួនដល់ភាគីពាក់ព័ន្ធផ្សេងៗ រួមមាន រាជរដ្ឋាភិបាលកម្ពុជា("រដ្ឋាភិបាល") ក្រុមហ៊ុនដែលកំពុងប្រតិបត្តិការនៅក្នុងតំបន់ជនជាតិដើមភាគតិច អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដែលកំពុងធ្វើការជួយជ្រោមជ្រែងដល់ការចុះបញ្ជីដីជនជាតិដើមភាគតិច និងដល់សហគមន៍ជនជាតិដើមភាគតិចដែរ។ អនុសាសន៍ទាំងនេះ មានគោលបំណងសម្រួលដល់ដំណើរការចុះបញ្ជីដីសមូហភាព ហើយដើម្បីធានាឲ្យមានសុវត្ថិភាពកាន់កាប់ដីធ្លីកាន់តែប្រសើរសម្រាប់សហគមន៍ជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា។

# ១. សេចក្តីផ្តើម

## ១.១ និន្នាការទូទៅនៃស្ថានភាពដីធ្លីនៅកម្ពុជា

សេរីភាវូបនីយកម្មសេដ្ឋកិច្ច ការពង្រីកការនាំចេញយ៉ាងរហ័ស និងកំណើនវិនិយោគទុនបរទេស ក្នុងរយៈពេលពីរទសវត្សចុងក្រោយនេះ បាននាំឲ្យមានតម្រូវការដីធ្លីយ៉ាងខ្លាំងនៅកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតឲ្យមានការជួលដីក្នុងទំហំធំសម្រាប់ផលប្រយោជន៍ពាណិជ្ជកម្ម តាមរយៈសម្បទានដីសេដ្ឋកិច្ច។ ភាពត្រៀមខ្លួនរបស់រដ្ឋាភិបាលក្នុងការបែងចែកដីធ្លីឡើងវិញ រួមជាមួយនឹងអសុវត្ថិភាពនៃការកាន់កាប់ដីធ្លីដោយសារតែកង្វះកម្មសិទ្ធិស្របច្បាប់យ៉ាងរីករាលដាល និងនីតិរដ្ឋដ៏ទន់ខ្សោយផងនោះ បានសម្រួលដល់ការចាប់យកដីនិងការបណ្តេញចេញដោយបង្ខំយ៉ាងច្រើន។ សម្បទានដីសេដ្ឋកិច្ច អនុញ្ញាតឲ្យអ្នកទទួលផលជួលដីដែលមានរដ្ឋជាម្ចាស់រហូតដល់ទៅ ១០.០០០ ហិចតាសម្រាប់ប្រើប្រាស់ក្នុងវិស័យកសិកម្មបែបឧស្សាហកម្មសម្រាប់រយៈពេលអតិបរមា ៩៩ឆ្នាំ[3] ទោះបីជានាពេលថ្មីៗនេះ រដ្ឋាភិបាលបានប្រកាសអំពីចេតនាក្នុងការកាត់បន្ថយកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចជាបន្តបន្ទាប់ឲ្យមកនៅសល់ត្រឹមតែ៥០ឆ្នាំក៏ដោយ។[4] បើយោងតាមអនុក្រឹត្យលេខ ១៤៦ ស្តីពីសម្បទានដីសេដ្ឋកិច្ច ដែលបញ្ញត្តិទៅលើសម្បទានដីសេដ្ឋកិច្ចនោះ សម្បទានដីសេដ្ឋកិច្ចទាំងអស់ត្រូវតែបំពេញត្រឹមត្រូវតាមលក្ខខណ្ឌដែលមានស្រាប់មុននឹងទទួលបានសម្បទាដីសេដ្ឋកិច្ច។ លក្ខខណ្ឌទាំងនោះរួមមានដូចជាការបំពេញរួចរាល់នូវការវាយតម្លៃផលប៉ះពាល់សង្គមនិងបរិស្ថាន ការផ្តល់ដំណោះស្រាយសម្រាប់ការផ្លាស់ទីលំនៅដែលមិនតម្រូវឲ្យមានការផ្លាស់ទីលំនៅដោយមិនស្ម័គ្រចិត្តឡើយ ព្រមទាំងការពិគ្រោះយោបល់ជាសាធារណៈជាមួយភាគីពាក់ព័ន្ធ ដោយរាប់បញ្ចូលទាំងសហគមន៍ដែលរងការប៉ះពាល់។[5] ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែង សម្បទានដីសេដ្ឋកិច្ចត្រូវបានផ្តល់ដោយមិនបានបំពេញតាមលក្ខណវិនិច្ឆ័យបែបនេះទេ។ មានការប៉ាន់ប្រមាណថាដីច្រើនជាង ២ លានហិចតានៅកម្ពុជា ត្រូវបានផ្តល់ឲ្យតាមរយៈសម្បទានដីសេដ្ឋកិច្ចដល់ក្រុមហ៊ុនបរទេសនិងក្នុងស្រុក ក៏ដូចជាផ្តល់ទៅឲ្យអ្នកនយោបាយមានទ្រព្យធនច្រើនសម្រាប់ធ្វើសកម្មកសិកម្ម-ឧស្សាហកម្ម។[6]

បន្ថែមពីលើសម្បទានដីសេដ្ឋកិច្ច សកម្មភាពអភិវឌ្ឍដែលបានស្នើឡើងផ្សេងទៀត ត្រូវបានផ្តួចផ្តើមឡើង ដែលបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិដីធ្លីរបស់ពលរដ្ឋក្នុងប្រទេសកម្ពុជា។ ដី២លានហិចតាផ្សេងទៀតបានទទួលរងផលប៉ះពាល់ដោយសារសម្បទានរ៉ែ និងមានការកសាងទំនប់វារីអគ្គីសនីធំៗយ៉ាងហោចណាស់

---

[3] ច្បាប់ភូមិបាល មាត្រា៦១

[4] សេចក្តីថ្លែងការណ៍លេខ៦៨៣ ចុះថ្ងៃទី២៨ កក្កដា ២០១៥ ចេញដោយក្រសួងបរិស្ថានបានប្រកាសថា តាមគោលការណ៍ រដ្ឋាភិបាលបានសម្រេចបន្ថយកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចឲ្យមកនៅត្រឹម៥០ឆ្នាំ

[5] អនុក្រឹត្យលេខ ១៤៦ ស្តីពីសម្បទានដីសេដ្ឋកិច្ច អនក្រ/បក (ខែ២៧ ខែធ្នូ ឆ្នាំ២០០៥)

[6] អង្គការលីកាដូ "សម្បទាននៅកម្ពុជា" (ខែឧសភា ឆ្នាំ២០១៥) http://bit.ly/1LdkawE

ចំនួន៩[7] ដែលគំរាមកំហែងនាំឲ្យមានទឹកជំនន់ទៅលើផ្ទៃដីដ៏ធំពាសពេញប្រទេស។ ជាលទ្ធផល ការបំពានសិទ្ធិដីធ្លីស្ថិតនៅក្នុងចំណោមការរំលោភបំពានសិទ្ធិមនុស្សដែលរីករាលដាលជាងគេក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ដែលទទួលរងយ៉ាងខ្លាំងដោយក្រុមងាយរងគ្រោះនិងក្រុមដែលគេផាត់ចេញនៅក្នុងសង្គម។

តាមរយៈការទទួលស្គាល់បញ្ហាជុំវិញសម្បទានដីធ្លីនេះ រាជរដ្ឋាភិបាលកម្ពុជាបានចេញការផ្អាកផ្តល់សម្បទានដីសេដ្ឋកិច្ចនៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ តាមរយៈបទបញ្ជា០១។ បទបញ្ជានេះ ហាមឃាត់ទទួលការផ្តល់សម្បទានដីសេដ្ឋកិច្ចបន្ថែមទៀត ហើយអំពាវនាវឲ្យមានការពិនិត្យឡើងវិញទៅលើសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ក្នុងពេលបច្ចុប្បន្ននេះ។[8] ក្នុងខែសីហា ឆ្នាំ២០១៤ រដ្ឋាភិបាលបានបង្កើតគណៈកម្មការអន្តរក្រសួងក្នុងការពិនិត្យ កំណត់ព្រំ និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច[9] ដែលមានភារកិច្ចពិនិត្យទៅលើសម្បទានដីសេដ្ឋកិច្ច និងដកហូតមកវិញនូវដីក្រុមហ៊ុនដែលខកខានអនុវត្តតាមលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យា។ ក្នុងឆ្នាំ២០១៤ សម្បទានចំនួន២៤ ត្រូវបានដកហូត ឬកាត់បន្ថយក្នុងទំហំសរុបចំនួន ២០២.២១០ ហិចតាក្នុងខេត្តចំនួន១១ ដោយសារតែការមិនអនុវត្តតាមច្បាប់។[10]

ក៏ប៉ុន្តែ ភាគច្រើននៃសម្បទានដីសេដ្ឋកិច្ចដែលត្រូវបានផ្តល់ឲ្យក្រោមកាលៈទេសៈច្បាប់មិនច្បាស់លាស់ទាំងនោះ នៅតែមិនទាន់មានការពិនិត្យឡើងវិញនៅឡើយទេ។ នេះគឺភាគច្រើនដោយសារតែអំពើពុករលួយដែលរីករាលដាលក្នុងចំណោមអ្នកធំមានអំណាចនៅក្នុងប្រទេសកម្ពុជា ដែលបណ្តោយឲ្យតួអង្គឯកជនប្រព្រឹត្តអំពើរំលោភបំពានសិទ្ធិមនុស្ស រួមទាំងនិទណ្ឌភាព។ មានការប៉ាន់ប្រមាណថា ២០% នៃដីសរុបដែលត្រូវបានបែងចែកតាមរយៈសម្បទានដីសេដ្ឋកិច្ចនេះ ត្រូវកាន់កាប់ដោយសមាជិកព្រឹទ្ធសភានៃគណបក្សប្រជាជនកម្ពុជាកំពុងកាន់អំណាច[11]តែប្រាំរូបប៉ុណ្ណោះ ដែលនេះជាការចង្អុលបង្ហាញអំពីទំហំអំពើពុករលួយនៅក្នុងប្រទេស។ ជាងនេះទៀត សម្បទានដីសេដ្ឋកិច្ច និងគម្រោងហេដ្ឋារចនាសម្ព័ន្ធជាច្រើន ធ្វើឲ្យសកម្មភាពកាប់ឈើមានការកើនឡើង ដោយរាប់បញ្ចូលទាំងការកាប់ឈើខុសច្បាប់ដែរ[12] ដែលវាធ្វើឲ្យកាន់តែមានការប៉ះពាល់ទៅលើសិទ្ធិដីធ្លី និងបណ្តាលឲ្យមានវិវាទ។ ចំណងរវាងសម្បទានដីនិងការកាប់ឈើខុសច្បាប់ ត្រូវបានអតីតអ្នករាយការណ៍

---

[7] សារ៉ា មីលីន "និស្សារណកម្ម៖ ការកាប់ឈើដោយខុសច្បាប់ នៅក្នុងស្រមោលនៃអភិបាលនិងការវិនិយោគឆ្លងប្រទេស" *ការសិក្សាវិភាគអាស៊ី* វ៉ុល៤៧ លេខ២ (ខែឧសភា ឆ្នាំ២០១៥)

[8] បទបញ្ជា ០១ ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ ស្តីពីវិធានការពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច

[9] សេចក្តីសម្រេចលេខ ១២៥ សសរ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងក្នុងការពិនិត្យ កំណត់ព្រំ និងប៉ាន់ប្រមាណសម្បទានដីសេដ្ឋកិច្ច

[10] អង្គការអាដហុក "ដីរបស់អ្នកណា? របាយការណ៍ស្តីពីស្ថានភាពសិទ្ធិដីធ្លីនៅកម្ពុជា ឆ្នាំ២០១៤ និងពាក់កណ្តាលទីមួយនៃឆ្នាំ២០១៥ (ខែកក្កដា ឆ្នាំ២០១៥)

[11] គ្លូបិលវីតណេស "អ្នកជំនួញដែលកាន់កាប់មួយផ្នែកនៃឧស្សាហកម្មកៅស៊ូ" វិធីដែលក្រុមហ៊ុនវៀតណាម និងហិរញ្ញជិកាវីអន្តរជាតិកំពុងនាំមុខក្នុងវិបត្តិប្លាមយកដីធ្លីក្នុងប្រទេសកម្ពុជា និងឡាវ (ខែមិនា ឆ្នាំ២០១៣) http://bit.ly/1HgC1V8

[12] សារ៉ា មីលីន "និស្សារណកម្ម៖ ការកាប់ឈើដោយខុសច្បាប់ នៅក្នុងស្រមោលនៃអភិបាលនិងការវិនិយោគឆ្លងប្រទេស" *ការសិក្សាវិភាគអាស៊ី* វ៉ុល៤៧ លេខ២ (ខែឧសភា ឆ្នាំ២០១៥)

ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា គឺលោកសូរិយាស៊ូប៊ីឌី បានទទួលស្គាល់នៅក្នុងឆ្នាំ២០១២ ដោយកត់សំគាល់ថា *«សម្បទានិកជាច្រើន ប្រតិបត្តិការនៅពីក្រោយរនាំងនៃភាពសម្ងាត់»។*[13]

វប្បធម៌នៃអំពើពុករលួយក្នុងប្រទេសកម្ពុជាដែលសម្រួលដល់សកម្មភាពលួចលាក់ខុសច្បាប់ទាំងនេះ បាននាំឲ្យប្រទេសនេះត្រូវបានចាត់ថ្នាក់លេខរៀងទី១៥០ នៃប្រទេសចំនួន១៦៨ ដោយលិបិក្រមការយល់ឃើញអំពីអំពើពុករលួយក្នុងឆ្នាំ២០១៤ របស់អង្គការតម្លាភាពអន្តរជាតិ។[14] ជាពិសេស ការផ្តល់ពិន្ទុទាបដែលឆ្លុះបញ្ចាំងអំពើកុករលួយដ៏រាលដាលនៅក្នុងប្រព័ន្ធយុត្តិធម៌របស់ប្រទេសកម្ពុជា ដូចបានបង្ហាញនៅក្នុងលិបិក្រមស្តីពីនីតិរដ្ឋរបស់គម្រោងកម្មវិធីយុត្តិធម៌ពិភពលោក ដែលបានចេញផ្សាយពីការវាយតម្លៃទៅលើវិស័យយុត្តិធម៌នៃបណ្តាប្រទេសនីមួយៗបានដាក់ចំណាត់ថ្នាក់ប្រទេសកម្ពុជាស្ថិតនៅក្នុងលេខរៀងទី ៩៨ ក្នុងចំណោមប្រទេសចំនួន ១០២។[15] អំពើពុករលួយនៅក្នុងប្រព័ន្ធយុត្តិធម៌នាំឲ្យមានកង្វះខាតជាទូទៅក្នុងការប្រតិបត្តិ និងការអនុវត្តច្បាប់ និងបទបញ្ញាពាក់ព័ន្ធនានា។ បន្ថែមលើនេះ អំពើពុករលួយដ៏រាលដាលនៅក្នុងប្រទេសកម្ពុជា ក៏គឺជាកត្តាយ៉ាងចម្បងមួយដែលធ្វើឲ្យប្រជាជនច្រើនតែត្រូវបានបដិសេធក្នុងការផ្តល់ឲ្យនូវដំណោះស្រាយដែលពេញចិត្តទៅលើជម្លោះដីធ្លីដែលពាក់ព័ន្ធនឹងពួកគេឡើយ ទោះបីជាមានវត្តមានយន្តការដោះស្រាយដីធ្លីមួយចំនួននៅក្នុងប្រទេសកម្ពុជាក៏ដោយ។[16] ទោះបីជាតាមទ្រឹស្តី យន្តការទាំងអស់នេះត្រូវបានបង្កើតឡើងដើម្បីការពារសិទ្ធិដីធ្លីរបស់ពលរដ្ឋក៏ដោយ ក៏ក្នុងការអនុវត្តជាក់ស្តែង គេដឹងថាមានការលម្អៀងទៅរកអ្នកធំអ្នកមាន។

## ១.២ និន្នាភាពទូទៅនៃសហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា

មានការប៉ាន់ប្រមាណថា មានប្រជាជនជាតិដើមភាគតិចចំនួនជាង ៣៧០លាននាក់ ដែលកំពុងរស់នៅក្នុងប្រទេសចំនួនប្រហែល៩០ នៅទូទាំងពិភពលោក។ និយមន័យជាផ្លូវការដែលកំណត់ថាអ្វីទៅជា "ជនជាតិដើមភាគតិច" មិនទាន់ត្រូវបានអនុម័តដោយអង្គការសហប្រជាជាតិនៅឡើយទេ ដោយសារតែចម្រុះភាពនៃជនជាតិដើមភាគតិចនៅក្នុងពិភពលោក។ ប៉ុន្តែ បែរជាមានការបង្កើតឡើងនូវពាក្យស័ព្ទ "ជនជាតិដើមភាគតិច" បែបទំនើបនិងមានការយល់ដឹងទាំងអស់ ។ និយមន័យនេះរួមបញ្ចូលទាំងមនុស្សដែលមានប្រវត្តិពូជពង្សជាងពាក់ព័ន្ធបន្តជាមួយនឹងសង្គមមុនអាណានិគមនិងមុនពេលមានអ្នកមកតាំងទីលំនៅដែលអភិវឌ្ឍនៅលើដែនដីរបស់ពួកគេ អ្នកដែលមានប្រព័ន្ធសង្គម សេដ្ឋកិច្ច ឬនយោបាយដោយឡែក ក្រុមដែលបង្កើតឡើងមិនមានការគ្របដណ្តប់នៅក្នុងសង្គម ការកំណត់ខ្លួនឯង និងទទួលស្គាល់ និងទទួលយកដោយសហគមន៍របស់ពួកគេ ក្នុងឋានៈជាជនជាតិដើមភាគតិច រក្សាភាសា វប្បធម៌ និងជំនឿដោយឡែករបស់ខ្លួន និងមានចំណងខ្លាំងទៅនឹងទឹកដីនិង

---

[13] សូរិយាស៊ូប៊ីឌី "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា" (២៤ ខែកញ្ញា ឆ្នាំ២០១២) http://bit.ly/1kUyGln

[14] អង្គការតម្លាភាពអន្តរជាតិ "លិបិក្រម ២០១៥ សញ្ញានៃអំពើពុករលួយ" (មករា២០១៦) http://bit.ly/1JKBrkS

[15] គម្រោងកម្មវិធីយុត្តិធុម៌ពិភពលោក "លិបិក្រម២០១៥ (២០១៥) http://bit.ly/1cwTwCz

[16] សម្រាប់ព័ត៌មានបន្ថែមអំពីភាពខ្វះចន្លោះនៃយន្តការដោះស្រាយវាវាទ សូមអាន ម.ស.ម.ក "បរាជ័យនៃយន្តការដោះស្រាយវិវាទដីធ្លី" (កំណត់ព័ត៌មានសង្ខេប) (ខែកក្កដា ឆ្នាំ២០១៤) http://bit.ly/12zx4nE

ធនធានធម្មជាតិនៅជុំវិញខ្លួន និងព្រមព្រៀងរក្សានិងបង្កើតឡើងវិញនូវបរិស្ថានបុព្វបុរសនិងប្រព័ន្ធដែលមានលក្ខណៈជាមនុស្សនិងសហគមន៍ដោយឡែក។[17]

ក្នុងប្រទេសកម្ពុជា មានជនជាតិដើមភាគតិចចំនួន ១៩០.០០០នាក់ ដែលត្រូវនឹង ១,៤ ភាគរយនៃប្រជាជនសរុបក្នុងប្រទេសកម្ពុជា។[18] ចំនួនជនជាតិដើមភាគតិចនៅកម្ពុជាមាន ២៤ ក្រុមផ្សេងគ្នាដូចជា ចារ៉ាយ ព្រៅ កាវេត គ្រឹង លុន ពួង (ភាសាដើមហៅថាពូ នង) ស្ទៀង គួយ និងក្រុមផ្សេងទៀត ហើយមកដល់ពេលបច្ចុប្បន្ននេះ ភាសាជនជាតិភាគតិចចំនួន២៣ ត្រូវបានគេកំណត់។[19] ជនជាតិដើមភាគតិចនៅកម្ពុជារស់នៅក្នុងខេត្ត ១៥ នៃខេត្តទាំង២៤[20]នៅក្នុងប្រទេសនេះ ទោះបីជាជនជាតិដើមភាគច្រើនរស់នៅខេត្តភាគឦសានដូចជាខេត្តរតនគីរីនិងមណ្ឌលគីរីក៏ដោយ។[21] សហគមន៍ជនជាតិដើមភាគតិចជាធម្មតារស់នៅក្នុងភូមិស្វ័យត៍ដែលរៀបចំដោយខ្លួនឯង គ្រប់គ្រងដោយក្រុមមនុស្សចាស់ ដែលទទួលខុសត្រូវក្នុងការថែរក្សាសន្តិភាពនិងសណ្តាប់ធ្នាប់នៅក្នុងចំណោមពួកគេ និងកាត់សេចក្តីដោយផ្អែកទៅលើច្បាប់ប្រពៃណីក្នុងការដោះស្រាយ នៅពេលវិវាទកើតឡើង។[22]

តាមប្រពៃណីជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា ចិញ្ចឹមជីវិតតាមរយៈការដាំដុះលើដីព្រៃ ប្រើប្រាស់បច្ចេកទេសដែលគេហៅថាការធ្វើកសិកម្មវិលជុំ។[23] ពួកគេក៏បរបាញ់សត្វព្រៃនិងប្រមូលអនុផលព្រៃឈើ រួមមានដូចជា ផ្លែឈើ ទឹកឃ្មុំ ផ្កា ផ្សិត និងជ័រទឹក។ ជាងនេះទៀត ជំនឿ ប្រពៃណី និងអត្តសញ្ញាណរបស់សហគមន៍ជនជាតិដើមភាគតិច មានចំណងជិតស្និទ្ធទៅនឹងដី។ ដីធ្លីជាពិសេសគឺព្រៃដែលជាទីគោរពសក្ការៈដ៏សំខាន់ដល់វិញ្ញាណខ័ន្ធដូនតារបស់ពួកគេនិងអារុក្ខអារក្ខអ្នកតា។ ទំនាក់ទំនងជាមួយដូនតានិងជាមួយព្រលឹងអារុក្ខអារក្ខទាំងនេះបង្កើតបានជាអត្តសញ្ញាណនិងព្រលឹងវប្បធម៌ដ៏សំខាន់របស់សហគមន៍។ តាមពិតទៅ វាជាការលំបាកណាស់សម្រាប់ប្រជាជនដែលមិនមែនជាជនជាតិដើមភាគតិចក្នុងការយល់អំពីចំណងស្អិតរមួតដែលជនជាតិដើមភាគតិចមានជាប់ជាមួយនឹងដី។ ហាក់ដូចជាកង្វះខាតការយល់ដឹងអំពីចំណងដ៏ពិសេសរវាងជនជាតិដើម

---

[17] វេទិកាអចិន្ត្រៃយ៍អង្គការសហប្រជាជាតិស្តីពីបញ្ហាជនជាតិដើមភាគតិច "សម័យប្រជុំលើកទី៥ សលាកប័ត្រព័ត៌មាន១៖ ជនជាតិដើមភាគតិចនិងអត្តសញ្ញាណ" http://bit.ly/1mOcHLo

[18] វេទិកាអង្គការមិនមែនរដ្ឋាភិបាលនៃកម្ពុជា "ជនជាតិដើមភាគតិចនៅកម្ពុជា" (ខែមេសា ឆ្នាំ២០០៦) http://bit.ly/21tZ1rr

[19] អ៊ាន បែត "ជនជាតិដើមភាគតិចនិងដីធ្លី៖ ការប្រៀបធៀបប័ណ្ណកម្មសិទ្ធិដីសហគមន៍និងឥទ្ធិពលនៅក្នុងប្រទេសកម្ពុជានិងឡាវ" *ទស្សនៈអាស៊ីប៉ាស៊ីហ្វិក* វ៉ុល ៥៤ លេខ ៣ (ខែធ្នូ ឆ្នាំ២០១៣)

[20] ឡូរ៉ាម៉ាកឃើចណឺ "រស់នៅជាយសង្គម៖ អំពីស្ថានភាពនិងទីតាំងរបស់និគមជននិងជនជាតិដើមភាគតិចនៅកម្ពុជា" មូលនិធីហែនរិចបូលស្ទីហ្វស្ទង់ កម្ពុជា (ខែមិថុនា ឆ្នាំ២០១៥) http://bit.ly/1XFN911

[21] វេទិកាអង្គការមិនមែនរដ្ឋាភិបាលនៃកម្ពុជា "ជនជាតិដើមភាគតិចនៅកម្ពុជា" (ខែមេសា ឆ្នាំ២០០៦) http://bit.ly/21tZ1rr

[22] ឡូរ៉ាម៉ាកឃើចណឺ "រស់នៅជាយសង្គម៖ អំពីស្ថានភាពនិងទីតាំងរបស់និគមជននិងជនជាតិដើមភាគតិចនៅកម្ពុជា" មូលនិធីហែនរិចបូលស្ទីហ្វស្ទង់ កម្ពុជា (ខែមិថុនា ឆ្នាំ២០១៥) http://bit.ly/1XFN911

[23] ត្រូវបានសំដៅទៅលើកសិកម្មវិលជុំ។ នេះគឺជាទម្រង់មួយនៃកសិកម្មវិលជុំដែលគេឈូសឆាយដីសម្រាប់ធ្វើការដាំដុះ ជាធម្មតា តាមរយៈការកាត់និងដុតរុក្ខជាតិទាំងឡាយ ហើយបន្ទាប់មកដាំដុះមួយរយៈពេលខ្លី មុនពេលដែលបោះបង់ដីនោះចោល ហើយទៅរកតំបន់ថ្មីមួយទៀត រហូតដល់ពេលដល់ពេលដែលដីរដាតិដីកើតមានឡើងវិញតាមធម្មជាតិ។

ភាគតិចទៅនឹងដីនេះហើយដែលធ្វើឲ្យមានការប៉ះពាល់ដ៏មហន្តរាយសម្រាប់សហគមន៍ជនជាតិដើមភាគតិចដូចដែលអេរីកា អារ៉េនីដាស អតីតអ្នករាយការណ៍ពិសេសស្តីពីការការពារសម្បត្តិវប្បធម៌ និងកម្មសិទ្ធិបញ្ញារបស់ជនជាតិដើមភាគតិចបានលើកឡើងថា *"ការធ្វើឲ្យខូចបង់បន្តិចម្តងៗទៅលើសង្គមរបស់ជនជាតិដើមភាគតិចទាំងនេះអាចរកឃើញថាមានតម្រុយពាក់ព័ន្ធនឹងការមិនទទួលស្គាល់ទំនាក់ទំនងដ៏ជ្រាលជ្រៅដែលជនជាតិដើមភាគតិចមានជាប់ជាមួយនឹងដី ដែនដី និងធនធានរបស់ពួកគេ ..."*[24]

ក្នុងរយៈប៉ុន្មានឆ្នាំថ្មីៗនេះ ហេដ្ឋារចនាសម្ព័ន្ធដែលត្រូវបានកែលម្អឲ្យប្រសើរឡើងនោះ បានជួយឲ្យសហគ្រាសពាណិជ្ជកម្មចូលទៅដល់តំបន់ដាច់ស្រយាលដែលពីមុនមិនអាចចូលទៅដល់ នៅក្នុងប្រទេសនេះដែលមានអ្នករស់នៅភាគច្រើនជាជនជាតិដើមភាគតិច។ ហេតុដូច្នេះហើយ ប្រជាជនជាជនជាតិដើមភាគតិចដែលជាទូទៅរស់នៅកន្លែងដែលសំបូរធនធាននៅក្នុងប្រទេសនោះ កាន់តែមានភាពងាយរងគ្រោះច្រើនឡើងៗដោយសារការចាប់ដី ការកាប់បំផ្លាញព្រៃឈើ និងគំនាបផ្នែកពាណិជ្ជកម្ម។ ការផ្តល់អាទិភាពទៅលើគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ និងការជួលសម្បទានដីនៅក្នុងតំបន់ដែលជនជាតិដើមភាគតិចរស់នៅតាមបែបប្រពៃណីទាំងនេះ បានគំរាមកំហែងដល់ជីវភាពរស់នៅវប្បធម៌ និងអត្តសញ្ញាណរបស់សហគមន៍ជនជាតិដើមភាគតិច។ ដូចមានកត់សម្គាល់ដោយអង្គការសហប្រជាជាតិក្នុងឆ្នាំ២០០៧ ថា *"ការដកហូតដីរបស់ជនជាតិដើមភាគតិចតាមរយៈការផ្តល់សម្បទានដីសេដ្ឋកិច្ចនិងសម្បទានផ្សេងៗទៀត គឺកំពុងតែធ្វើឲ្យចុះខ្សោយដល់សមត្ថភាពរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងការចុះបញ្ជីកម្មសិទ្ធិសមូហភាពទៅលើដីប្រពៃណី និងដល់ការពង្រឹងសិទ្ធិរបស់ពួកគេក្នុងការទទួលបានដីធ្លីតាមច្បាប់ភូមិបាល"។*[25] ការផ្លាស់ប្តូរដ៏ឆាប់រហ័សបែបនេះចំពោះបរិស្ថានកំពុងតែកើតឡើងនៅក្នុងបរិបទដែលជាភាសាជាតិជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជាច្រើនតែស្ថិតក្នុងភាពអនក្ខរកម្មនៃភាសាជាតិគឺភាសាខ្មែរ និងជាបរិបទដែលអភិបាលកិច្ចមូលដ្ឋានដ៏ទន់ខ្សោយ និងកង្វះតម្លាភាពបានបង្កឧបសគ្គដ៏ធ្ងន់ធ្ងរចំពោះការចូលរួមរបស់ជនជាតិដើមភាគតិចនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត។[26]

សហគមន៍ជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា កំពុងតែបាត់បង់ដីសហគមន៍និងធនធានរបស់ខ្លួនយ៉ាងឆាប់រហ័ស ហើយជាលទ្ធផល ទំនៀមទម្លាប់និងប្រពៃណីរបស់ពួកគេដែលមានសារៈសំខាន់បំផុតក្នុងការ

---

[24] អនុគណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីការលើកកម្ពស់និងការការពារសិទ្ធិមនុស្ស "ជនជាតិដើមភាគតិចនិងទំនាក់ទំនងជាមួយដី៖ អត្ថបទចុងក្រោយរៀបចំដោយអ្នករាយការណ៍ពិសេស លោកស្រី អេរីកាអាយរីណៃ អេ ដេស E/CN.4/Sub.2/2001/21 (ខែមិថុនា ឆ្នាំ២០០១) http://bit.ly/1MJYUy7

[25] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា"ដីសម្បទានសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា"៖ទស្សនៈសិទ្ធិមនុស្សឆ្នាំ២០០៧ (ខែមិថុនា ឆ្នាំ២០០៧) http://bit.ly/1a47Sss

[26] សមាជិកសកម្មសិទ្ធិជនជាតិដើមភាគតិច (IRAM) "ជនជាតិដើមភាគតិចនៅកម្ពុជាកំពុងប្រឈមនឹងវិបត្តិ" សារណាដោយជនជាតិដើមភាគតិចនៅកម្ពុជា ដាក់ទៅកិច្ចប្រជុំរៀបចំសម្រាប់វេទិកាអចិន្ត្រៃយ៍របស់អង្គការសហប្រជាជាតិស្តីពីបញ្ហាជនជាតិដើមភាគតិច ដែលបានរៀបចំឡើងនៅក្នុងប្រទេសម៉ាឡេស៊ី នៅថ្ងៃទី ៤-៦ ខែមិនា ឆ្នាំ២០០៩ http://bit.ly/1Ufbvi3

អភិរក្សអត្តសញ្ញាណជនជាតិដើមភាគតិចនឹងបាត់បង់ជាបន្តបន្ទាប់ផងដែរ។ ដូចបានថ្លែងពីខាងដើមរួចហើយ យន្តការដោះស្រាយជម្លោះដែលមានស្រាប់នៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ ជាពិសេសសម្រាប់សហគមន៍ជនជាតិដើមភាគតិចដែលខ្វះខាតការយល់ដឹងខ្លាំងអំពីយន្តការបែបនេះ ហើយខ្វះមធ្យោបាយក្នុងការប្រើប្រាស់យន្តការទាំងនោះទៀតផង។ ប្រសិនបើគ្មានការចុះបញ្ជីជាផ្លូវការនិងការការពារផ្នែកច្បាប់ទៅលើដីសហគមន៍ទាំងនេះទេ ជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជានៅតែបន្តស្ថិតនៅក្នុងសភាពងាយរងគ្រោះជាខ្លាំងដោយសារការទន្ទ្រានយកដីពីសំណាក់អ្នកទទួលផលប្រយោជន៍ពីសម្បទានដីនិងបុគ្គលដែលមានអំណាច។ ប័ណ្ណកម្មសិទ្ធិដីសមូហភាពផ្តល់នូវការការពារសម្រាប់ដីរបស់ជនជាតដើមភាគតិច ប៉ុន្តែ ដំណើរការក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិមានភាពតឹងតែងក្រៃលែងនិងអូសបន្លាយពេលវេលាច្រើន ហើយវាស្ទើរតែមិនអាចទៅរួចទេសម្រាប់សហគមន៍ទាំងនោះក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដោយគ្មានជំនួយពីខាងក្រៅ។

ជំនួយគាំទ្រពីខាងក្រៅជាច្រើនត្រូវបានផ្តល់សម្រាប់ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។ ឧទាហរណ៍ ការគាំទ្ររបស់អង្គការពលកម្មអន្តរជាតិសម្រាប់គម្រោងជនជាតិដើមភាគតិចដែលបានចាប់ផ្តើមក្នុងឆ្នាំ២០០៥ ជួយដល់សហគមន៍ជនជាតិដើមក្នុងការចុះបញ្ជីដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពបានគាំទ្រដល់សហគមន៍ជនជាតិដើមចំនួន ១៦៦ នៅកម្ពុជាក្នុងអំឡុងពេលអនុវត្តគម្រោងនោះ។ ក្នុងចំណោមនោះ ១១៤ សហគមន៍បានបំពេញចប់សព្វគ្រប់ដំណាក់កាលទាំងបីនៅក្នុងដំណើរការចុះបញ្ជីកម្មសិទ្ធិដីសមូហភាពដោយបានទទួលជោគជ័យក្នុងការទទួលបានការទទួលស្គាល់អត្តសញ្ញាណ ហើយសហគមន៍ចំនួន៩៧ បានឈានដល់ដំណាក់កាលទីពីរនៃការចុះបញ្ជីជានីតិបុគ្គល។[27] ក្រៅពីនេះក៏មានការគាំទ្របន្ថែមទៀតសម្រាប់ការចុះបញ្ជីដីជនជាតិដើមភាគតិចកាលពីឆ្នាំ២០០៩ តាមរយៈអនុកម្មវិធីវិស័យរដ្ឋបាលដីធ្លីដែលមានពហុម្ចាស់ជំនួយការគាំទ្រ។ ក៏ប៉ុន្តែ ក្នុងកំឡុងពេលសរសេររបាយការណ៍នេះ មានសហគមន៍ជនជាតិដើមភាគតិចចំនួនតែ១១ ប៉ុណ្ណោះដែលបានទទួលប័ណ្ណកម្មសិទ្ធិដីសមូហភាពនៅទូទាំងប្រទេស។ ដូច្នេះ ប្រសិនបើគ្មានការគាំទ្រពីខាងក្រៅទេ ចំនួននេះអាចនឹងមានតិចជាងនេះ។ អ្នកសម្របសម្រួលគម្រោងគាំទ្រដល់ជនជាតិដើមភាគតិចនេះបានប្រាប់*សារព័ត៌មានឌឹខេមបូឌាដេលី* នៅពេលគម្រោងជិតដល់ពេលបញ្ចប់ថា *"ប្រសិនបើគ្មានការសម្របសម្រួលពីអង្គការពលកម្មអន្តរជាតិទេនោះ វានឹងត្រូវចំណាយពេលច្រើនជាងនេះ ហើយភូមិមួយចំនួននឹងមិនមានឱកាសក្នុងការទទួលបាន [ប័ណ្ណកម្មសិទ្ធិដីសមូហភាព] ទៀតទេ"។*[28]

---

[27] វេទិកាអចិន្ត្រៃយ៍របស់អង្គការសហប្រជាជាតិស្តីពីបញ្ហាជនជាតិដើមភាគតិច "បច្ចុប្បន្នភាពនៃសកម្មភាពអង្គការពលកម្មអន្តរជាតិទាក់ទងនឹងជនជាតិដើមភាគតិច"សម័យប្រជុំទី១៤ ក្រុងញូយ៉ក ថ្ងៃទី២០ ខែមេសា ដល់ ១ ខែឧសភា ឆ្នាំ២០១៥ http://bit.ly/1NrZHUT

[28] ម៉ាលីយ៉ា ហ្គុយើ ស្ទេវេន និង គុចណារ៉ែន "មូលនិធិសម្រាប់គម្រោងលើកកម្ពស់សិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច ត្រូវបញ្ចប់" *ឌឹខេមបូឌាដេលី* (ខែកុម្ភៈ ឆ្នាំ២០១៥) http://bit.ly/1VB50qn

ដូច្នេះ ប្រសិនបើគ្មានអន្តរាគមន៍ពន្លឿនឲ្យបានច្រើនទេ ការបាត់បង់ដីជាបន្តបន្ទាប់ដែលសហគមន៍ជនជាតិដើមភាគតិចកំពុងទទួលរងនេះនឹងទំនងជាធ្វើឲ្យយើងឃើញជនជាតិដើមភាគតិចដែលកំពុងតែរួមតូចខ្លាំងនេះ បាត់បង់ប្រពៃណីនិងទំនៀមទម្លាប់របស់ពួកគេជាក់ជាមិនខាន។

# ២. សិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា

ដោយសារតែដីត្រូវបានទន្ទ្រានយកក្នុងកម្រិតគួឲ្យកត់សម្គាល់ដែលកើតឡើងពាសពេញផ្ទៃប្រទេស សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជាស្ថិតក្នុងសភាពងាយរងគ្រោះជាពិសេស ចំពោះការបាត់បង់ដីធ្លីសម្រាប់ចិញ្ចឹមជីវិត ហើយពួកគេច្រើនតែទទួលរងការបណ្តេញចេញដោយបង្ខំ និងរារាំងពួកគាត់ក្នុងការទទួលបានដីប្រពៃណីរួមជាមួយនឹងការរំលោភបំពានជាច្រើនផ្សេងទៀតទៅលើសិទ្ធិដីធ្លីរបស់ខ្លួន។ ប្រព័ន្ធច្បាប់ជាក់លាក់ផ្នែកការការពារទៅលើសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិចពិតជាមានសារៈសំខាន់ណាស់។ ច្បាប់នៅកម្ពុជាមួយចំនួនធំមានបញ្ចូលស្តង់ដារច្បាប់អន្តរជាតិទាក់ទងនឹងសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច ហើយបើតាមទ្រឹស្តីគួរផ្តល់នូវការការពារផ្នែកច្បាប់គ្រប់គ្រាន់ដល់ជនជាតិដើមភាគតិច។ ក៏ប៉ុន្តែ ទោះបីជាមានកម្រងច្បាប់ការពារដ៏ស៊ីជម្រៅជាច្រើនក៏ដោយ ក៏ការការពារទាំងនេះកម្រត្រូវបានគេយកទៅអនុវត្តជាក់ស្តែងណាស់។

ជំពូកនេះ ផ្តល់នូវទិដ្ឋភាពទូទៅមួយនៃបរិបទផ្នែកច្បាប់ពាក់ព័ន្ធនឹងសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា ដោយពិនិត្យមើលទៅលើបទប្បញ្ញត្តិដែលពាក់ព័ន្ធ ទាំងក្នុងច្បាប់ជាតិនិងច្បាប់អន្តរជាតិ និងពិនិត្យមើលថាតើច្បាប់ដែលមានស្រាប់ទាំងនេះត្រូវបានគេអនុវត្តខ្ជាប់ខ្ជួនដែលឬយ៉ាងណា ។

## ២. ១ ទ្រឹស្តី៖ ក្របខ័ណ្ឌ ច្បាប់សម្រាប់ការពារ

### ២.១.១ ការការពារសិទ្ធិដីធ្លីជនជាតិដើមភាគតិចក្រោមច្បាប់អន្តរជាតិ

សិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិចត្រូវបានការពារយ៉ាងមុតមាំក្រោមច្បាប់អន្តរជាតិ។ ការការពារសិទ្ធិមនុស្សអន្តរជាតិ ត្រូវបានបញ្ចូលទៅក្នុងច្បាប់កម្ពុជា តាមរយៈមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ដែលចែងថាកម្ពុជាត្រូវទទួលស្គាល់និងគោរពសេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្ស ("ស.ប.ស.ស") និងកតិកានិងអនុសញ្ញាទាក់ទងនឹងសិទ្ធិមនុស្ស។[29] ដូច្នេះ ស្តង់ដារសិទ្ធិមនុស្សអន្តរជាតិអាចអនុវត្តបានដោយផ្ទាល់នៅក្នុងប្រព័ន្ធច្បាប់កម្ពុជាដូចដែលបានបញ្ជាក់សារជាថ្មីឡើងវិញដោយសេចក្តីសម្រេចមួយដែលធ្វើឡើងដោយក្រុមប្រឹក្សាធម្មនុញ្ញក្នុងឆ្នាំ២០០៧។[30]

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ដែលជាឯកសារដ៏សំខាន់បំផុតនៅក្នុងប្រវត្តិសាស្ត្រសិទ្ធិមនុស្សចែងនៅក្នុងមាត្រា ១៧ ថា *"មនុស្សគ្រប់រូប ទោះជាបុគ្គលក្តី សមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ"* ហើយថា *"គ្មានជនណាម្នាក់ត្រូវបានដកហូតកម្មសិទ្ធិដោយបំពានឡើយ"*។[31] មាត្រា២៥ នៃស.ស.ប.ស ធានា

[29] រដ្ឋធម្មនុញ្ញ មាត្រា៣១

[30] ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា៖ សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧/ (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧) http://bit.ly/1rmdbcj

[31] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (១០ ខែធ្នូ ឆ្នាំ១៩៤៨) មាត្រា១៧ http://bit.ly/1O8f0nS

សិទ្ធិទទួលបានលំនៅឋានសមរម្យ[32] ដែលរួមបញ្ចូលទាំងសិទ្ធិទទួលបានសន្តិសុខកាន់កាប់ និងទទួលបានការការពារពីការបណ្តេញចេញដោយបង្ខំទៀតផង។ សិទ្ធិទទួលបានលំនៅឋានសមរម្យ ក៏ត្រូវបាន ការការពារនៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌[33] អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រី[34] និងអនុសញ្ញាស្តីពីសិទ្ធិកុមារ។[35] បន្ថែមលើនេះ អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ បានហាមឃាត់ជាពិសេសចំពោះការរើសអើងពូជសាសន៍នៅក្នុងការទទួលបានសិទ្ធិទទួលបានលំនៅឋានសមរម្យ។[36] ប្រទេសកម្ពុជាបានក្លាយជាភាគីនៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ក្នុងឆ្នាំ ១៩៨៣ ហេតុដូច្នេះហើយ កម្ពុជាមានកាតព្វកិច្ចក្នុងការធានាថារាល់ក្រុមភាគតិចទាំងអស់ ដោយរាប់បញ្ចូលទាំងជនជាតិដើមភាគតិចផង ទទួលបានសិទ្ធិដែលមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍។ ជាចុងក្រោយ គោលការណ៍ទី៩ នៃគោលការណ៍ណែនាំស្តីពីការផ្លាស់ទីលំនៅក្នុងប្រទេសបានសង្កត់ធ្ងន់ថា *"រដ្ឋស្ថិតនៅក្រោមកាតព្វកិច្ចជាក់លាក់មួយក្នុងការការពារប្រឆាំងនឹងការផ្លាស់ប្តូរលំនៅដ្ឋានរបស់ជនជាតិដើមភាគតិច និគមជន ... និងក្រុមផ្សេងទៀតដែលមានការពឹងផ្អែកនិងអាស្រ័យផលលើ ដីរបស់ពួកគេ"។*[37]

លិខិតូបករណ៍ដែលផ្តល់ការការពារជាក់លាក់ដល់ ជនជាតិដើមភាគតិចនៅកម្ពុជាគឺជាសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច។ ប្រទេសកម្ពុជាបានបោះឆ្នោតគាំទ្រសេចក្តីប្រកាសនេះក្នុងឆ្នាំ២០០៧ ដែលមានមាត្រាមួយចំនួនបានចែងយ៉ាងច្បាស់អំពីការការពារជនជាតិដើមភាគតិចក្នុងការទទួលបានដីធ្លី។ តាមរយៈសេចក្តីប្រកាសនេះ ជនជាតិដើមភាគតិចមានសិទ្ធិធ្វើជាម្ចាស់ប្រើប្រាស់ អភិវឌ្ឍ និងគ្រប់គ្រងលើដី ដែនដី និងធនធាននានា ដែលពួកគេអាស្រ័យផល ដោយមូលហេតុនៃភាពជាម្ចាស់ ការកាន់កាប់និងការប្រើប្រាស់តាមបែបប្រពៃណី[38] ហើយរដ្ឋគួរផ្តល់នូវការទទួលស្គាល់និងការការពារផ្លូវច្បាប់ទៅលើដីធ្លីទាំងនោះ។[39] រដ្ឋត្រូវតែផ្តល់យន្តការប្រកបដោយប្រសិទ្ធភាពក្នុងការទប់ស្កាត់សកម្មភាពដែលធ្វើឲ្យជនជាតិដើមភាគតិចបាត់បង់សិទ្ធិធ្វើជាម្ចាស់ដីធ្លី ដែនដី និងធនធានរបស់ពួកគេ។[40] ជាងនេះទៀត រដ្ឋត្រូវពិគ្រោះយោបល់ជាមួយជនជាតិដើមភាគតិចដែលពាក់ព័ន្ធ ដើម្បីឲ្យទទួលបានការយល់ព្រមដោយមានការជូនដំណឹងជាមុន

---

[32] *ដដែល* មាត្រា២៥(១)

[33] អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (១៦ ខែធ្នូ ឆ្នាំ១៩៩៦) មាត្រា១១(១) http://bit.ly/J1E1V3

[34] អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រី (១៨ ខែធ្នូ ឆ្នាំ១៩៧៩) មាត្រា១៤ http://bit.ly/1jkl3IM

[35] អនុសញ្ញាស្តីពីសិទ្ធិកុមារ (២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩) មាត្រា២៧ http://bit.ly/1fGCcXV

[36] អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ មាត្រា៥, http://bit.ly/1k1MoiX

[37] ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ចរបស់អង្គការសហប្រជាជាតិ "គោលការណ៍ណែនាំស្តីពីការផ្លាស់ទីលំនៅក្នុងប្រទេស" គោលការណ៍ទី៩ (១១ ខែកុម្ភៈ ឆ្នាំ១៩៩៨) http://bit.ly/1GxBOfU

[38] សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច (សេចក្តីសម្រេចមហាសន្និបាត) ៦១/២៩៥ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧) មាត្រា២៦ http://bit.ly/1bKIrMs

[39] *ដដែល* មាត្រា២៦(៣)

[40] *ដដែល* មាត្រា៨(២)(ខ)

មុននឹងអនុម័តគម្រោងនានាដែលប៉ះពាល់ដល់ដីរបស់ពួកគេ។[41] សេចក្តីប្រកាសនោះចែងថាជនជាតិដើមភាគតិចមិនត្រូវគេបណ្តេញចេញដោយបង្ខំពីដីរបស់ពួកគាត់ទេ ហើយថាមិនមានការផ្លាស់ប្តូរទីលំនៅណាមួយដែលកើតឡើងដោយមិនមានការយល់ព្រម ដោយមានការជូនដំណឹងជាមុនពីជនជាតិដើមភាគតិចដែលពាក់ព័ន្ធឡើយ។[42] ជាងនេះទៀត តាមរយៈឧបករណ៍ទាំងនេះ ជនជាតិដើមភាគតិចត្រូវមានសិទ្ធិទទួលបានសំណងសម្រាប់ដីធ្លី ទឹកដី និងធនធានរបស់ពួកគេ ដែលត្រូវបានគេរឹបអូស គេកាន់កាប់ ឬបំផ្លាញ ដោយមិនមានការយល់ព្រម និង ជូនដំណឹងជាមុននៅឡើយ។[43] ទោះបីជាសេចក្តីប្រកាសរបស់មហាសន្និបាតស្តីពីសិទ្ធិជនជាតិ ដើមភាគតិច មិនចងកាតព្វកិច្ចផ្លូវច្បាប់ក៏ដោយ ក៏ *"តំណាងឲ្យការអភិវឌ្ឍប្រកបដោយភាពស៊េរើកនៃបទដ្ឋាន ច្បាប់អន្តរជាតិនិងឆ្លុះបញ្ចាំងអំពីការប្តេជ្ញាចិត្តរបស់រដ្ឋក្នុងការឆ្ពោះទៅកេទិសដៅជាក់លាក់មួយដោយប្រកាន់ខ្ជាប់តាមគោលការណ៍មួយចំនួន។*[44]

ក៏ប៉ុន្តែ ខណៈដែលកម្ពុជាបោះឆ្នោតគាំទ្រសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច កម្ពុជាមិនទាន់បានផ្តល់សច្ចាប័នដល់អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ ១៦៩ ស្តីពីជនជាតិដើមភាគតិចនិងក្រុមកុលសម្ពន្ធដែលផ្តល់ការការពារផ្លូវច្បាប់ដ៏រឹងមាំសម្រាប់ជនជាតិដើមភាគតិចនៅឡើយទេ។ អនុសញ្ញានេះគឺជាឧបករណ៍ច្បាប់អន្តរជាតិដ៏សំខាន់មួយក្នុងការគាំទ្រដល់គោលការណ៍គ្រប់គ្រងដោយខ្លួនឯងក្នុងការការពារវប្បធម៌និងសហគមន៍ជនជាតិដើមភាគតិច និងគាំទ្រដល់សិទ្ធិទទួលបានដីនិងធនធានប្រពៃណីព្រមទាំងក្នុងការលើកទឹកចិត្តឲ្យមានការប្រព្រឹត្តដោយស្មើភាពគ្នានិងការទទួលបានសេវាកម្មរបស់រដ្ឋដោយស្មើភាពគ្នាដែរ។ ចំណុចសំខាន់គឺទាមទារឲ្យមានការចូលរួមនិងពិគ្រោះយោបល់ពីជនជាតិដើមភាគតិចទៅលើបញ្ហាទាំងឡាយដែលប៉ះពាល់ដល់ពួកគេជាពិសេសបញ្ហាអភិវឌ្ឍន៍។[45] តាមរយៈការខកខានមិនបានផ្តល់សច្ចាប័នអនុសញ្ញាលេខ ១៦៩ នេះកម្ពុជាបង្ហាញអំពីកង្វះចេតនាក្នុងការផ្តល់នូវកម្លាំងផ្លូវច្បាប់ពិតប្រាកដក្នុងការការពារសិទ្ធិជនជាតិដើមភាគតិច។

### ២.១.២ ការការពារសិទ្ធិដីធ្លីជនជាតិដើមភាគតិចក្រោមច្បាប់អន្តរជាតិ

រដ្ឋធម្មនុញ្ញធានាថាពលរដ្ឋទាំងអស់មានសិទ្ធិដូចគ្នា *"ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ... ជំនឿសាសនា"* ឬភាពខុសគ្នាផ្សេងទៀត[46]ខណៈដែលច្បាប់ភូមិបាលឆ្នាំ២០០១("ច្បាប់ភូមិបាល"[47])

---

[41] *ដដែល* មាត្រា២៣(២)

[42] *ដដែល* មាត្រា១០

[43] *ដដែល* មាត្រា២៨

[44] វេទិកាអចិន្ត្រៃយ៍របស់អង្គការសហប្រជាជាតិស្តីពីបញ្ហាជនជាតិដើមភាគតិច "សំណួរដែលត្រូវបានសួរញឹកញាប់៖ សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច http://bit.ly/1QNk9Wq

[45] អង្គការពលកម្មអន្តរជាតិ៖ អនុសញ្ញាស្តីពីជនជាតិដើមភាគតិចនិងក្រុមកុលសម្ព័ន្ធ ឆ្នាំ១៩៨៩ (លេខ ១៦៩) សម័យប្រជុំលើកទី៧៦ (២៧ ខែមិថុនា ឆ្នាំ១៩៨៩) (ចូលជាធរមាននៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩៩១) http://bit.ly/1O0X1Dc

[46] រដ្ឋធម្មនុញ្ញ មាត្រា៣១

និងអនុក្រឹត្យលេខ៨៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីធ្លីសម្រាប់សហគមន៍ជនជាតិដើមភាគតិច ("អនុក្រឹត្យ ៨៣")[48] ផ្តល់នូវការការពារជាក់លាក់ចំពោះសិទ្ធិជនជាតិដើមភាគតិចក្នុងការទទួលបានដីធ្លីនៅកម្ពុជា។ ច្បាប់ភូមិបាលជាច្បាប់ដំបូងគេនៅកម្ពុជាដែលបានទទួលយ៉ាងច្បាស់អំពីអត្ថិភាពរបស់ជនជាតិដើមភាគតិច ព្រមទាំងបានរៀបរាប់យ៉ាងច្បាស់អំពីសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិចនៅក្នុងជំពូក៣ ផ្នែក២ ដែលមានចំណងជើងថា *"អចលនទ្រព្យរបស់សហគមន៍ជនជាតិដើមភាគតិច"* ដែលបានកំណត់និយមន័យសហគមន៍ ជនជាតិដើមភាគតិចថា *"ក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទម្លាប់នៃការប្រើប្រាស់ជាសមូហភាព"។*[49] ក្នុងមាត្រា ២៦ ច្បាប់ភូមិបានបានទទួលស្គាល់យ៉ាងច្បាស់ អំពីបញ្ញត្តិនៃកម្មសិទ្ធិសមូហភាពដីរបស់សហគមន៍ជនជាតិដើម ភាគតិចក្នុងទម្រង់ប័ណ្ណកម្មសិទ្ធិដីសមូហភាព។[50] ដូច្នេះ ច្បាប់ភូមិបាល គឺជាឯកសារច្បាប់ដ៏មានសារៈសំខាន់បំផុតសម្រាប់សិទ្ធិជាសមូហភាពក្នុងការទទួលបានដីធ្លីសម្រាប់ជនជាតិដើមភាគតិច។

*រូបទី ១៖*

| ប្រភេទដីដែលអាចទទួលប័ណ្ណកម្មសិទ្ធិដីសមូហភាព | | | | |
|---|---|---|---|---|
| ដីដែលមានរដ្ឋជាម្ចាស់ | | | | |
| ដីឯកជនរបស់រដ្ឋ (ងាយនឹងត្រូវផ្តល់ឲ្យជាសម្បទានដីសេដ្ឋកិច្ច) | | ដីសាធារណៈរបស់រដ្ឋ | | |
| ដីលំនៅដ្ឋាន | ដីដាំដុះ | ព្រៃអារក្ស | ដីបញ្ចុះសព | ដីបម្រុង (សម្រាប់កសិកម្មវិលជុំ) |

អនុក្រឹត្យ ៨៣ ផ្តល់និយមន័យបន្ថែមចំពោះដីសហគមន៍ជនជាតិដើមភាគតិច និងចែងថា អាចមានប្រាំប្រភេទ (១) ដីលំនៅដ្ឋាន (២) ដីដាំដុះ (៣) ដីបម្រុងចាំបាច់សម្រាប់ធ្វើកសិកម្មវិលជុំ (៤) ដីព្រៃអារក្ស និង (៥) ដីព្រៃបញ្ចុះសព។[51] ដីពីរប្រភេទខាងដើម (ដីលំនៅដ្ឋាន និងដីដាំដុះ) អាចជាដីដែលត្រូវបានចុះបញ្ជីរួចជាមួយរដ្ឋក្នុងឋានៈជាដីឯកជនរបស់រដ្ឋ[52] (សូមមើល រូបទី ១)។ រីឯប្រភេទដីបីផ្សេងទៀតនោះ អាចរួមបញ្ចូលដីដែលត្រូវបានចុះបញ្ជីជាដីសាធារណៈរបស់រដ្ឋ។ ទាំងតម្រូវការនិងការសន្និដ្ឋានដែលថាដីដែលប្រើដោយសហ

---

[47] ច្បាប់ភូមិបាល សន/រកម/០៨០១/១៤ (២០ ខែកក្កដា ឆ្នាំ២០០១)

[48] អនុក្រឹត្យ៨៣ អនក្រ/បក (៩ ខែមិថុនា ឆ្នាំ២០០៩)

[49] ច្បាប់ភូមិបាល មាត្រា២៣

[50] ច្បាប់ភូមិបាល មាត្រា២៦

[51] អនុក្រឹត្យលេខ ៨៣ មាត្រា៤

[52] *ដដែល* មាត្រា៦

គមន៍ជនជាតិដើមភាគតិចជាដីរដ្ឋនោ ធ្វើឲ្យដីទាំងនេះប្រឈមនឹងហានិភ័យនៃការដែលត្រូវរដ្ឋយកទៅធ្វើកម្មសិទ្ធិ។ នេះដោយសារថា ប្រសិនបើមិនទាន់បានចុះបញ្ជីជាដីសហគមន៍ជនជាតិដើមភាគតិចទេ ប្រភេទដីទាំងនេះ ត្រូវបានចាត់ថ្នាក់ជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយអាចត្រូវបានផ្តល់ឲ្យជាសម្បទានដីសេដ្ឋកិច្ច។[53] ក៏ប៉ុន្តែ បើយោងតាមច្បាប់ភូមិបាល សហគមន៍ជនជាតិដើមភាគតិច អាចមានសិទ្ធិបន្តចាត់ចែងនិងប្រើប្រាស់ដីរបស់ខ្លួនតាមទំនៀមទម្លាប់ប្រពៃណីរបស់ខ្លួន។[54] ជាងនេះទៀត សហគមន៍ជនជាតិដើមភាគតិចមានសិទ្ធិបន្តប្រើប្រាស់ដីព្រៃតាមប្រពៃណីរបស់ខ្លួនដូចមានចែងនៅក្នុងច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២ ដែលរួមបញ្ចូលទាំងសិទ្ធិក្នុងការប្រមូលអនុផលព្រៃឈើនិងប្រើប្រាស់ឈើសម្រាប់ធ្វើផ្ទះ និងក្រោលសត្វព្រមទាំងកាត់ស្មៅនិងឲ្យសត្វស៊ី។[55] អនុក្រឹត្យ ៨៣ បន្ថែមទៀតថាសហគមន៍ជនជាតិដើមភាគតិចមានសិទ្ធិបន្តប្រើប្រាស់ប្រភពទឹកនៅក្នុងព្រៃ ឧទាហរណ៍ អូរ និងទន្លេ។ ក៏ប៉ុន្តែ អនុក្រឹត្យ ៨៣ ចែងថាដើម្បីបន្តការប្រើប្រាស់តាមបែបប្រពៃណីទៅលើដីនោះ សហគមន៍ត្រូវធ្វើកិច្ចព្រមព្រៀងជាមួយអាជ្ញាធរពាក់ព័ន្ធ[56] ដែលផ្ទុយនឹងច្បាប់ស្តីពីព្រៃឈើ ដែលបានចែងថាមិនតម្រូវឲ្យមានការសុំអនុញ្ញាតនោះទេ។[57] ដោយសារតែច្បាប់ស្តីពីព្រៃឈើជាឧបករណ៍ច្បាប់ដែលមានឋានៈខ្ពស់ជាងអនុក្រឹត្យ៨៣ នោះច្បាប់ស្តីពីព្រៃឈើត្រូវមានឥទ្ធិពលជាង[58] ហេតុដូច្នេះនៅក្នុងការអនុវត្តជាក់ស្តែងសហគមន៍មិនតម្រូវឲ្យសុំអនុញ្ញាតដើម្បីបន្តប្រើប្រាស់ដីរបស់ខ្លួនតាមប្រពៃណីឡើយ។

*តារាងទី១៖ សិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា-សង្ខេប*

| សិទ្ធិ | សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស | អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ | អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ | សេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច | អនុសញ្ញាអង្គការពលកម្មអន្តរជាតិ ១៦៩ | រដ្ឋធម្មនុញ្ញ | ច្បាប់ក្នុងប្រទេស |
|---|---|---|---|---|---|---|---|
| សិទ្ធិធ្វើជាម្ចាស់ទ្រព្យសម្បត្តិ | ✓ | | | | | ✓ | ✓ |
| សិទ្ធិទទួលបាន | ✓ | ✓ | | | | | |

---

[53] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "កម្ពុជា"៖ ជម្លោះដីធ្លី និងទិដ្ឋភាពទូទៅនៃស្ថានភាពដីធ្លី (របាយការណ៍) (ខែធ្នូ ឆ្នាំ២០១៣) http://bit.ly/1KtPNVy

[54] ច្បាប់ភូមិបាល មាត្រា២៣

[55] ច្បាប់ស្តីពីព្រៃឈើ នស/រកម/០៨០២/០១៦ (ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០២) មាត្រា៤០ http://bit.ly/1tbrB3i

[56] អនុក្រឹត្យលេខ ៨៣

[57] ច្បាប់ស្តីពីព្រៃឈើ មាត្រា ៤០

[58] ឋានានុក្រមច្បាប់ក្នុងប្រទេសកម្ពុជា មើល (សលាកប័ត្រ របស់ ម.ស.ម.ក) (មករា២០១៤) http://bit.ly/1IKTN4m

| | | | | | | | |
|---|---|---|---|---|---|---|---|
| លំនៅដ្ឋានសមរម្យ | | | | | | | |
| សិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ | ✓ | | | ✓ | ✓ | ✓ | |
| សិទ្ធិទទួលបានការការពារឲ្យជៀសផុតពីការរើសអើងពូជសាសន៍ក្នុងការទទួលបានលំនៅដ្ឋាន | ✓ | | ✓ | ✓ | ✓ | | |
| សិទ្ធិធ្វើជាម្ចាស់និងប្រើប្រាសដីប្រពៃណី | | | | ✓ | ✓ | | ✓ |
| សិទ្ធិទទួលបានការការពារតាមផ្លូវច្បាប់ទៅលើកម្មសិទ្ធិដីប្រពៃណី | | | | ✓ | ✓ | | ✓ |
| សិទ្ធិទទួលបានការពិគ្រោះយោបល់មុនពេលការអភិវឌ្ឍន៍ប៉ះពាល់ដីជនជាតិដើមភាគតិច | | | | ✓ | ✓ | | ✓ |
| សិទ្ធិទទួលបានដំណោះស្រាយសម្រាប់ការបំពានសិទ្ធិដីធ្លី | ✓ | | | ✓ | ✓ | | ✓ |
| សិទ្ធិការពារមធ្យោបាយចិញ្ចឹមជីវិតរបស់សហគមន៍ | | ✓ | | | | | |

## ២.២ ក្នុងការអនុវត្តៈ ការចុះបញ្ជីដីជនជាតិដើមភាគតិច

ទោះបីជាច្បាប់ភូមិបាលទទួលស្គាល់សិទ្ធិសហគមន៍ជនជាតិដើមភាគតិចក្នុងការចុះបញ្ជីដីរបស់ពួកគេ និងទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពក៏ដោយ ក៏ក្នុងការអនុវត្តជាក់ស្តែង ដំណើរការក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះមានភាពស្មុគស្មាញនិងត្រូវបានពន្យារពេល។ មកដល់ពេលសរសេររបាយការណ៍នេះ មានសហគមន៍ចំនួនតែ១១ ក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិច១៦៦[59] ដែលបានចាប់ផ្តើមដំណើរការនេះបានទទួលប័ណ្ណកម្មសិទ្ធិដីសមូហភាពដើម្បីការពារដីរបស់ពួកគេ។ ភាពស្មុគស្មាញនៃក្របខណ្ឌច្បាប់ដែលការពារសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច រួមជាមួយនឹងការអនុវត្តច្បាប់មិនបានគ្រប់គ្រាន់នោះនៅតែជាមូលហេតុចម្បងដែលមានការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះក្នុងចំនួនតិចតួចបំផុត។ ការណែនាំអំពីវិធីដែលសហគមន៍ជនជាតិដើមភាគតិចអាចទទួលបានប័ណ្ណកម្មសិទ្ធិដីសហមូហភាព ទើបតែដាក់ចេញនៅក្នុងឆ្នាំ២០០៩[60]ប៉ុណ្ណោះ គឺប្រាំបីឆ្នាំក្រោយពេលច្បាប់ភូមិបាលត្រូវបានអនុម័ត។ ពេលវេលាដែលបានកន្លងផុតទៅនោះមានសារៈសំខាន់ណាស់ ពីព្រោះនៅក្នុងអំឡុងពេលចន្លោះពីការអនុវត្តច្បាប់ភូមិបាលឆ្នាំ២០០១ និងការចេញអនុក្រឹត្យ ៨៣ ក្នុងខែមិថុនា ឆ្នាំ២០០៩ មានផ្ទៃដីចំនួន ២.១០៦.៣៤៣ ហិកតានៅកម្ពុជាត្រូវបានផ្តល់តាមរយៈសម្បទានដីសេដ្ឋកិច្ច។[61]

### ២.២.១ ដំណើរការចុះបញ្ជីដីសម្រាប់ប័ណ្ណកម្មសិទ្ធដីសហមូហភាព

ដំណើរការសម្រាប់ចុះបញ្ជីកម្មសិទ្ធិដីសមូហភាព មានរយៈពេលវែងនិងមានភាពស្មុគស្មាញក្រៃលែង។ ក្នុងការអនុវត្តជាក់ស្តែង សហគមន៍ត្រូវតែបំពេញដំណាក់កាលចំនួនបីដែលមានរួមជំហានជាច្រើន ដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះ គឺដំបូងសហគមន៍ត្រូវតែទទួលបានការទទួលស្គាល់អត្តសញ្ញាណខ្លួនឯងជាផ្លូវការថាជា *"វប្បធម៌ប្រពៃណី"* មួយ ពីក្រសួងអភិវឌ្ឍន៍ជនបទ ហើយបន្ទាប់មកសហគមន៍ត្រូវដាក់ពាក្យសុំការទទួលស្គាល់ជា *"នីតិបុគ្គល"* ជាមួយនឹងក្រសួងមហាផ្ទៃ និងជាចុងក្រោយ សហគមន៍ត្រូវដាក់សំណើសុំចុះដីសហគមន៍ទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដើម្បីចុះបញ្ជីដីរបស់ពួកគេ និងដើម្បីឲ្យក្រសួងចេញប័ណ្ណកម្មសិទ្ធិដីសមូហភាពឲ្យ។[62]

សភាពស្មុគស្មាញនៃដំណើរការនេះ រួមជាមួយនឹងការខ្វះខាតធនធាននៅក្នុងសហគមន៍ជនជាតិដើមភាគតិចទាមទារចាំបាច់ឲ្យមានជំនួយពីខាងក្រៅដើម្បីបំពេញដំណើរការចុះបញ្ជីដីសមូហភាពនេះ។ ជាងនេះ

---

[59] តួលេខយោងតាមរបាយការណ៍របស់អង្គការពលកម្មអន្តរជាតិ "បញ្ជីបច្ចុប្បន្នភាពនៃវឌ្ឍនភាពប័ណ្ណកម្មសិទ្ធិដីសមូហភាពដែលគាំទ្រដោយ ILO GIZ និងអង្គការមិនមែនរដ្ឋាភិបាល និងគោលដៅដែលរងការប៉ះពាល់ដោយបទបញ្ជា០១ ពីឆ្នាំ២០១៣ ដល់ ថ្ងៃ១៣ មករា ២០១៥ (ខែមករា ២០១៥)

[60] អនុក្រឹត្យលេខ ៨៣

[61] លីកាដូ "ការផ្តល់ដ៏ច្រើនក្នុងប្រទេសកម្ពុជា៖ ការផ្តល់សម្បទានដីពីពេលមួយទៅពេលមួយ" (១មិនា២០១៣) http://bit.ly/HxpSOV

[62] អនុក្រឹត្យលេខ ៨៣

ទៀត តាមអនុក្រឹត្យ ៨៣ ចែងថាសហគមន៍ជនជាតិដើមភាគតិចត្រូវបានអនុញ្ញាតិឲ្យចុះបញ្ជីដីសមូហភាពបាន ត្រឹមតែ ៧ ហិកតា នៃដីបញ្ចុះសពនិងព្រៃអារក្សតែប៉ុណ្ណោះ ដែលការដាក់កំហិតនេះផ្ទុយនឹងច្បាប់ភូមិបាល ដែលមិនអនុញ្ញាតិឲ្យមានការដាក់កំហិតតាមទំនើងចិត្តទៅលើដីបែបនេះទេ។

### ២.២.២ វិធានការការពារបណ្តោះអាសន្ន

តាមសភាពនៃការពន្យារពេលនៃដំណើរការចុះបញ្ជីនេះ កង្វះខាងសន្តិសុខក្នុងការកាន់កាប់សម្រាប់សហគមន៍ជនជាតិដើមភាគតិចនៅក្នុងដំណើរការដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះ គឺជាការព្រួយបារម្ភយ៉ាងខ្លាំង។ ក្នុងឆ្នាំ២០១១ សារាចរអន្តរក្រសួងស្តីពីវិធានការការពារបណ្តោះអាសន្នពាក់ព័ន្ធនឹងដីរបស់សហគមន៍ជនជាតិដើមភាគតិចដែលបានដាក់សុំប័ណ្ណកម្មសិទ្ធិសមូហភាពនេះ ត្រូវបានប្រកាសចេញមក ដែលបទប្បញ្ញត្តិនៅមូលដ្ឋាននឹងត្រូវប្រកាសចេញក្នុងការណែនាំប្រជាជនឲ្យឈប់ជាបណ្តោះអាសន្ននូវរាល់ទម្រង់នៃការជួញដូរដីធ្លី ព្រមទាំងជាការជូនដំណឹងដល់អាជ្ញាធរមូលដ្ឋានឲ្យឈប់បញ្ជាក់ការលក់ដូរដីធ្លីសម្រាប់តំបន់ដីដែលត្រូវបានស្នើសុំចុះបញ្ជីដីសមូហភាព។ ក៏ប៉ុន្តែ ការការពារក្រោមការណែនាំទាំងនេះមានកម្រិតតិចតួចបំផុត គឺថា សន្តិសុខក្នុងការកាន់កាប់ត្រូវបានធានាតែនៅដំណាក់ចុងក្រោយនៃដំណើរការនេះប៉ុណ្ណោះ គឺនៅពេលដែលសហគមន៍បានដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពជាមួយនឹងក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ រួចហើយ។[63] បន្ថែមពីលើនេះ វិធានការការពារទាំងនេះ មិនបានបញ្ចូលដីដែលរដ្ឋាភិបាលបានយល់ព្រមផ្តល់សម្រាប់ការវិនិយោគឬអភិវឌ្ឍន៍មុនពេលវិធានការទាំងនេះចូលជាធរមាន[64] ដូច្នេះ ដីដែលទទួលរងការប៉ះពាល់នៅក្នុងសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់នោះ មិនទទួលបានការការពារទេ។

### ២.២.៣ ការធ្វើផែនការប្រើប្រាស់ដីតាមវិធីសាស្រ្តចូលរួម

ការធ្វើផែនការប្រើប្រាស់ដីតាមវិធីសាស្រ្តចូលរួម គឺជាគំរូនៃការគ្រប់គ្រងការប្រើប្រាស់ដីមួយបែបដែលមានបំណងឲ្យភាគីពាក់ព័ន្ធទាំងអស់ ផ្តល់មតិយោបល់អំពីការបែងចែកដីធ្លីនៅក្នុងតំបន់ជាក់លាក់ណាមួយ។ ការធ្វើផែនការប្រើប្រាស់ដីតាមវិធីសាស្រ្តចូលរួមនេះ ពាក់ព័ន្ធនឹងការព្រាងបទប្បញ្ញត្តិប្រើប្រាស់ដីធ្លី ការអនុវត្តការ បែងចែក និងការការពារតំបន់ដីអភិរក្សដែលត្រូវបានបង្កើតឡើងទៀតផង។ តាមរយៈការដាក់ឲ្យប្រើប្រាស់ វិធីសាស្រ្តនេះក្នុងទសវត្សឆ្នាំ២០០០ បន្ទាប់ពីការសាកល្បងរួចមក ទីបំផុត ការធ្វើផែនការប្រើប្រាស់ដីតាមវិធីសាស្រ្តចូលរួមនេះត្រូវបានរំលាយចោលវិញក្នុងឆ្នាំ២០០៨។ កំឡុងពេលអនុវត្តនៅក្នុងប្រទេសកម្ពុជា ការធ្វើផែនការប្រើប្រាស់ដីតាមវិធីសាស្រ្តចូលរួម ត្រូវបាន ប្រើនៅក្នុងសហគមន៍ជនបទ ដោយរួមទាំងសហគមន៍ជនជាតិដើមភាគតិចក្នុងការផ្តល់នូវភាពច្បាស់លាស់ទៅលើការប្រើប្រាស់ដីបច្ចុប្បន្ននៅក្នុងតំបន់និមួយៗ

---

[63] ក្រសួងមហាផ្ទៃនិងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សារាចរអន្តរក្រសួងស្តីពីវិធានការការពារបណ្តោះអាសន្នក្នុងការការពារដីធ្លីជនជាតដើមភាគតិច (២០០១)

[64] ក្រសួងមហាផ្ទៃនិងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សារាចរអន្តរក្រសួងស្តីពីវិធានការការពារបណ្តោះអាសន្ន ក្នុងការការពារដីធ្លីជនជាតដើមភាគតិច (២០០១)

ហើយក្នុងករណីខ្លះសម្រាប់ដោះស្រាយវិវាទដីធ្លីផងដែរ។ ទោះបីជាការធ្វើផែនការប្រើប្រាស់ដីតាមវិធីសាស្ត្រចូលរួមនេះ ទទួលរងការរិះគន់ ហើយសម្បទានដីសេដ្ឋកិច្ចត្រូវបានផ្តល់ឲ្យដោយជាន់លើដីដែលទទួលស្គាល់នៅក្នុងផែនទីដែលបានមកពីការធ្វើផែនការប្រើប្រាស់ដីតាមវិធីសាស្ត្រចូលរួមនេះក៏ដោយ ក៏សម្រាប់សហគមន៍ជនជាតិដើមភាគតិចដែលកាន់កាប់ដីនោះ ផែនទីទាំងនេះគឺជាឧបករណ៍ដ៏មានប្រយោជន៍ ដែលផ្តល់ភាពត្រឹមត្រូវទៅលើការប្រើប្រាស់ដីរបស់ខ្លួន ដោយសារតែវាមានការទទួលស្គាល់ប្រភេទនៃការប្រើប្រាស់ដីផ្សេងៗ ដូចជាព្រៃអារក្ស ព្រៃបញ្ចុះសព និងដែលប្រើសម្រាប់ធ្វើកសិកម្មវិលជុំទៀតផង[65]។

## ២.២.៤ យុទ្ធនាការពន្លឿនការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី

នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ រដ្ឋាភិបាលបានប្រកាសពីចេតនារបស់ខ្លួនក្នុងការដាក់ឲ្យប្រើប្រាស់យុទ្ធនាការពន្លឿនការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដែលត្រូវអនុវត្តដោយយុវជនស្ម័គ្រចិត្តដើម្បីគ្របដណ្តប់ទៅលើតំបន់ដែលពលរដ្ឋរស់នៅដោយគ្មានឯកសារផ្លូវច្បាប់គ្រប់គ្រាន់នៅលើដីរដ្ឋដែលត្រូវបានផ្តល់ជាសម្បទានសេដ្ឋកិច្ច ឬសម្បទានព្រៃឈើ។ កម្មវិធីនេះមិនបានដាក់បញ្ចូលតំបន់ដីជម្លោះ ហេតុដូចនេះហើយប្រជាពលរដ្ឋងាយរងគ្រោះបំផុតក៏មិនបានបញ្ចូលទៅក្នុងកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិនេះផងដែរ។ កម្មវិធីបានទទួលរងការរិះគន់ដោយសារតែភាពគ្មានប្រសិទ្ធភាព កង្វះតម្លាភាព មានលក្ខណៈនយោបាយខ្លាំង និងមានលក្ខណៈក្រៅច្បាប់។[66] របាយការណ៍បានលើកឡើងអំពីអាជ្ញាធរដែលបង្កកទុកប័ណ្ណកម្មសិទ្ធិ ខណៈពេលដែលអ្នកផ្សេងមួយចំនួនបានបាត់បង់ដីនៅក្នុងដំណើរការនេះ។ ចាប់តាំងពីកម្មវិធីនេះត្រូវបានបន្តក្នុងខែវិច្ឆិកា ឆ្នាំ២០១៣ ក្រោយពេលពន្យារពេលកាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣ មុនពេលបោះឆ្នោតជាតិថ្ងៃទី២៨ ខែកក្កដា វិញ ការអនុវត្តមានសភាពយឺតយ៉ាវបំផុត។

ប្រការគួរឲ្យកត់សម្គាល់នោះគឺ សហគមន៍ជនជាតិដើមភាគតិចត្រូវបានមិនរាប់បញ្ចូលក្នុងកម្មវិធីនេះ គឺថា ប៉ុន្មានថ្ងៃបន្ទាប់ពីសេចក្តីណែនាំលេខ ១៥ ត្រូវបានប្រកាសដោយរដ្ឋាភិបាល ដែលអនុញ្ញាតឲ្យមានការចេញប័ណ្ណកម្មសិទ្ធិដីសមូហភាព សេចក្តីណែនាំលេខ ២០ ត្រូវបានប្រកាសដែលជាការដកហូតសិទ្ធិក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព។ សេចក្តីណែនាំលេខ ២០ ចែងថា មូលហេតុនៅពីក្រោយការពន្យារពេលចេញប័ណ្ណកម្មសិទ្ធិដីសមូហភាពពីកម្មវិធីនេះ គឺដោយសារតែការលំបាកនានាក្នុងការកំណត់អត្តសញ្ញាណដីជនជាតិដើមភាគតិចដែលទាមទារឲ្យមាន *"រយៈពេលវែងនិងថវិកាចំណាយច្រើន"*។[67] លើសពីនេះ សេចក្តីណែនាំលេខ ២០ បានបញ្ចូលបទប្បញ្ញត្តិមួយដែលអនុញ្ញាតិឲ្យជនជាតិដើមភាគតិច *"ដកខ្លួន"* ចេញពីសហគមន៍ ប្រសិនបើពួកគេប្រាថ្នាចង់បានប័ណ្ណកម្មសិទ្ធិដីឯកជន ដោយគ្រាន់តែផ្តិតមេដៃលើកិច្ចសន្យាមួយ។ ជាការដែលមិនគួរឲ្យ

---

[65] សារ៉ា មីលីន និង ប៊ីលអាដាម "របាំងមុខទីផ្សារ៖ ការលោតត្រដាងអំពីនយោបាយនៃការចំណាយនៅថ្នាក់ឃុំសម្រាប់សេវាបរិស្ថានក្នុងប្រទេសកម្ពុជា" *ការអភិវឌ្ឍន៍និងការផ្លាស់ប្តូរ* វ៉ុល៤៣ លេខ១ (ខែកុម្ភៈ ឆ្នាំ២០១២)

[66] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "កម្ពុជា៖ ដីទំនាស់ ទិដ្ឋភាពទូទៅនៃស្ថានភាពដីធ្លី" (ខែធ្នូ ឆ្នាំ២០១៣) http://bit.ly/1KtPNVy

[67] ជេហ្វរ៉ាយ និង មែនហ្វ្រេដ ហ៊ាននុង មូលនិធិហៃនរិចបូល "ជនជាតិដើមភាគតិចនិងប័ណ្ណកម្មសិទ្ធិដីធ្លីក្នុងប្រទេសកម្ពុជា" សន្និសីទប្រចាំឆ្នាំរបស់ធនាគារពិភពលោកស្តីពីដីធ្លីនិងភាពក្រីក្រឆ្នាំ២០១៣ ថ្ងៃទី៨-១១ ខែមេសា ឆ្នាំ២០១៣ http://bit.ly/1XntSBe

ភ្ញាក់ផ្អើលទេ ដែលមានរបាយការណ៍ជាច្រើនបានលើកឡើងអំពីសហគមន៍ជនជាតិដើមភាគតិចដែលទទួលរង ការគាបសង្កត់ឲ្យទទួលយកកម្មសិទ្ធិដីឯកជន។[68] នេះជាក្តីបារម្ភដ៏ខ្លាំងមួយ ដោយសារថាតាមច្បាប់កម្ពុជា នៅពេលដែលពួកគាត់បានទទួលកម្មសិទ្ធិដីឯកជនហើយ ជនជាតិដើមភាគតិចទាំងនោះលែងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានកម្មសិទ្ធិដីសមូហភាពទៀតហើយ។[69] ជាលទ្ធផល គ្រួសារជនជាតិដើមភាគតិចណាមួយដែលបានទទួលយកកម្មសិទ្ធិដីឯកជន នឹងត្រូវតែដកចេញពីប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ ហើយដីរបស់ពួកគេក៏ដូច្នោះដែរ។

ដូច្នេះ ទោះបីជាតាមទ្រឹស្តី ក្របខណ្ឌច្បាប់ក្នុងប្រទេសកម្ពុជាការពារសិទ្ធិដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិចក៏ដោយក្តី ក៏នៅក្នុងការអនុវត្តជាក់ស្តែង ពួកគេត្រូវបានទុកចោលដោយគ្មានការការពារ ដែលជាហេតុធ្វើឲ្យពួកគេងាយរងគ្រោះទាំងស្រុងដោយសារការចាប់ដីនិងការរំលោភបំពានផ្សេងៗដែលពាក់ព័ន្ធ។

[68] *ដដែល*
[69] *ដដែល*

# ៣. គោលបំណង វិសាលភាព និងវិធីសាស្ត្រ

## ៣.១. គោលបំណងនៃការស្រាវជ្រាវ

របាយការណ៍នេះផលិតឡើងបន្ទាប់ពីការចេញផ្សាយប្រវត្តិមួយចំនួននៅក្នុង *កម្រងប្រវត្តិសកម្មជនដីធ្លី*[70]របស់ ម.ស.ម.ក ដែលផ្ដោតលើសហគមន៍ជនជាតិដើមភាគតិចដែលទទួលរងការប៉ះពាល់ដោយជម្លោះដីធ្លីជាច្រើននៅក្នុងប្រទេស។ បន្ថែមពីលើប្រវត្តិមួយចំនួននៅក្នុងកម្រងប្រវត្តិសកម្មជននោះ របាយការណ៍នេះបំពេញបន្ថែមទៅលើលទ្ធផលនៃការពិភាក្សាតុមូលរបស់ ម.ស.ម.ក ស្ដីពី *"ដីធ្លីនិងសិទ្ធិជនជាតិដើមភាគតិច"*[71] ដែលបានរៀបចំឡើងក្នុងឆ្នាំ២០១៣ ក្នុងចំណោមអ្នកតំណាងសហគមន៍ជនជាតិដើមភាគតិច សង្គមស៊ីវិល និងអាជ្ញាធរមូលដ្ឋាន ហើយរបាយការណ៍ឆ្នាំ២០១៣ របស់ ម.ស.ម.ក មានចំណងជើងថា *"កម្ពុជា៖ ដីជម្លោះ ទិដ្ឋភាពទូទៅនៃស្ថានភាពដីធ្លី"*។[72]

របាយការណ៍នេះផ្ដោតជាពិសេសទៅលើបញ្ហារបស់សហគមន៍ជនជាតិដើមភាគតិចដែលបានជួបប្រទះក្នុងកិច្ចប្រឹងប្រែងការពារដីសហគមន៍របស់ខ្លួនតាមរយៈការប៉ុនប៉ងចុះបញ្ជីដី ដើម្បីទទួលប័ណ្ណកម្មសិទ្ធិដីសមូហភាព។ មូលហេតុនៃការសិក្សាស្រាវជ្រាវនេះគឺផ្អែកទៅលើកការទទួលស្គាល់ថា បញ្ហាទាំងឡាយទាក់ទងនឹងការទទួលបានកម្មសិទ្ធិដីស្របច្បាប់ គឺជាបញ្ហាដ៏លំបាកមួយក្នុងចំណោមបញ្ហាលំបាកខ្លាំងជាច្រើន ដែលក្រុមងាយរងគ្រោះកំពុងប្រឈមមុខ ជាពិសេសសហគមន៍ជនជាតិដើមភាគតិច ដូចដែលមានបង្ហាញជាកស្ដុតាងនៅក្នុង *កម្រងប្រវត្តិសកម្មជនដីធ្លី* របស់ ម.ស.ម.ក និងការពិភាក្សាតុមូលស្ដីពី *"ដីនិងសិទ្ធិជនជាតិដើមភាគតិច"*។

របាយការណ៍នេះមានគោលបំណងបង្ហាញទិន្នន័យដែលប្រមូលបានមកពីការស្រាវជ្រាវរបស់គម្រោងអំពីឧបសគ្គដែលសហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជាប្រឈម នៅពេលស្វែងរកសន្តិសុខក្នុងការកាន់កាប់ដីធ្លី តាមរយៈការដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព។ គម្រោងសង្ឃឹមថាតាមរយៈការរំលេចនូវហេតុផលនៃភាពចម្លោះប្រហោងក្នុងការអនុវត្តដំណើរការចុះបញ្ជីកម្មសិទ្ធិដីសមូហភាពនិងការរកឃើញនូវអនុសាសន៍ទាំងឡាយ របាយការណ៍នេះនឹងលើកកម្ពស់ការអនុវត្តកាន់តែប្រសើរទៅលើការចុះបញ្ជីដីសមូហភាពនិងការការពារសិទ្ធិដីធ្លីជនជាតិដើមភាគតិច ក្នុងចំណោមភាគីពាក់ព័ន្ធទាំងឡាយ។

## ៣.២ វិធីសាស្ត្រ

ការស្រាវជ្រាវនេះត្រូវបានធ្វើឡើងដោយប្រើទាំងទិន្នន័យដើមនិងទិន្នន័យបន្ទាប់បន្សំដើម្បីប្រមូលព័ត៌មានអំពីការលំបាកដែលសហគមន៍ជនជាតិដើមភាគតិចជួបប្រទះ ក្នុងការប៉ុនប៉ងការពារដីរបស់ពួកគេ។

---

[70] ម.ស.ម.ក "ប្រវត្តិសកម្មជនដីធ្លី" (ខែកញ្ញា ឆ្នាំ២០១៥) http://bit.ly/21b6V96

[71] ម.ស.ម.ក "មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជារៀបចំកិច្ចពិភាក្សាតុមូលស្ដីពីដីនិងសិទ្ធិជនជាតិដើមភាគតិច" (ប្រកាសព័ត៌មាន) (ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៣) http://bit.ly/1QWvIJE

[72] ស.ម.ម.ក "កម្ពុជា៖ ដីទំនាស់ ទិដ្ឋភាពទូទៅនៃស្ថានភាពដីធ្លី" (របាយការណ៍) (ខែធ្នូ ឆ្នាំ២០១៣) http://bit.ly/1KtPNVy

ការស្រាវជ្រាវទៅលើឯកសារជាច្រើនទាំងជាភាសាខ្មែរនិងភាសាអង់គ្លេសធ្វើឡើងដោយផ្អែកលើការស្រាវជ្រាវមុនរបស់គម្រោង និងត្រូវបានធ្វើឡើងតាមរយៈការវិភាគច្បាប់ជាមូលដ្ឋាននិងរចនាសម្ព័ន្ធច្បាប់ដែលកំណត់អំពីច្បាប់ដីធ្លីកម្ពុជា និងផ្តល់ការការពារដល់សិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច ការពិនិត្យឡើងវិញទៅលើឯកសារនិងការស្រាវជ្រាវពីភ្នាក់ងារនិងស្ថាប័នពាក់ព័ន្ធ ព្រមទាំងពិនិត្យឡើងវិញទៅលើរបាយការណ៍របស់អង្គការសង្គមស៊ីវិលក្នុងស្រុកនិងអន្តរជាតិដែលកំពុងធ្វើការលើបញ្ហានានាទាក់ទងនឹងដីធ្លី។ ប្រធានក្រុមប្រឹក្សាភិបាលរបស់ ម.ស.ម.ក ដែលជាជនជាតិដើមព្នងក៏ផ្តល់នូវយោបល់ស៊ីជម្រៅសម្រាប់របាយការណ៍នេះ និងជួយជ្រោមជ្រែងក្នុងគម្រោងការស្រាវជ្រាវនេះ។

ការស្រាវជ្រាវទិន្នន័យដើម តាមទម្រង់ការសម្ភាសពាក់កណ្តាលរចនាសម្ព័ន្ធត្រូវបានធ្វើឡើងនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៥ នៅក្នុងសហគមន៍ជនជាតិដើមភាគតិចចំនួន៥ ទូទាំងប្រទេស (សូមមើលរូបទី៣៖ ផែនទីទីតាំងស្រាវជ្រាវទិន្នន័យដើម)។ សហគមន៍ដែលមិនទាន់បានទទួលប័ណ្ណកម្មសិទ្ធិដីធ្លី ត្រូវបានកំណត់ដោយផ្អែកទៅលើការស្រាវជ្រាវពីមុនដែលអនុវត្តដោយគម្រោង។ ជាសរុប តំណាងសហគមន៍ចំនួន ៣៩ (ស្ត្រី ១៨) ត្រូវបានសម្ភាសសម្រាប់ការស្រាវជ្រាវនេះ ដោយក្នុងនោះ ៩ នាក់មកពីសហគមន៍ព្នងនៅភូមិចឹង ឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ ("ភូមិចឹង") ៨នាក់មកពីសហគមន៍ព្នងនៅភូមិចក់ចារ ស្រុកកែវសីមា ខេត្តមណ្ឌលគីរី ("ភូមិចក់ចារ") ៩ នាក់មកពីសហគមន៍ព្នងនៅឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ("ឃុំប៊ូស្រា") ៧នាក់មកពីសហគមន៍ព្នង[73]នៅភូមិក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង ("ភូមិក្បាលរមាស") និងចុងក្រោយ ៦ នាក់មកពីសហគមន៍ជនជាតិជងនៅភូមិជំនាប់ ស្ទឹងអារ៉ែង ស្រុកថ្មបាំង ខេត្តកោះកុង ("ស្ទឹងអារ៉ែង")។ សំណួរសម្ភាសផ្តោតលើសារៈសំខាន់នៃដីរបស់សហគមន៍ជនជាតិដើមភាគតិច ការប៉ះពាល់នៃវិវាទដីធ្លីទៅលើជីវភាពរស់នៅនិងអត្តសញ្ញាណ ការរើសអើងនិងការរំលោភបំពានសិទ្ធិមនុស្សដែលទទួលរងក្រោមដៃរបស់អាជ្ញាធរនិងក្រុមហ៊ុនដែលមានការពាក់ព័ន្ធក្នុងវិវាទ ការយល់ដឹងក្នុងចំណោមសហគមន៍អំពីច្បាប់ដីធ្លីកម្ពុជានិងសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច ការយល់ដឹងអំពីដំណើរការក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព និងការលំបាកដែលបានជួបប្រទះនៅពេលស្វែងរកកម្មសិទ្ធិដីធ្លី។

[73] សូមកត់សម្គាល់ថា ព្នង និងបូនង សំដៅទៅលើក្រុមជនជាតិដើមភាគតិចតែមួយ និងត្រូវបានក្រសួងអភិវឌ្ឍន៍ជនជនសំដៅទៅលើ "ព្នង"។ ម.ស.ម.ក ប្រើប្រាស់ឈ្មោះដែលកំណត់ដោយសហគម៍ជនជាតិដើមភាគតិច។

*រូបទី២៖ ផែនទីទីតាំងស្រាវជ្រាវទិន្នន័យដើម*




បន្ថែមពីលើនេះ ការសម្ភាសត្រូវបានធ្វើឡើងនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៥ ជាមួយនឹងមន្ត្រី រដ្ឋាភិបាលនៅតាមមូលដ្ឋានដែលមានការពាក់ព័ន្ធចំនួន ៨ នាក់ ក្នុងនោះមានស្ត្រីពីរនាក់រួមមានមេឃុំ សមាជិកក្រុមប្រឹក្សាឃុំ និងតំណាងម្នាក់មកពីរដ្ឋបាលព្រៃឈើ ព្រមទាំងតំណាង ៦ នាក់មកពីសង្គមស៊ីវិលធ្វើការជាមួយសហគមន៍ជនជាតិដើមភាគតិចដែល ម.ស.ម.ក ដែលបានកំណត់យក រួមមានអង្គការអាដហុក មជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍ អង្គការសង្គមអភិរក្សសត្វព្រៃ អង្គការភូមិខ្ញុំ និងអង្គការមាតាធម្មជាតិ។ ក្នុងខែមករា ឆ្នាំ២០១៦ ម.ស.ម.ក ក៏បានជួបជាមួយមន្ត្រីរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ពាក់ព័ន្ធនឹងព័ត៌មានដែលមានក្នុងរបាយការណ៍នេះផងដែរ។

## ៣.៣ វិសាលភាពនិងដែនកំណត់នៃការស្រាវជ្រាវ

ដោយសារតែបញ្ហាពេលវេលានិងធនធានមានកម្រិត គម្រោងសម្រេចផ្តោតការស្រាវជ្រាវនេះទៅលើសហគមន៍ជនជាតិដើមភាគតិចចំនួន ៥ ដែលគម្រោងបានទទួលព័ត៌មានពីការស្រាវជ្រាវមុនៗរួចហើយ។ ការធ្វើបែបនេះ មិនត្រឹមតែសន្សំពេលវេលានិងធនធានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងស្របជាមួយនឹងជំនឿរបស់ ម.ស.ម.ក ក្នុងការតាមដានបន្តជាមួយសហគមន៍និងបន្តតាមដានករណីរបស់ពួកគេផងដែរ។ ខណៈដែលបញ្ហាទាំងនោះ មានន័យថាក្រុមការងារគម្រោងមិនអាចប្រមូលទិន្នន័យពីសហគមន៍ជនជាតិដើមភាគតិចពីគ្រប់កន្លែងក្នុងប្រទេសឡើយ យើងសង្ឃឹមថាសហគមន៍ទាំងប្រាំដែលត្រូវបានជ្រើសរើសនោះ តំណាងឲ្យទំហំសមល្មមមួយ

ក្នុងការទាញយកការវិភាគសម្រាប់ជាគំរូមួយតាងឲ្យទូទាំងប្រទេសបាន។ បន្ថែមលើនេះ យើងសង្ឃឹមថា លទ្ធផលនៃការស្រាវជ្រាវនេះផ្តល់មូលដ្ឋានសម្រាប់ការសិក្សាកាន់តែទូលំទូលាយក្នុងអនាគតខាងមុខ។

# ៤. ឧបសគ្គក្នុងការចុះបញ្ជីដីសម្ជហភាព

## ៤.១ ដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសម្ជហភាព

មានបញ្ហាមួយចំនួននៅក្នុងដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសម្ជហភាពនេះផ្ទាល់ដែលរារាំងសហគមន៍ជនជាតិដើមភាគតិចក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដីសម្ជហភាព។ ភាពស្មុគ្រស្មាញនៃដំណើរការនេះ និងកង្វះខាតព័ត៌មានបាននាំឲ្យមានកង្វះខាតការយល់ដឹងជាទូទៅមួយអំពីដំណើរការនេះក្នុងចំណោមសមាជិកសហគមន៍និងសូម្បីតែក្នុងចំណោមអាជ្ញាធរមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាល។ នៅពេលដែលសហគមន៍ និងអ្នកដែលត្រូវជ្រោមជ្រែងគាត់មិនបានយល់ដឹងអំពីដំណើរការនេះ ការទទួលបានប័ណ្ណកម្មសិទ្ធិដីសម្ជហភាពនៅតែជាបញ្ហាប្រឈម។ ជាងនេះទៀត សហគមន៍ខ្វះធនធានដើម្បីបំពេញតាមជំហានជាច្រើនពាក់ព័ន្ធនឹងដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសម្ជហភាពនេះ និងក្នុងការចំណាយពាក់ព័ន្ធផ្សេងៗក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដីសម្ជហភាពនេះ។ កត្តាទាំងអស់នេះហើយដែលទាមទាឲ្យការគាំទ្រពីខាងក្រៅដើម្បីឲ្យសហគមន៍មួយអាចចូលរួមដោយប្រសិទ្ធភាពក្នុងដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសម្ជហភាព។ ជំពូកនេះនឹងពន្យល់លម្អិតបន្ថែមទៀតទៅលើបញ្ហាទាំងនេះជាមួយនឹងដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសម្ជហភាព ព្រមទាំងបង្ហាញអំពីឧបសគ្គក្នុងការចុះបញ្ជីដីធ្លីសម្រាប់សហគមន៍ជនជាតិដើមភាគតិច។

### ៤.១.១ កង្វះខាតការយល់ដឹងអំពីដំណើរការនេះក្នុងចំណោមសហគមន៍

សមាជិកសហគមន៍ទាំងអស់ដែលត្រូវបានសម្ភាសបានយល់ដឹងអំពីបញ្ញត្តិនៃប័ណ្ណកម្មសិទ្ធិដីសម្ជហភាព ដោយភាគច្រើនពួកគាត់បានទទួលចំណេះដឹងនេះតាមរយៈការចូលរួមការបណ្តុះបណ្តាលដែលបានផ្តល់ដោយអង្គការសង្គមស៊ីវិលផ្សេងៗគ្នា ឬតាមរយៈការផ្សព្វផ្សាយព័ត៌មានពីតំណាងសហគមន៍ទាំងនោះដែលបានចូលរួមក្នុងការបណ្តុះបណ្តាល។ ជាងនេះទៀត មានការស្តាប់វិទ្យុ និងការអានសារព័ត៌មានខ្លះៗគឺជាប្រភពព័ត៌មានដែលបានបង្កើនចំណេះដឹងរបស់សហគមន៍អំពីប័ណ្ណកម្មសិទ្ធិដីសម្ជហភាព។ ក៏ប៉ុន្តែ អ្នកចូលរួមភាគច្រើនបានទទួលស្គាល់ថាខ្លួនខ្វះខាតការយល់ដឹងអំពីដំណើរការបែបណាក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដីសម្ជហភាព។ តំណាងសហគមន៍ម្នាក់មកពីស្ទឹងអារ៉ែងបានថ្លែងថា *"យើងមិនមានចំណេះផ្នែកច្បាប់ទេ វាស្មុគ្រស្មាញណាស់។ ដូច្នេះហើយបានជាដំណើរការនេះនៅជាប់គាំង"*។ នៅក្នុងភូមិចក់ចារក្នុងអំឡុងពេលសម្ភាសន៍ សហគមន៍បានស្នើឲ្យ ម.ស.ម.ក ពន្យល់ពួកគេអំពីភាពខុសគ្នារវាងប័ណ្ណកម្មសិទ្ធិដីសម្ជហភាពនិងប័ណ្ណកម្មសិទ្ធិដីឯកជន ដែលនេះអាចបញ្ជាក់អំពីកង្វះខាតការយល់ដឹងលម្អិតអំពីភាពខុសគ្នារវាងប្រភេទប័ណ្ណកម្មសិទ្ធិដីទាំងពីរប្រភេទនេះ។ ស្រដៀងគ្នានេះដែរ នៅស្ទឹងអារ៉ែង សហគមន៍បានស្នើឲ្យ ម.ស.ម.ក ផ្តល់ព័ត៌មានបន្ថែមអំពីដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសម្ជហភាពនេះ។

បន្ថែមពីលើនេះ សូមបញ្ជាក់ថាបុគ្គលដែលត្រូវបានសម្ភាសក្នុងការស្រាវជ្រាវនេះ រួមមានតំណាងសហគមន៍និងសកម្មជនសុទ្ធតែជាសមាជិកសហគមន៍ដែលទំនងជាមានចំណេះដឹងអំពីដំណើរការទទួលបានប័ណ្ណ

កម្មសិទ្ធិដីសមូហភាពក្នុងសហគមន៍របស់ខ្លួន។ ដូច្នេះ នេះជាហេតុផលសមល្មមក្នុងការសន្មតថាកម្រិតយល់ដឹងជាទូទៅអំពីនីតិវិធីទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពក្នុងចំណោមសមាជិកសហគមន៍ទាំងមូលអាចនឹងមានកម្រិតទាបជាងនេះខ្លាំង។ វាច្បាស់ណាស់ដែលថាប្រសិនបើគ្មានជំនួយពីអង្គការសង្គមស៊ីវិលទេ សហគមន៍ទាំងនេះនឹងមិនអាចចាប់ផ្តើមដំណើរការចុះបញ្ជីដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនោះទេ ដោយសារតែពួកគេខ្វះខាតចំណេះដឹងអំពីអ្វីដែលមានការពាក់ព័ន្ធនឹងដំណើរការនោះ។ អ្នកតំណាងម្នាក់មកពីអង្គការសង្គមអភិរក្សសត្វព្រៃគិតថា "[សហគមន៍] *មិនមានសមត្ថភាពទេ ដូច្នេះពួកគាត់ត្រូវពឹងលើជំនួយរបស់ពួកយើង និងរបស់ដៃគូផ្សេងទៀត។ វាជាការពិបាកណាស់សម្រាប់ពួកគេក្នុងដំណើរការចុះបញ្ជីដោយខ្លួនឯងនោះ*"។

## ៤.១.២ កង្វះខាតការយល់ដឹងអំពីដំណើរការនេះក្នុងចំណោមអាជ្ញាធរមូលដ្ឋាន

សូម្បីតែក្នុងចំណោមអាជ្ញាធរមូលដ្ឋានក៏មានការខ្វះខាតចំណេះដឹងនេះឬមានការយល់ច្រឡំអំពីដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះខ្លាំងដែរ។ ឧទាហរណ៍នៅស្ទឹងអារ៉ែង សហគមន៍បានលើកឡើងថា "*សូម្បីតែអាជ្ញាធរឃុំក៏មិនបានដឹងអំពីសិទ្ធិរបស់ជនជាតិដើមភាគតិចនិងដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពដែរ*" ដែលនេះបង្ហាញពីតម្រូវការឲ្យរដ្ឋាភិបាល "*ពង្រឹងសមត្ថភាពរបស់អាជ្ញាធរមូលដ្ឋាននិងអប់រំពួកគេអំពីសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច*"។ តំណាងអង្គការសង្គមស៊ីវិលបានបញ្ជាក់ថាកង្វះខាតចំណេះដឹងជាទូទៅក្នុងចំណោមអាជ្ញាធរថ្នាក់ក្រោមដូចដែលតំណាងអង្គការសង្គមស៊ីវិលរូបនេះថ្លែងថា "*អាជ្ញាធរនៅថ្នាក់ក្រោមជាតិមានការយល់ដឹងតិចតួចអំពីដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព*"។

ជាងនេះទៀត អាជ្ញាធរមូលដ្ឋានខ្លួនឯងបានសារភាពអំពីការខ្វះខាតការយល់ដឹងក្នុងវិស័យនេះ។ នៅក្នុងក្រុមប្រឹក្សាឃុំឃ្សឹម ដែលមានអំណាចទៅលើភូមិចឹង មិនមានមេឃុំឬសមាជិកក្រុមប្រឹក្សាណាមួយដែលមានវត្តមាននៅក្នុងពេលសម្ភាសនោះដឹងអំពីដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនោះទេ។ មេឃុំថ្លែងថា "*ខ្ញុំមិនបានដឹងអំពីដំណើរការចុះបញ្ជីដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពទេ ... រដ្ឋាភិបាលមិនដែលបានផ្តល់ព័ត៌មានឬការបណ្តុះបណ្តាលណាមួយអំពីរបៀបជួយជនជាតិដើមភាគតិចជាមួយនឹងដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះទេ។*" នៅក្នុងតំបន់មួយចំនួន អង្គការសង្គមស៊ីវិលកំពុងផ្តល់ការបណ្តុះបណ្តាលដើម្បីបំពេញគម្លាតដែលរដ្ឋាភិបាលខកខានមិនបានផ្តល់ដល់អាជ្ញាធរមូលដ្ឋានអំពីចំណេះដឹងនេះ។ នៅក្នុងឃុំប៊ូស្រា សមាជិកក្រុមប្រឹក្សាឃុំម្នាក់បានលាតត្រដាងថា "*ពីមុនខ្ញុំមិនបានដឹងអំពីរបៀបទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពទេ ហូតដល់ពេលដែលមជ្ឈមណ្ឌលច្បាប់សម្រាប់សហគមន៍មកពិភាក្សាអំពីសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច*"។ ក៏ប៉ុន្តែ សូម្បីតែអង្គការសង្គមស៊ីវិលដែលប៉ុនប៉ងបំពេញគម្លាតនេះ ក៏សមត្ថភាពរបស់ពួកគេក្នុងការបណ្តុះបណ្តាលអាជ្ញាធរមូលដ្ឋាននៅមានកម្រិតទាបនៅឡើយ។ សមាជិកក្រុមប្រឹក្សាឃុំដដែលបានបន្ថែមថា "*ទោះបីជាខ្ញុំបានចូលរួមក្នុងការបណ្តុះបណ្តាលក៏ដោយក៏ខ្ញុំនៅតែមិនទាន់ដឹងសព្វគ្រប់នៅឡើយទេ*"។

នៅពេលដែលក្រុមប្រឹក្សាឃុំនៅក្នុងតំបន់ជនជាតិដើមភាគតិចខ្វះខាតចំណេះដឹងអំពីដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនោះ ពួកគេមិនអាចមានលទ្ធភាពក្នុងការបំពេញអាណត្តិការងាររបស់ខ្លួនដើម្បីតំណាងឲ្យពលរដ្ឋនៅក្នុងសហគមន៍របស់ពួកគេ និងបម្រើផលប្រយោជន៍ទូទៅរបស់ពលរដ្ឋបាន ដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់[74]បានទេ។ លទ្ធផលនៃការស្រាវជ្រាវនេះបានបង្ហាញប្រាកដណាស់ថា អាជ្ញាធរមូលដ្ឋានត្រូវទទួលបានការផ្តល់ព័ត៌មានឲ្យបានពេញលេញអំពីដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះពិតជាមានសារៈសំខាន់ណាស់ ប៉ុន្តែ គួរឲ្យសោកស្តាយដែលនៅក្នុងតំបន់ខ្លះ វាហួសពេលបាត់ទៅហើយ។ នៅក្នុងឃុំឃ្សឹម ក្រុមប្រឹក្សាឃុំបានថ្លែងថាខ្លួន *"ស្វាគមន៍អង្គការមិនមែនរដ្ឋាភិបាលក្នុងការផ្តល់ការបណ្តុះបណ្តាលអំពីដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពសម្រាប់ជនជាតិដើមភាគតិច ប៉ុន្តែឥឡូវនេះហួសពេលបាត់ទៅហើយ ដោយសារតែនៅទីនេះមិនមានសល់ដីសម្រាប់ជនជាតិដើមភាគតិចទៀតទេ។ អ្វីគ្រប់យ៉ាងហួសពេលអស់ហើយ ប្រសិនបើអាជ្ញាធរចង់ជួយជនជាតិដើមភាគតិច ក៏វាជាការឥតប្រយោជន៍ដែរ ពីព្រោះឥឡូវនេះគ្មានដីសម្រាប់ពួកគេទេ"*។

## ៤.១.៣ ការចំណាយពាក់ព័ន្ធ

ការចំណាយច្រើនពាក់ព័ន្ធក្នុងដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះត្រូវបានលាតត្រដាងថាគឺជាឧបសគ្គមួយក្នុងចំណោមឧបសគ្គធំៗបំផុតដែលសហគមន៍ត្រូវជម្នះឲ្យបានដើម្បីចុះបញ្ជីដីរបស់ពួកគេ។ ឧទាហរណ៍ ដំណាក់កាលដំបូងនៃដំណើរការនេះ គឺការទទួលស្គាល់អត្តសញ្ញាណជាមួយនឹងក្រសួងអភិវឌ្ឍន៍ជនបទត្រូវបានគេប៉ាន់ប្រមាណថាត្រូវចំណាយចន្លោះពី ១០.០០០ ទៅ ២០.០០០ ដុល្លាអាមេរិច។[75] ការចំណាយដ៏ច្រើនសម្បើមនេះ សម្រាប់ចំណាយទៅលើការធ្វើដំណើររបស់ក្រសួងអភិវឌ្ឍន៍ជនបទទៅកាន់សហគមន៍ ការស្នាក់នៅ សោហ៊ុយចំណាយ និងការចំណាយផ្សេងៗទៀតដែលពាក់ព័ន្ធនឹងដំណើរការនេះ។ ប្រសិនបើគ្មានជំនួយពីខាងក្រៅទេ វាជាការពិបាកយល់ណាស់ថាតើសហគមន៍ជនជាតិដើមភាគតិចនិងសង្គមស៊ីវិលនៅតាមមូលដ្ឋានត្រូវធ្វើយ៉ាងដូចម្តេចដើម្បីអាចរ៉ាប់រងទៅលើចំណាយដ៏ច្រើនសន្ធឹកសន្ធាប់ដែលពាក់ព័ន្ធនឹងដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះបាន។

សមាជិកក្រុមប្រឹក្សាឃុំប៊ូស្រាម្នាក់ដែលជាជនជាតិដើមភាគតិចផ្ទាល់ ហើយបានចូលរួមនៅក្នុងដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពជាមួយសហគមន៍ដែរបានពន្យល់ថា *"ការលំបាកចម្បងគឺថាយើងមិនមានលុយគ្រប់គ្រាន់សម្រាប់ដំណើរការចុះបញ្ជីទេ្បមមានការវាស់វែងដីធ្លី ការដាក់ពាក្យ ហើយអ្វីៗសព្វបែបយ៉ាងត្រូវការលុយ លើកលែងតែនៅពេលមានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល"*។ អាជ្ញាធរមូលដ្ឋានមិនមាន

---

[74] ម.ស.ម.ក ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ (សលាកប័ត្រព័ត៌មាន ម.ស.ម.ក)(ខែមិថុនា ឆ្នាំ២០១២) http://bit.ly/1QvgfiZ

[75] ការប៉ាន់ប្រមាណចេញមកពីអង្គការសង្គមស៊ីវិលនិងដៃគូអភិវឌ្ឍន៍ដែលកំពុងធ្វើការលើវិស័យកម្មសិទ្ធិដីធ្លីសហគមន៍ដែលពួកគេទទួលបានពីក្រសួងអភិវឌ្ឍន៍ជនបទ

សមត្ថភាពផ្នែកហិរញ្ញវត្ថុដើម្បីជួយក្នុងការងារនេះទេ។ មេឃុំឃ្សឹម បានពណ៌នាអំពីឧបសគ្គផ្នែកហិរញ្ញវត្ថុរបស់អាជ្ញាធរមូលដ្ឋានថា *"ប្រសិនបើមិនមានជំនួយហិរញ្ញវត្ថុពីអង្គការពាក់ព័ន្ធទេ ក្រុមប្រឹក្សាឃុំមិនអាចដំណើរការចុះបញ្ជីបានទេ ដោយសារតែថវិកាមានកំណត់... រដ្ឋាភិបាលមិនដែលបានផ្តល់ថវិកាអ្វីសម្រាប់ការងារនេះទេ"*។ តំណាងមកពីអង្គការអភិរក្សសត្វព្រៃក៏បានសង្កត់ធ្ងន់អំពីការចំណាយពាក់ព័ន្ធ រួមជាមួយនឹងកង្វះខាតលុយថា *"ឧបសគ្គទីមួយគឺការចំណាយ។ សម្រាប់អ្វីៗគ្រប់បែបយ៉ាង សូម្បីតែដំណើរការចុះបញ្ជី ការកំណត់ព្រំ ការប្រជុំ ការដំណើរការនៅក្នុងក្រសួងពាក់ព័ន្ធតែងតែត្រូវការលុយ។ សហគមន៍មិនមានលុយផ្ទាល់ខ្លួនទេដូច្នេះសហគមន៍ត្រូវពឹងផ្អែកលើជំនួយពីគម្រោងដើម្បីគាំទ្រពួកគេ"*។ ក៏ប៉ុន្តែការចំណាយពាក់ព័ន្ធទាំងនេះក៏អាចជាឧបសគ្គចំពោះជំនួយពីក្រៅផងដែរ ហើយក៏មានករណីមួយចំនួនដែលអង្គការកំពុងជួយសហគមន៍ជនជាតិដើមភាគតិចនៅក្នុងដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះត្រូវបានបង្ខំឲ្យបញ្ឈប់ការគាំទ្រដោយសារតែបញ្ហាថវិកានេះគឺត្រូវចាកចេញចោលសហគមន៍ដែលគ្មានមធ្យោបាយសម្រាប់ការពារដីរបស់ពួកគេ។ ឧទាហរណ៍នៅស្ទឹងអារ៉ែង សហគមន៍ជនជាតិដើមភាគតិចបានចាប់ផ្តើមទទួលជំនួយសម្រាប់ដំណាក់កាលដំបូងដើម្បីដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនៅដើមឆ្នាំ២០១៤ ពីក្រុមមេធាវីសិទ្ធិដែលជាក្រុមមេធាវីមួយនៅកម្ពុជាផ្តល់ជំនួយមិនយកកម្រៃ ប៉ុន្តែ បើយោងតាមការលើកឡើងរបស់សហគមន៍ *"ឥឡូវនេះក្រុមមេធាវីសិទ្ធិនិយាយថា ពួកគេមិនមានមូលនិធិគ្រប់គ្រាន់សម្រាប់គាំទ្រដល់ដំណើរការទទួលស្គាល់អត្តសញ្ញាណទេ"*។

យោងតាមក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ថារដ្ឋាភិបាលបានចាត់ចែងថវិកាចំនួន ៣០០.០០០ ដុល្លាសហរដ្ឋអាមេរិក ក្នុងមួយឆ្នាំសម្រាប់ការចុះបញ្ជីដីសមូហភាពដែលបានគ្រោងធ្វើឲ្យបាន១០ សហគមន៍ក្នុងមួយឆ្នាំក្នុងដំណាក់កាលចុងក្រោយនេះ ហើយពុំបានតម្រូវឲ្យសហគមន៍ចេញថវិកាក្នុងដំណើរការនេះទេ។ មន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនអាចផ្តល់យោបល់អ្វីដែលពាក់ព័ន្ធនឹងការចំណាយក្នុងដំណើរការការងារជាមួយក្រសួងអភិវឌ្ឍន៍ជនបទនិងក្រសួងមហាផ្ទៃឡើយ។

### ៤.១.៤ កង្វះខាតឆន្ទៈនយោបាយក្នុងការសម្រួលដំណើរការ

មិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលទេដែលបញ្ហាចម្បងមួយត្រូវបានលើកឡើងក្នុងការស្រាវជ្រាវនេះគឺកង្វះឆន្ទៈរបស់រដ្ឋាភិបាលក្នុងការផ្តល់ដល់សហគមន៍នៅក្នុងដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះ ទោះបីជាមានក្របខណ្ឌច្បាប់មួយជាធរមានសម្រាប់ការពារដីជនជាតិដើមភាគតិចក៏ដោយក្តី ក៏នៅក្នុងការអនុវត្តជាក់ស្តែងច្បាប់ទាំងនេះច្រើនតែមិនត្រូវបានគេអនុវត្តឡើយ។ នៅក្នុងឃុំប៊ូស្រា សមាជិកក្រុមប្រឹក្សាឃុំបានទទួលស្គាល់ថាទោះបីជារដ្ឋាភិបាលបានអនុម័តច្បាប់និងចេញអនុក្រឹត្យ ដើម្បីការពារសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិចក៏ដោយ តែតាមពិតទៅវាមិនមានផលអ្វីទេ ដោយគាត់បានថ្លែងថា *"រដ្ឋាភិបាលគ្រាន់តែមានច្បាប់ ប៉ុន្តែមិនបានអនុវត្តទេ។"* អាជ្ញាធរមូលដ្ឋានភាគច្រើន ដែលចូលនៅក្នុងការស្រាវជ្រាវនេះ បានគូសបញ្ជាក់ដដែលឡើងវិញអំពីអារម្មណ៍មួយនេះ។

ជាការពិតណាស់ នៅក្នុងសហគមន៍ជនជាតិដើមភាគតិច គេមិនសូវមានជំនឿចិត្តទៅលើរដ្ឋាភិបាលក្នុងការការពារដីធ្លីរបស់ពួកគេនោះទេ។ ឧទាហរណ៍ ក្នុងភូមិក្បាលរមាស នៅពេលសួរថាតើអ្វីទៅជាឧបសគ្គចម្បងក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនោះ សមាជិកឃុំម្នាក់សន្និដ្ឋានថា *"ការលំបាកចម្បងគឺរដ្ឋាភិបាល។ ពួកគេជាអ្នកផ្តល់សម្បទាន។ ពួកគេទប់ស្កាត់ការចុះបញ្ជីដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់យើង។ គ្មានអ្នកណាផ្សេងទៀតទេ។"* តាមពិតទៅ នៅពេលដែលរដ្ឋាភិបាលអនុញ្ញាតឲ្យអ្នកទទួលផលពីសម្បទានដីសេដ្ឋកិច្ចទន្ទ្រានលើដីសហគមន៍ជនជាតិដើមភាគតិច និងអនុម័តឲ្យមានគម្រោងអភិវឌ្ឍដែលប៉ះពាល់លើតំបន់ជនជាតិដើមភាគតិចហើយនោះ កង្វះការព្រួយបារម្ភក្នុងការការពារដីជនជាតិដើមភាគតិចបានបង្ហាញឡើងយ៉ាងច្បាស់ក្រឡែត។

ចំណុចដែលកើតឡើងយ៉ាងញឹកញយដែលបានបង្ហាញនៅក្នុងការស្រាវជ្រាវនេះគឺកង្វះដំណោះស្រាយនយោបាយនៅក្នុងដំណាក់កាលផ្សេងៗគ្នានៃដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះដែលទីបំផុតធ្វើឲ្យដំណើរការត្រូវជាប់គាំង។ សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ក្នុងឃុំប៊ូស្រាបានកត់សម្គាល់ថា *"រដ្ឋាភិបាលកម្រិតនីមួយៗ និយាយថាពួកគេមិនមានសមត្ថកិច្ចដោះស្រាយស្ថានភាពនោះទេ ហើយឲ្យទៅកេថ្នាក់លើ។ វាគ្រាន់តែជាការបញ្ជូនទៅបញ្ជូនមកតែប៉ុណ្ណោះ"*។ នេះជាអារម្មណ៍ដែលត្រូវបានសង្កត់ធ្ងន់សារជាថ្មីម្តងទៀតដោយជំទប់ទីមួយឃុំស្រែឈូក នៅក្នុងភូមិចក់ចារ ដែលបានលាតត្រដាងថា *"បញ្ហាគឺថាអាជ្ញាធរមានសមត្ថកិច្ចមិនបានយកចិត្តទុកដាក់ច្រើនក្នុងការពន្លឿនដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះទេ"*។ តំណាងមកពីអង្គការសង្គមអភិរក្សសត្វព្រៃបានពណ៌នាស្ថានភាពនេះថា *"ជួនកាលមនុស្សនៅក្នុងស្ថាប័នពាក់ព័ន្ធមិនបានយកចិត្តទុកដាក់តាមតួនាទីក្នុងការពន្លឿនដំណើរការនេះទេ សូម្បីតែនៅពេលយើងដាក់ឯកសារក៏ដោយ ក៏អ្នកទាំងនោះព្រងើយកន្តើយនិងនៅស្ងាត់ស្ងៀម ដូច្នេះវាលំបាកណាស់។"*

បើយោងតាមអនុសញ្ញាពលកម្មអន្តរជាតិ ក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិចចំនួន ១៦៦ ដែលបានចាប់ផ្តើមដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនោះ មានសហគមន៍ចំនួន ១៤៤ ដែលបានបំពេញចប់សព្វគ្រប់នៅដំណាក់កាលទីមួយ ហើយនិងបានទទួលការទទួលស្គាល់អត្តសញ្ញាណពីក្រសួងអភិវឌ្ឍន៍ជនបទ។[76] ដោយសារតែសហគមន៍ជនជាតិដើមភាគតិចត្រូវតែបំពេញតាមដំណាក់កាលនីមួយៗនៃដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព មុននឹងឈានចូលក្នុងដំណាក់កាលបន្ទាប់មកទៀត ការពន្យារនៅក្នុងដំណាក់កាលដំបូង មុននឹងមានវិធានការការពារបណ្តោះអាសន្នគឺពិតជាសំខាន់ណាស់ មានន័យថាការពន្យារពេលដ៏វែងនេះដែលប៉ះពាល់យ៉ាងខ្លាំងសម្រាប់សហគមន៍ ដោយសារតែភាពងាយរងគ្រោះពីការចាប់ដី។ យោងតាមព័ត៌មានផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់នៅខែមករា ឆ្នាំ២០១៦ បាន

[76] តួលេខយោងតាមរបាយការណ៍របស់អង្គការពលកម្មអន្តរជាតិ "បញ្ជីបច្ចុប្បន្នភាពនៃវឌ្ឍនភាពប័ណ្ណកម្មសិទ្ធិដីសមូហភាពដែលគាំទ្រដោយ ILO GIZ និងអង្គការមិនមែនរដ្ឋាភិបាល និងគោលដៅដែលរងការប៉ះពាល់ដោយបទបញ្ជា០១ ពីឆ្នាំ២០១៣ ដល់ ថ្ងៃ១៣ ខែមករា ឆ្នាំ២០១៥។

បង្ហាញថាក្រសួងបានទទួលសំណុំបែបបទស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពមកពីសហគមន៍ចំនួនតែ ៤៣ ប៉ុណ្ណោះ ក្នុងនោះសហគមន៍ចំនួន ១១ បានប័ណ្ណកម្មសិទ្ធិដីសមូហភាពរួចរាល់ហើយ រីឯសហគមន៍ចំនួន ៩ ទៀតនឹងទទួលបាននៅក្នុងរដូវប្រាំង ឆ្នាំ២០១៦នេះ ។ នេះបង្ហាញបន្ថែមទៀតថាសហគមន៍ដែលប៉ុនប៉ងចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីសមូហភាពកំពុងស្ថិតក្នុងភាពរាំងស្ទះនៅដំណាក់កាលទទួលប័ណ្ណកម្មសិទ្ធិដីសមូហភាពនៅថ្នាក់ក្រោម។

តំណាងអង្គការសង្គមស៊ីវិលមួយរូបបានថ្លែងអំពីកង្វះខាតធន្ធនយោបាយក្នុងការសម្រួលដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះថា *"ក្រុមហ៊ុននានាទទួលបានសម្បទានដីភ្លាមៗពីរដ្ឋាភិបាលនៅពេលពួកគេដាក់សំណើប៉ុន្តែសម្រាប់សហគមន៍ជនជាតិដើមភាគតិចវិញដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពពួកគេត្រូវការចំណាយពេលយូរណាស់ទម្រាំទទួលបាន ដាក់ស្តែងសហគមន៍មួយចំណាយពេលជិតដប់ឆ្នាំដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះ"*។

## ៤.២ អាជ្ញាធរមូលដ្ឋាន

### ៤.២.១ កង្វះខាតការគាំទ្រ

ក្នុងឃុំប៊ូស្រា សហគមន៍បានប្រាប់ឲ្យដឹងថា អាជ្ញាធរមូលដ្ឋានមិនបានព្យាយាមជួយដល់ពួកគេក្នុងដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះទេដោយគាត់បានលើកឡើងថា *"អាជ្ញាធរមិនដែលគាំទ្រយើងទេ ប៉ុន្តែប្រសិនបើគាត់ប្តេជ្ញាចិត្តថាគាំទ្រយើង យើងនឹងទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពយ៉ាងឆាប់ដាក់ជាមិនខាន"*។ នៅភូមិចឹងដែលសហគមន៍ជនជាតិដើមភាគតិចត្រូវការការគាំទ្រខ្លាំងជាទីបំផុតក្នុងការការពារដីដែលនៅសេសសល់របស់ពួកគេនោះ សហគមន៍បានបាត់បង់ទំនុកចិត្តទាំងស្រុងទៅលើអាជ្ញាធរមូលដ្ឋានក្នុងការផ្តល់ការជួយជ្រោមជ្រែងដល់ពួកគេកន្លងមកគឺដោយសារតែខ្វះការគាំទ្រនេះ។ ដូចតំណាងសហគមន៍ម្នាក់បានថ្លែងថា *"អាជ្ញាធរមិនដែលគាំទ្រពួកយើងទេ ពួកគេច្រានចោលសំណើរបស់ពួកយើងក្នុងការជួយយើងចុះបញ្ជីជានីតិបុគ្គល"*។ កង្វះខាតការគាំទ្រយ៉ាងច្បាស់មួយពីអាជ្ញាធរមូលដ្ឋាន អាចត្រូវបានគេមើលឃើញនៅភូមិក្បាលរមាស ជាទីដែលសមាជិកក្រុមប្រឹក្សាឃុំដែលមានទឹកចិត្តអាណិតអាសូរម្នាក់ បានរកឃើញនូវកង្វះការប្តេជ្ញាចិត្តពីអាជ្ញាធរមូលដ្ឋានក្នុងការគាំទ្រសហគមន៍ ថាជាឧបសគ្គដ៏ចម្បងមួយក្នុងដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះ។

**ករណីសិក្សាៈ កង្វះខាតការគាំទ្រពីអាជ្ញាធរមូលដ្ឋានសម្រាប់ជនជាតិដើមភាគតិចពួងនៅភូមិក្បាលរមាស**[77]

**ស្ថានភាពប័ណ្ណកម្មសិទ្ធិដីសមូហភាពៈ** កំពុងរង់ចាំការទទួលស្គាល់អត្តសញ្ញាណជាផ្លូវការពីក្រសួងអភិវឌ្ឍន៍ជនបទ ដី ជីវភាពរស់នៅនិងរបៀបរស់នៅទាំងស្រុងរបស់ជនជាតិដើមភាគតិចពួងដែលកំពុងរស់នៅក្នុងភូមិក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង កំពុងស្ថិតក្រោមការគំរាមកំហែងពីការសាងសង់ទំនប់សេសានក្រោម២ ដែលត្រូវបានអនុម័តកាលពីខែវិច្ឆិកា ឆ្នាំ២០១២ ហើយបច្ចុប្បន្ននេះកំពុងស្ថិតក្រោមការសាងសង់របស់ក្រុមហ៊ុនទំនប់វារីអគ្គិសនីសេសានក្រោម២របស់កម្ពុជាចិននៅលើទន្លេសេសាន។[78] អ្នករស់នៅទីនោះ បានរស់នៅលើដីនេះតាំងពីបុព្វបុរសខ្លួនមកម្ល៉េះ ហើយពឹងផ្អែកជីវិតរបស់ពួកគេទៅលើទន្លេនិងព្រៃដែលនៅជុំវិញ ហើយជាកន្លែងដែលពួកគេបរបាញ់សត្វព្រៃនិងប្រមូលអនុផលព្រៃឈើដូចជាផ្លែឈើ ទឹកឃ្មុំ ផ្សិត និងជ័រទឹក។ ដីនិងព្រៃក៏មានសារៈសំខាន់ខាងផ្នែកព្រលឹងដ៏ចម្បងមួយដែរ ដោយសារតែវាមានចំណងទៅនឹងបុព្វបុរសរបស់ពួកគេនិងព្រលឹងធម្មជាតិ ដែលរួមមានទីតាំងសំខាន់ៗមួយចំនួនដែលប្រជាជនមូលដ្ឋានបន់ស្រន់ចំពោះព្រលឹងទាំងនោះក្នុងការស្រែកជង្រើយសុំជំនួយដើម្បីថែរក្សាសុខភាពព្រលឹងនិងរាងកាយរបស់សហគមន៍។

ការកសាងទំនប់វារីអគ្គីសនី ដែលនឹងផ្គត់ផ្គង់អគ្គិសនីដល់ខេត្តកំពង់ចាមនិងខេត្តក្រចេះបានចាប់ផ្តើមក្នុងខែកុម្ភៈ ឆ្នាំ២០១៤ ហើយតាមការប៉ាន់ស្មានមួយចំនួន ថានឹងអាចប្រតិបត្តិការបានត្រឹមឆ្នាំ២០១៧ ។ បើយោងតាមការវាយតម្លៃផលប៉ះពាល់បរិស្ថានដែលបានបញ្ចប់ក្នុងខែតុលា ឆ្នាំ២០០៨ ការកសាងទំនប់នេះនឹងត្រូវបំផ្លាញព្រៃចំនួន ៣០.០០០ ហិកតាដែលស្ថិតនៅតាមដងទន្លេស្រែពកនិងទន្លេសេសាន និងបំផ្លាញ ២៥%នៃដីកសិកម្មសរុបក្នុងស្រុកសេសាន ដែលជាការកាត់បន្ថយសមត្ថភាពផលិតយ៉ាងច្រើននៅក្នុងតំបន់នេះ។ ជាងនេះទៀត គម្រោងនេះនឹងធ្វើឲ្យលិចលង់លើផ្ទៃដី ៣៣៥ គម២។ ការសាងសង់ទំនប់នេះ តម្រូវឲ្យមានការផ្លាស់ប្តូរទីលំដោយគ្មានការស្ម័គ្រចិត្តទៅលើគ្រួសារចំនួន ១.៥៧៩ ទៅកាន់តំបន់លំនៅដ្ឋានចំនួន ៦ ដែលក្នុងនោះមានកន្លែងខ្លះស្ថិតនៅក្នុងតំបន់សម្បទានព្រៃ/ដីដែលបានអនុម័តរួចហើយ *"ដែលនេះទំនងជាទទួលរងការខាតយ៉ាងច្រើនក្នុងពេលបច្ចុប្បន្ននិងក្នុងពេលអនាគត"*។ ម្យ៉ាងវិញទៀត អង្គការសង្គមស៊ីវិលក្នុងស្រុកនិងអន្តរជាតិមួយចំនួនបានអះអាងថាការប៉ះពាល់របស់ទំនប់នេះ ទំនងជាធ្ងន់ធ្ងរជាងការទទួលស្គាល់កាលពីដំបូងទៅទៀត ដូច្នេះ ពួកគេអំពាវនាវឲ្យមានការធ្វើការប៉ាន់ប្រមាណផលប៉ះពាល់បរិស្ថានថ្មីមួយទៀត។

---

[77] សម្រាប់ព័ត៌មានបន្ថែមលើករណីនេះ សូមអាន ម.ស.ម.ក "ភូមិក្បាលរមាស ប្រវត្តិទំនប់ទន្លេសេសានក្រោម២" (ប្រវត្តិសកម្មជនដីធ្លី) http://bit.ly/21U8oB4

[78] ភូមិក្បាលរមាស ស្ថិតនៅលើរបត់នៃទន្លេពក ដែលជាចំណុចប្រសព្វរវាងទន្លេសេសាននិងទន្លេសេកុង មុនពេលចាក់ចូលទៅក្នុងទន្លេមេគង្គ។ ប្រព័ន្ធទន្លេដែលគេហៅថា ស៣ នេះ បង្កើតបានជាផ្នែកមួយតំបន់ទេសចរណ៍ព្រៃស្ងួតមេគង្គក្រោម ដែលជាតំបន់មួយដែលមានជីវសាស្ត្រចម្រុះសំបូរបែប និងជាលំនៅដ្ឋានសម្រាប់ប្រភេទសត្វកម្រនិងជិតផុតពូជជាច្រើនប្រភេទ។




អ្នកភូមិបានសរសេរលើជញ្ជាំងផ្ទះរបស់គាត់ដើម្បីសម្តែងការជំទាស់ចំពោះទំនប់សេសានក្រោម២
រូបភាពដោយ ម.ស.ម.ក

ព្រៃនៅជិតភូមិក្បាលរមាសកំពុងត្រូវបានគេឈូសឆាយដើម្បីបើកផ្លូវសាងសង់អាងស្តុកទឹកដែលនឹងធ្វើឲ្យភូមិលិចលង់នៅពេលក្រោយ ដែលទង្វើនេះបានឲ្យកាន់តែមានការលំបាកកើនឡើងសម្រាប់អ្នករស់នៅមូលដ្ឋានក្នុងការបន្តវិធីរកប្រាក់ចំណូលតាមបែបប្រពៃណីរបស់ខ្លួន។ ក្នុងឆ្នាំ២០១៤ ក្រុមហ៊ុនបានសន្យាក្នុងការផ្លាស់ប្តូរទីលំនៅរបស់អ្នកភូមិថានឹងផ្តល់ដល់គ្រួសារមួយៗនូវដីមួយដុំទំហំ ៨០ ម៉ែត្រ ដីស្រែ ៥ ហិកតា ប្រាក់សំណង ៦.០០០ដុល្លារ និងផ្តល់ម្ហូបអាហារសម្រាប់រយៈពេលមួយឆ្នាំ បន្ថែមពីលើហេដ្ឋារចនាសម្ព័ន្ធផ្សេងៗនៅទីតាំងលំនៅដ្ឋានថ្មីនោះ។ តំណាងសហគមន៍បានអះអាងថា ភាគច្រើននៃអ្នកដែលបានយល់ព្រមក្នុងការផ្លាស់ប្តូរទីលំនៅនោះ គឺជាសមាជិកសហគមន៍ដែលបានរៀបការជាមួយប្រជាពលរដ្ឋដែលមិនមែនជាជនជាតិដើមភាគតិចនិងបានចាកចេញពីសហគមន៍ទៅហើយ ហើយបានត្រឡប់មកវិញនៅពេលដែលបានដឹងអំពីការផ្តល់សំណងពីក្រុមហ៊ុនប៉ុណ្ណោះ។ ប៉ុន្តែ អាជ្ញាធរប៉ុនប៉ងប្រើប្រាស់ការផ្លាស់ប្តូរទីលំនៅរបស់ពួកគេជាភស្តុតាងក្នុងការបង្ហាញថាសមាជិកសហគមន៍ដែលនៅសល់ជាមនុស្សមានះមិនព្រមក្នុងការផ្លាស់ប្តូរទីលំនៅនោះទេ។ នៅពេលអ្នកភូមិបានព្យាយាមរៀបកិច្ចប្រជុំនៅក្នុងភូមិដើម្បីពិភាក្សាអំពីបញ្ហាការផ្លាស់ប្តូរទីលំនៅនិងបញ្ហាសំណងនោះ ពួកគេបានជួបនឹងការរារាំងពីអាជ្ញាធរមូលដ្ឋាន។

ជាងនេះទៅទៀត សម្បទានដីសេដ្ឋកិច្ចទំហំ ១១.២៥៧ ហិកតា ដែលផ្តល់ឲ្យក្រុមហ៊ុនវិនិយោគស៊ីវហ៊្វិចដែលមានម្ចាស់ជាជនជាតិចិនក្នុងឆ្នាំ២០០៦ កំពុងតែបណ្តាលឲ្យមានបញ្ហាបន្ថែមទៀតសម្រាប់ជនជាតិដើមភាគតិចព្នងនៅក្នុងភូមិក្បាលរមាស។ សម្បទានដីសេដ្ឋកិច្ចបានទន្ទ្រានទៅលើដីនិងព្រៃសហគមន៍ រួមទាំងព្រៃអារក្សផង ហើយក្រុមហ៊ុននេះកំពុងទទួលរងការចោទអំពីការកាប់ឈើខុសច្បាប់ក្នុងតំបន់នោះ។[79]

អភិបាលខេត្តបានសម្រេចទទួលស្គាល់សហគមន៍ជាសហគមន៍ជនជាតិដើមភាគតិចក្នុងខែតុលា ឆ្នាំ ២០១២ ហើយបានដាក់សំណើរបស់សហគមន៍ទៅក្រសួងអភិវឌ្ឍន៍ជនបទក៏ប៉ុន្តែសហគមន៍នៅតែកំពុងរង់ចាំ

[79] ផាក សៀងលី និង ដានីញែល ផាយ "ឈើប្រណិតត្រូវរកឃើញកប់ទុក" (១៧ ខែកុម្ភៈ ឆ្នាំ២០១៤) http://bit.ly/1QiweCH

ការទទួលស្គាល់អត្តសញ្ញាណពីក្រសួងអភិវឌ្ឍន៍ជនបទ។ តំណាងសហគមន៍ចង់ឲ្យរដ្ឋាភិបាលផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដើម្បីការពារដីរបស់ពួកគេពិចារណាឡើងវិញអំពីគម្រោងទំនប់វារីអគ្គិសនី និងវាយតម្លៃពីផលប៉ះពាល់បរិស្ថានបន្ថែមទៀត។ សមាជិកក្រុមប្រឹក្សាឃុំដែលបន្តគាំទ្រសហគមន៍ក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនោះបានបញ្ចេញឲ្យដឹងថាគាត់ជឿថាដំណើរការនេះ *"ជាប់គាំងដោយសារតែអាជ្ញាធរនៅថ្នាក់ក្រោម ពីព្រោះពួកគេតែងតែព្រងើយកន្តើយចំពោះការអនុវត្តច្បាប់"* និងបដិសេធក្នុងការជួយសហគមន៍កំណត់ព្រំដីរបស់ពួកគេ។ គាត់បានបន្ថែមទៀតថា *"ខ្ញុំមានការបារម្ភខ្លាំងណាស់អំពីអនាគត ខ្លាចខ្ញុំមិនអាចការពារប្រជាជនបានទៀត ពីព្រោះក្រុមប្រឹក្សាឃុំកំពុងស្វែងរកវិធីដើម្បីឈ្នះហើយខ្ញុំមានតែម្នាក់ឯងទេដែលគាំទ្រពួកគេ"*។

សមាជិកក្រុមប្រឹក្សាឃុំក្នុងតំបន់មួយចំនួន ពិតជាបានបន្តគាំទ្រដល់សហគមន៍ក្នុងដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព ជាពិសេសនៅពេលដែលពួកគេជាសមាជិកជនជាតិដើមភាគតិច។ ប៉ុន្តែ កម្រមានមនុស្សដូចពួកគាត់ណាស់ ហើយការគាំទ្រដល់សហគមន៍គឺជាហានិភ័យផ្ទាល់ខ្លួនយ៉ាងខ្លាំង។ ជំទប់ទីពីរឃុំជំនាប់ បានពន្យល់ថា នៅពេលដែលគាត់គាំទ្រសហគមន៍ជនជាតិដើមភាគតិចនៅស្ទឹងអារ៉ែងក្នុងដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព និងជួយរៀបចំឯកសារចាំបាច់សម្រាប់ដំណាក់កាលដំបូងនោះ នាងមានការភ័យខ្លាចអំពីផលវិបាកដែលកើតចេញពីការគាំទ្រនេះ *"ខ្ញុំខ្លាចថាថ្ងៃណាមួយ គេដកខ្ញុំចេញពីក្រុមប្រឹក្សាឃុំ។ គេស្គាល់ខ្ញុំថាខ្ញុំជាមនុស្សសកម្មក្នុងការគាំទ្រសហគមន៍និងមិនគាំទ្រក្រុមហ៊ុនទេ ដូច្នេះខ្ញុំជាគោលដៅរបស់ពួកគេ"*។ ការភ័យខ្លាចនេះ មិនមែនគ្មានមូលដ្ឋានទេ។ សមាជិកក្រុមប្រឹក្សាឃុំម្នាក់ឈ្មោះ វ៉ែន វ៉ន ដែលគាំទ្រសហគមន៍ ត្រូវបានគេចាប់ខ្លួនកាលពីខែតុលា ឆ្នាំ២០១៥ ហើយចាប់ពីពេលនោះមក ត្រូវបានគេឃុំខ្លួនតាមទំនើងចិត្តពីបទចោទមិនពិតមួយចំនួន ដោយសារតែភាពសកម្មរបស់គាត់ក្នុងការគាំទ្រសហគមន៍។

## ៤.២.២ កង្វះខាតសមត្ថកិច្ចនិងសមត្ថភាព

សូម្បីតែនៅក្នុងករណីដ៏កម្រដែលអាជ្ញាធរមូលដ្ឋានចង់គាំទ្រដល់សហគមន៍ក៏ដោយ ក៏ពួកគេមិនមានសមត្ថភាពឬសមត្ថកិច្ចគ្រប់គ្រាន់ក្នុងការចាត់វិធានការសម្រាប់គាំទ្រដែរ។ ដូចបានបង្ហាញពីខាងដើមហើយថាអាជ្ញាធរថ្នាក់ឃុំជាច្រើន ខ្វះចំណេះដឹងអំពីដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនិងជំហានចាំបាច់ដែលពាក់ព័ន្ធនឹងដំណើរការនេះ។ ជាងនេះទៀត ក្រុមហ៊ុនដែលមានការពាក់ព័ន្ធនៅក្នុងវិវាទដីធ្លីជាមួយសហគមន៍ជនជាតិដើមភាគតិចបានទទួលអាជ្ញាប័ណ្ណពីរដ្ឋាភិបាលដូច្នេះដើម្បីគាំទ្រសហគមន៍បានអាជ្ញាធរមូលដ្ឋាននឹងត្រូវតែជំទាស់នឹងការសម្រេចចិត្តដែលបានធ្វើឡើងរួចហើយនៅកម្រិតរដ្ឋាភិបាល។ តាមរយៈអំណាចពិតប្រាកដដ៏តិចតួចស្តួចស្តើងនោះ អាជ្ញាធរមូលដ្ឋានបានត្រឹមតែធ្វើតាមបញ្ជាពីថ្នាក់លើប៉ុណ្ណោះ ហើយភាគច្រើនភ័យខ្លាចថាការមិនធ្វើតាមថ្នាក់លើនឹងបណ្តាលឲ្យមានការដកចេញពីតួនាទី។ ដូចដែលអ្នកតំណាងម្នាក់មកពីសមាគមអាដហុកបានរៀបរាប់ថា *"បញ្ហាជាមួយអាជ្ញាធរមូលដ្ឋាន ជាពិសេសនៅថ្នាក់ឃុំ គឺថាពួកគេមិនបានដឹងអំពីវិមជ្ឈការទេ ពួកគេមិនបានដឹងអំពីសិទ្ធិ អំណាចរបស់ពួកគេទេ ពួកគេកម្រអាចធ្វើការសម្រេចចិត្តដោយខ្លួនឯងណាស់ ពួកគេបានតែរង់ចាំបញ្ជាពីអភិបាលខេត្ត។ ពួកគេមិនយល់អំពីតួនាទីរបស់ខ្លួន ដូច្នេះ តើឲ្យពួកគេ*

*អាចអនុវត្តច្បាប់ដោយរបៀបណា? ហើយពួកគេខ្លាចថ្នាក់លើរបស់ខ្លួន គឺថាប្រសិនបើពួកគេមិនធ្វើតាមបញ្ជាទេ ពួកគេនឹងមានបញ្ហា"។*

## ៤.២.៣ ការស៊ីមគ្រលុំជាមួយក្រុមហ៊ុន

ក្នុងចំណោមសហគមន៍ដែលមានបំណងទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព មានការបញ្ចេញឲ្យដឹងអំពីករណីដែលអាជ្ញាធរមូលដ្ឋានដើរតួប្រឆាំងសហគមន៍ ដោយស៊ីមគ្រលុំជាមួយក្រុមហ៊ុន។ នៅឯតំបន់ស្ទឹងអារ៉ែង សហគមន៍បានរៀបរាប់អំពីរឿងកាលពីមុនដែលមេឃុំនិងក្រុមប្រឹក្សាឃុំគាំទ្រទាំងអស់ដល់ការចង់ចុះបញ្ជីដីរបស់ពួកគេដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព ក៏ប៉ុន្តែក្រោយមក *"មេឃុំបានផ្លាស់ប្តូរឥរិយាបទ ហើយឥឡូវបែរជាគាំទ្រក្រុមហ៊ុនទៅវិញ"*។ ក្នុងចំណោមសមាជិកក្រុមប្រឹក្សាឃុំប្រាំរូបមានតែពីររូបទេដែលបន្តគាំទ្រកិច្ចខិតខំរបស់សហគមន៍។ *"វាប្រហែលជាដោយសារតែសំណូក ប៉ុន្តែយើងគ្មានភស្តុតាងទេ"* ដែលនេះជាការពន្យល់របស់តំណាងសហគមន៍ពាក់ព័ន្ធនឹងការផ្លាស់ប្តូរឥរិយាបទរបស់អាជ្ញាធរមូលដ្ឋាន។ ឥឡូវនេះ អាជ្ញាធរបានគាបសង្កត់ជាប្រចាំទៅលើសហគមន៍ឲ្យទទួលយកគម្រោងទំនប់វារីអគ្គិសនីនិងផ្លាស់ប្តូរលំនៅដ្ឋាន។

ស្រដៀងគ្នានេះដែរ នៅភូមិចក់ចារ អាជ្ញាធរមូលដ្ឋានបានភ្លេចពាក្យសន្យាអំពីការគាំទ្រពីដំបូងដល់កិច្ចប្រឹងប្រែងក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពដែលសហគមន៍អះអាងថា ដោយសារតែគំនាបពីក្រុមហ៊ុន។ នៅភូមិក្បាលរមាស សមាជិកក្រុមប្រឹក្សាឃុំម្នាក់ដែលបានចោទថាក្រុមហ៊ុនបានផ្តល់សំណូកដល់សមាជិកក្រុមប្រឹក្សាទាំងនោះ ដោយគាត់បានរៀបរាប់អំពីរបៀបដែលក្រុមហ៊ុនបានទៅរកគាត់ជាច្រើនដង ដែលគាត់ជឿថាជាការប៉ុនប៉ងក្នុងការទិញការគាំទ្ររបស់គាត់ *"ខ្ញុំមិនទុកចិត្តក្រុមហ៊ុនទេ ហើយមិនដែលទៅជាមួយពួកគេទេ... ពួកគេមិនដែលបាននិយាយឲ្យចំរឿងលុយទេ ប៉ុន្តែនៅពេលដែលពួកគេអញ្ជើញខ្ញុំទៅជិះឡានទៅជាមួយពួកគេហើយស៊ីផឹកនោះ វាជាសញ្ញាមួយហើយ"*។

## ៤.២.៤ ការគាបសង្កត់ឲ្យទទួលយកកម្មសិទ្ធិដីឯកជន

ដូចបានកត់សម្គាល់រួចមកហើយ វាមិនមែនជារឿងចម្លែកទេសម្រាប់សហគមន៍ជនជាតិដើមភាគតិចដែលប្រឈមនឹងការគាបសង្កត់ពីអាជ្ញាធរមូលដ្ឋាន និស្សិតស្ម័គ្រចិត្ត ឬក្រុមហ៊ុនពាក់ព័ន្ធក្នុងវិវាទដីធ្លីនេះឲ្យព្រមទទួលយកកម្មសិទ្ធិដីឯកជន តាមរយៈការគំរាមកំហែងនិងផលប្រយោជន៍ផ្សេងៗ។ បើយោងតាមសហគមន៍ក្បាលរមាស ថ្វីត្បិតតែពួកគេបានតាំងចិត្តខ្ពស់ក្នុងការទទួលឲ្យបានប័ណ្ណកម្មសិទ្ធិដីសមូហភាពក៏ដោយ ក៏ពួកគេបានប្រឈមនឹងការគាបសង្កត់ជាច្រើនពីក្រុមហ៊ុនទំនប់វារីអគ្គិសនីសេសានក្រោម ២ ឲ្យពួកគាត់ទទួលយកកម្មសិទ្ធិដីឯកជនដែរ ដោយសមាជិកម្នាក់បានរៀបរាប់អំពីរបៀប *"ដែលស្ទើររាល់ថ្ងៃ ពួកគេបានមកដាក់សម្ពាធឲ្យយើងទទួលយកកម្មសិទ្ធិដីឯកជននៅតំបន់លំនៅដ្ឋានថ្មី"*។ នៅឃុំប៊ូស្រាក៏ដូច្នោះដែរ គឺថាអាជ្ញាធរមូលដ្ឋានតែងតែងបញ្ចុះបញ្ចូលអូសទាញសហគមន៍ឲ្យទទួលយកកម្មសិទ្ធិដីឯកជន។ មេឃុំបានព្យាយាមអូសទាញសហគមន៍ដោយប្រាប់ថាធនាគារនឹងឲ្យលុយខ្ចីសម្រាប់តែអ្នកដែលមានប័ណ្ណកម្មសិទ្ធិដីឯកជនតែប៉ុណ្ណោះ ដែលប័ណ្ណនេះអាចត្រូវបានប្រើជាទ្រព្យបញ្ចាំដើម្បីទទួលបានប្រាក់កម្ចី ហើយប្រសិនបើពួកគេនៅតែបន្តចង់បានប័ណ្ណកម្ម

សិទ្ធិដីសមូហភាពនោះ ពួកគេមិនអាចខ្ចីលុយបានទេ ហើយផ្ទុយមកវិញនឹង *"ត្រូវរស់នៅដូចរបបប៉ុលពត"*។ ការយោងប្រៀបធៀបជាប្រចាំទៅនឹងសម័យប៉ុលពត ត្រូវបានអាជ្ញាធរប្រើជាតិចនិចមួយដើម្បីធ្វើឲ្យប្រជាជនភ័យខ្លាច និងដឹងគុណចំពោះសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍជាមូលដ្ឋានដែលបានទទួលនៅក្នុងរបបបច្ចុប្បន្ននេះ។[80] មេឃុំប៊ូស្រាបានព្យាយាមជំរុញឲ្យសហគមន៍ស្នើសុំសម្បទានដីសង្គមកិច្ច និងទទួលយកកម្មសិទ្ធិដីឯកជន ក៏ប៉ុន្តែទោះបីជាត្រូវប្រឈមជាមួយនឹងការធ្វើទុក្ខបុកម្នេញនិងការគំរាមកំហែងក៏ដោយ ក៏តំណាងសហគមន៍នៅតែមានភាពរឹងមាំក្នុងការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពដែរ។ ដូចដែលតំណាងសហគមន៍ម្នាក់បានពន្យល់ថា *"ប្រសិនបើយើងទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព យើងនឹងមានដីប្រពៃណីរបស់យើងគ្រប់ប្រភេទ។ ប្រសិនបើយើងទទួលបានបណ្ណកម្មសិទ្ធិដីឯកជននោះ គ្រួសារខ្លះនឹងបាត់បង់ដីរបស់ពួកគេក្នុងពេលអនាគតដូចជានៅពេលដែលពួកគេមានបញ្ហាលុយកាក់ ពួកគេអាចលក់ដីឯកជននោះ។ ប័ណ្ណកម្មសិទ្ធិដីសមូហភាព ការពារដីសម្រាប់មនុស្សជំនាន់ក្រោយ"*។

មន្ត្រីសុរិយោដីស្រុកក៏បានគាបសមាជិកសហគមន៍ក្នុងឃុំប៊ូស្រាឲ្យព្រមទទួលយកកម្មសិទ្ធិដីឯកជនដើម្បីបានការទទួលស្គាល់។ មន្ត្រីទាំងនោះគំរាមថាប្រសិនបើគ្មានប័ណ្ណកម្មសិទ្ធិដីឯកជនទេសហគមន៍នឹងបាត់បង់ដីរបស់ខ្លួនហើយអាជ្ញាធរនឹងមិនទទួលខុសត្រូវទេ ដែលគំនិតនេះត្រូវបាននិស្សិតស្ម័គ្រចិត្តលើកមកគំរាមពួកគាត់ផងដែរ។ បន្ថែមពីលើនេះ សហគមន៍នៅស្ទឹងអារ៉ែងបានប្រឈមនឹងការគាបសង្កត់ពីនិស្សិតស្ម័គ្រចិត្តឲ្យព្រមទទួលយកកម្មសិទ្ធិដីឯកជននៅទីតាំងថ្មី ហើយដែលបានគំរាមសហគមន៍ថា ប្រសិនបើពួកគេខកខានមិនព្រមទទួលយកទេ ពួកគេនឹងគ្មានបានអ្វីទាំងអស់។

## ៤.២.៥ ការធ្វើទុក្ខបុកម្នេញពីប្រព័ន្ធយុត្តិធម៌

សមាជិកសហគមន៍ជាច្រើនបានប្រឈមមុខនឹងការធ្វើទុក្ខបុកម្នេញពីប្រព័ន្ធតុលាការនៅពេលព្យាយាមការពារដីរបស់ខ្លួន។ ឧទាហរណ៍ សមាជិកសហគមន៍ប្រាំនាក់នៅក្នុងភូមិចឹងដែលប៉ុនប៉ងការពារដីរបស់ពួកគេដែលកំពុងបាត់បង់យ៉ាងរហ័សនោះ ត្រូវបានគេចាប់ខ្លួននិងឃុំខ្លួនពីបទ *"ឆបោក"* (មាត្រា៣៧៧ នៃក្រមព្រហ្មទណ្ឌ) ក្នុងខែកុម្ភៈ ឆ្នាំ២០១៤។ រឿងនេះបានកើតឡើងបីថ្ងៃ បន្ទាប់ពីពួកគាត់ដាក់ពាក្យបណ្តឹងលើអធិការរងនគរបាលម្នាក់ដែលបានកាប់ព្រៃ និងបានលក់ដីព្រៃរបស់សហគមន៍ចំនួន ៤០ ហិកតា។ តំណាងសហគមន៍ទាំងនោះត្រូវបានដោះលែងឲ្យនៅក្រៅឃុំបួនខែក្រោយមកក្នុងខែមិថុនា ឆ្នាំ២០១៤។ ថ្មីៗនេះ ខណៈពេលដែលក្រុមការងារគម្រោងកំពុងធ្វើការស្រាវជ្រាវ សមាជិកគ្រួសាររបស់តំណាងសហគមន៍ម្នាក់បានទទួលការហៅទូរសព្ទអនាមិកមួយគំរាមអំពីការចាប់ខ្លួនតំណាងសហគមន៍។ បញ្ហានេះបានកើតឡើងមួយថ្ងៃបន្ទាប់ពីអ្នកភូមិបានដាក់ញត្តិទៅអាជ្ញាធរថ្នាក់ស្រុកស្នើសុំឲ្យបណ្តេញមេភូមិចេញពីតំណែងដោយសារតែការខ្វះការគាំទ្រពីមេភូមិនោះ។ ការចាប់ខ្លួននិងការគំរាមចាប់ខ្លួនទាំងនេះពិតជាបុព្វហេតុមួយនៃការព្រួយបារម្ភពីសំណាក់សកម្មជននិង

---

[80] សេបាស្ទៀនស្ទ្រេងជីអូ "កម្ពុជារបស់លោកហ៊ុនសែន" (ឆ្នាំ២០១៤)។

សមាជិកសហគមន៍ ហើយវាជាការក្រើនរំលឹកក្រៃលែងមួយដល់អ្នកផ្សេងទៀតដែលកំពុងទទួលបានការជំរុញចិត្តឲ្យតស៊ូមតិដើម្បីការពារដីរបស់ពួកគេ។

នៅភូមិចក់ចារ ក៏មានការទទួលស្គាល់យ៉ាងទូលាយដោយសហគមន៍មូលដ្ឋាននិងអង្គការមិនមែនរដ្ឋាភិបាលថា អាជ្ញាធរខេត្តមានការពាក់ព័ន្ធនឹងការកាប់ឈើខុសច្បាប់ដែលរីករាលដាលយ៉ាងខ្លាំងពាសពេញតំបន់នោះ។[81] ប៉ុន្តែ ខណៈដែលអាជ្ញាធរធ្វើជាមើលមិនឃើញជនល្មើសកាប់ឈើពិតប្រាកដនោះ សមាជិកសហគមន៍បែរជាត្រូវបានចោទប្រកាន់ពីការអនុវត្តខុសច្បាប់ទៅវិញ ទោះបីជាច្បាប់បានអនុញ្ញាតឲ្យសហគមន៍ជនជាតិដើមភាគតិចបន្តការប្រើប្រាស់ព្រៃតាមបែបប្រពៃណី ដែលរួមមានទាំងការប្រើប្រាស់ឈើសម្រាប់សង់ផ្ទះនិងក្រោលសត្វក៏នោះដោយ។ ការចោទសហគមន៍ជនជាតិដើមអំពីការកាប់ឈើខុសច្បាប់នៅពេលដែលពួកគេគ្រាន់តែប្រើប្រាស់ព្រៃនិងដីស្របតាមប្រពៃណីនិងច្បាប់នោះ គឺជាវិធីដែលអាជ្ញាធរប្រើប្រាស់ដើម្បីធ្វើទុក្ខបុកម្នេញទៅលើសហគមន៍ និងរារាំងពួកគេក្នុងការការពារដីរបស់ពួកគេបានតែប៉ុណ្ណោះ។ ការធ្វើទុក្ខបុកម្នេញតាមប្រព័ន្ធតុលាការដែលសកម្មជនសហគមន៍ប្រឈមនៅស្ទឹងអារ៉ែងនេះអាចបង្ហាញដូចតទៅនេះ ៖

**ករណីសិក្សាៈ ការធ្វើទុក្ខបុកម្នេញតាមប្រព័ន្ធតុលាការ ទៅលើជនជាតិដើមជងនៅស្ទឹងអារ៉ែង**[82]

**ស្ថានភាពប័ណ្ណកម្មសិទ្ធិដីសមូហភាព៖** នៅតែស្ថិតក្នុងដំណើរការប៉ុនប៉ងចង់ទទួលបានការទទួលស្គាល់អត្តសញ្ញាណជាផ្លូវការពីក្រសួងអភិវឌ្ឍន៍ជនបទ។



[81] នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៥ សមាជិកសហគមន៍មកពីភូមិចក់ចារ រួមជាមួយនឹងអង្គការអាដហុកនិងដៃគូអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត បានដាក់ញត្តិមួយទៅរដ្ឋាភិបាល ទាក់ទងនឹងការពាក់ព័ន្ធរបស់ប៉ូលីសយោធាខេត្តក្នុងការកាប់ឈើខុសច្បាប់ក្នុងតំបន់នោះ។

[82] សម្រាប់ព័ត៌មានបន្ថែមអំពីករណីនេះ សូមអាន៖ ម.ស.ម.ក "តំបន់អារ៉ែង៖ ដីរបស់ជនជាតិដើមភាគតិចរងការគំរាមពីការសាងសង់ទំនប់វារីអគ្គិសនី" (ប្រវត្តិសកម្មជនដីធ្លី) http://bit.ly/1GvNUBJ

ស្ទឹងអារ៉ែង ដែលនឹងលិចលង់ជ្រលងអារ៉ែងប្រសិនបើមានការសាងសង់ទំនប់វារីអគ្គីសនី

រូបថតដោយ៖ ម.ស.ម.ក

តំបន់ស្ទឹងអារ៉ែងដែលស្ថិតនៅក្នុងស្រុកថ្មបាំង ខេត្តកោះកុង គឺជាផ្នែកមួយនៃតំបន់ព្រៃការពារជួរភ្នំក្រវាញកណ្ដាលនិងជាតំបន់ជីវចម្រុះខ្ពស់ដែលមានសត្វព្រៃមួយចំនួនស្ថិតក្នុងសភាពគ្រោះថ្នាក់និងមានប្រជាជនរស់នៅប្រហែល ១.៥០០នាក់ ហើយភាគច្រើនជាជនជាតិដើមភាគតិចជង។ អ្នករស់នៅនិងដូនតា របស់ពួកគេបានរស់នៅលើដីនេះតាំងពីយូយារណាស់មកហើយ តែពុំមាននរណាម្នាក់ចងចាំថាពេលណានោះទេ។ ប៉ុន្តែគម្រោងទំនប់វារីអគ្គីសនីដែលត្រូវបានស្នើឡើងនិងអនុវត្តដោយក្រុមហ៊ុនស៊ីណូហាយដ្រូ (កម្ពុជា) យូណាធីតអិលធីឌី (ស៊ីណូហាយដ្រូ) នេះ មានការគំរាមកំហែងដល់ដី ជីវភាពរស់នៅ និងបរិស្ថានធម្មជាតិរបស់ពួកគេ។ ពីមុន ក្រុមហ៊ុនពីរផ្សេងទៀតបានទទួលការងារអនុវត្តគម្រោងនេះ ប៉ុន្តែបានដកខ្លួនចេញបន្ទាប់ពីការសិក្សាសមិទ្ធិលទ្ធភាព។ ក្រុមហ៊ុនស៊ីណូហាយដ្រូ បានចូលជំនួសគម្រោងទំនប់នេះក្នុងខែមករា ឆ្នាំ២០១៤។ គេមិនបានដឹងច្បាស់ថាតើគម្រោងនេះនឹងបញ្ចប់នៅពេលណានោះទេ ប៉ុន្តែសម្តេចនាយករដ្ឋមន្ត្រីហ៊ុន សែន បានប្រកាសថាការសាងសង់នឹងមិនចាប់ផ្តើមមុនឆ្នាំ២០១៨ ទេ។[83]

សហគមន៍ជនជាតិដើមភាគតិចដែលទទួលរងការប៉ះពាល់ បានជំទាស់ជានិច្ចចំពោះទំនប់នេះ និងបានបដិសេធក្នុងការ ទទួលសំណងនិងការផ្លាស់ប្តូរទីលំនៅ។ ប្រសិនបើមានការសាងសង់ អាងទំនប់នឹងជន់លិចផ្ទៃដីប្រហែល ២០.០០០ ហិកតាក្នុងតំបន់នេះ ដែលនាំឲ្យលិចបាត់ដីបុព្វបុរស ព្រៃអារក្ស និងទីតាំងបញ្ចុះសព។ ក្នុងការប៉ុនប៉ងការពារដីរបស់ខ្លួន សហគមន៍បានរៀបចំការតវ៉ាប្រឆាំងនឹងក្រុមហ៊ុន និងបានបិទផ្លូវដើម្បីរារាំងមិនឲ្យបុគ្គលិករបស់ក្រុមហ៊ុនចូលដល់ទីតាំងស្នើសុំសាងសង់ទំនប់វារីអគ្គីសនីនោះ។ ក្រោយមក សមាជិកសហគមន៍ត្រូវបានចាប់ខ្លួននិងឃុំខ្លួនតាមទំនើងចិត្តជាច្រើនដង។

នៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៥ មេដឹកនាំសហគមន៍និងសកម្មជនឈ្មោះ វ៉ែន វន ត្រូវបានគេចាប់ខ្លួននិងបញ្ជូនទៅពន្ធនាគារខេត្តកោះកុង ហើយត្រូវបានគេឃុំខ្លួនចាប់ពីពេលនោះមក ដោយត្រូវបានចោទប្រកាន់ពីបទ *"ប្រមូលផលព្រៃឈើ និង/ឬ អនុផលព្រៃឈើដោយគ្មានការអនុញ្ញាត"* (មាត្រា៩៨ នៃច្បាប់ស្តីពីព្រៃឈើ) និងបទ *"បំផ្លាញភស្តុតាង"* (មាត្រា៥៣៣ នៃក្រមព្រហ្មទណ្ឌ)។ បទចោទទាំងពីរនេះទាក់ទងនឹងការសាងសង់កន្លែងសម្រាប់អ្នកទស្សនាតូចមួយនិងកន្លែងប្រជុំសហគមន៍សម្រាប់សកម្មជនដែលមានការពាក់ព័ន្ធក្នុងយុទ្ធនាការប្រឆាំងនឹងទំនប់វារីអគ្គិសនីដែលត្រូវបានស្នើឡើងក្នុងជ្រលងស្ទឹងអារ៉ែងនេះដោយលោក វ៉ែន វន និងសកម្មជនមូលដ្ឋានមួយក្រុម។ អង្គការសង្កេតការណ៍ដើម្បីការពារអ្នកការពារសិទ្ធិមនុស្សបានរិះគន់ការចាប់ឃុំខ្លួនតាម

[83] ហ៊ុលរស្មី "នាយករដ្ឋមន្ត្រី គំរាមប្រើប្រាស់គ្រាប់រ៉ុក្កែតនៅតំបន់អារ៉ែង" *ឌឹខេមបូឌាដេលី* (២៥ ខែកុម្ភៈ ឆ្នាំ២០១៥) http://bit.ly/1IZ1kYm

ទំនើងចិត្តទៅលើលោក វ៉ែន វន នេះថាជាការទណ្ឌកម្មសម្រាប់ *"សកម្មភាពសិទ្ធិមនុស្សស្របច្បាប់"* និងបានអំពាវនាវឲ្យមានការដោះលែងគាត់ជាបន្ទាន់និងគ្មានលក្ខខណ្ឌ។[84]



មណ្ឌលសហគមន៍ដែលសាងសង់ដោយលោក វ៉ែន វន និងសកម្មភាពរួមក្រុម ដែលត្រូវបានចោទពីបទកាប់ឈើខុសច្បាប់
រូបថត៖ ម.ស.ម.ក

ការធ្វើផែនការប្រើប្រាស់ដីដោយប្រើវិធីសាស្ត្រចូលរួម ត្រូវបានគេធ្វើឡើងនៅក្នុងសហគមន៍ចំនួនបី ដែលជាការផ្តល់ភស្តុតាងថាការប្រើប្រាស់ដីរបស់ជនជាតិដើមភាគតិច កើតមានមែននៅក្នុងតំបន់នោះ។ នៅដើមឆ្នាំ២០១៤ ក្រុមមេធាវីសិទ្ធិ ចាប់ផ្តើមជួយជ្រោមជ្រែងដល់សហគមន៍ក្នុងដំណាក់កាលដំបូងនៃដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព ក៏ប៉ុន្តែ បញ្ហាថវិកាបានធ្វើឲ្យដំណើរការត្រូវបញ្ឈប់ ហើយសហគមន៍មិនទាន់បានការទទួលស្គាល់អត្តសញ្ញាណជាផ្លូវការពីសំណាក់ក្រសួងអភិវឌ្ឍន៍ជនបទនៅឡើយទេ។ ថ្មីៗនេះ ការរំពឹងរបស់សហគមន៍ថានឹងបានការទទួលស្គាល់ផ្លូវការនេះមានការកើនឡើងដោយសារតែការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាបានសម្តែងនូវចំណាប់អារម្មណ៍ក្នុងការគាំទ្រដល់សហគមន៍នៅក្នុងដំណាក់កាលទីមួយនេះ។ សហគមន៍ចង់ឲ្យរដ្ឋាភិបាលពន្លឿនដំណើរការចុះបញ្ជីកម្មសិទ្ធិដីសមូហភាពនេះ និងលុបចោលគម្រោងទំនប់វារីអគ្គិសនីដែលមិនត្រឹមតែធ្វើឲ្យមហន្តរាយដល់ជីវភាពរស់នៅរបស់ប្រជាជនទេ ហើយថែមទាំងគំរាមកំហែងដល់អត្តិភាពរបស់ក្រុមជនជាតិដើមភាគតិចផងដែរ។ ដូចតំណាងសហគមន៍ម្នាក់បានសន្និដ្ឋានថា *"នៅពេលយើងត្រូវជម្លៀសចេញពីទីនេះ អ្វីៗទាំងអស់ដែលពាក់ព័ន្ធនឹងអត្តសញ្ញាណរបស់យើងនឹងត្រូវបាត់បង់អស់។ វប្បធម៌និងប្រពៃណីរបស់យើងគឺពឹងផ្អែកលើដី។ យើងនឹងក្លាយទៅជាប្រជាជនខ្មែរទូទៅ យើងលែងជាជនជាតិដើមភាគតិចដងទៀតហើយ"*។

---

[84] អង្គការប្រឆាំងទារុណកម្មពិភពលោក និងសម្ព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស "ប្រទេសកម្ពុជា៖ ការឃុំខ្លួនតាមទំនើងចិត្ត និងការធ្វើទុក្ខបុកម្នេញពីប្រព័ន្ធតុលាការអំពីបណ្តឹងឧទ្ធរណ៍លោក វន ពៅ-ឱអប់សឺវេថូរី (ថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥) http://bit.ly/1Qe9pjq

### ៤.២.៦ ការធ្វើទុក្ខបុកម្នេញតាមទម្រង់ផ្សេងទៀត

បន្ថែមពីលើការធ្វើទុក្ខបុកម្នេញតាមប្រព័ន្ធតុលាការ នៅស្ទឹងអារ៉ែងសហគមន៍បានប្រឈមនឹងការធ្វើទុក្ខបុកម្នេញដោយពាក្យសម្តីនិងផ្លូវចិត្តជាច្រើន។ ឧទាហរណ៍ អាជ្ញាធរមូលដ្ឋានបានចោទសហគមន៍ថារស់នៅលើដីដោយខុសច្បាប់និងថាមិនមែនជាជនជាតិដើមភាគតិច ដោយសារតែពួកគេអាចនិយាយភាសាខ្មែរបាននិងសួរពួកគាត់ថា *"បើអ្នកជាជនជាតិដើមភាគតិច ហេតុអ្វីក៏ចេះនិយាយភាសាខ្មែរ?"* សហគមន៍ជនជាតិដងបានបាត់បង់ភាសាជូនតារបស់ពួកគេ (បើទោះតាមការសង្កេតឃើញមានពាក្យជនជាតិភាគតិតខ្លះមានបង្កប់ក្នុងភាសានិយាយក៏ដោយ)។ ច្បាស់ណាស់ថា អាជ្ញាធរប្រើប្រាស់ចំណុចនេះជាឧបករណ៍សម្រាប់បំភិតបំភ័យសហគមន៍ដូចសហគមន៍បានអះអាងថា *"អាជ្ញាធរប្រើប្រាស់ចំណុចនេះ ដើម្បីកុំឲ្យពួកយើងត្រូវបានការទទួលស្គាល់ជាជនជាតិដើមភាគតិច"*។ អាជ្ញាធរក៏ប្រើប្រាស់ ឈ្មោះ អាឡិច ហ្គូសាឡេ ដាវីដសុន (Alex Gonzalez-Davidson)[85]ដែលជាសកម្មជនបរិស្ថានដើម្បីប្រឆាំងនឹងសហគមន៍ផងដែរ។ សមាជិកសហគមន៍ម្នាក់បានលើកឡើងថា"[អាជ្ញាធរ] និយាយថានេះជាតំបន់ដែលគ្រប់គ្រងដោយអាឡិច។ សូម្បីតែគាត់បានចេញ*ពីប្រទេសទៅហើយក្តី ក៏ពួកគេនៅតែប្រើឈ្មោះរបស់គាត់ដើម្បីរារាំងយើងក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពដែរ"*។ បន្ថែមពីលើនេះ បន្ទាប់ពីមានការតវ៉ារបស់សហគមន៍ប្រឆាំងនឹងគម្រោងទំនប់វារីអគ្គិសនីនេះ ក្រុមប្រឹក្សាឃុំនេះបានគំរាមកំហែងក្នុងការលុបចោលក្រុមសន្សំប្រាក់នៅក្នុងសហគមន៍នោះ ដែលមនុស្សភាគច្រើនពឹងផ្អែកទៅលើក្រុមនេះសម្រាប់សន្តិសុខហិរញ្ញវត្ថុ។

សហគមន៍ជនជាតិដើមភាគតិចក្នុងឃុំប៊ូស្រា ក៏បានប្រឈមនឹងការធ្វើទុក្ខបុកម្នេញដោយអាជ្ញាធរមូលដ្ឋានដែលបានចោទប្រកាន់សហគមន៍ថាមានស្តង់ដាទ្វេគឺធ្វើការឲ្យក្រុមហ៊ុននិងបានលុយពីក្រុមហ៊ុន ប៉ុន្តែបែរជាតវ៉ាប្រឆាំងនឹងក្រុមហ៊ុនទៅវិញ។ ក្រៅពីមិនបានសន្តោសប្រណីដល់ស្ថានភាពដ៏លំបាករបស់សហគមន៍ធ្វើឲ្យសហគមន៍បានចោទអាជ្ញាធរវិញអំពីការមិនគោរពអត្តសញ្ញាណនិងវប្បធម៌របស់ជនជាតិដើមភាគតិចព្នងដោយបានសន្និដ្ឋានថា *"ការរើសអើងបានប៉ះពាល់ដល់អត្តសញ្ញាណសហគមន៍របស់យើង"*។

### ៤.៣ ក្រុមហ៊ុន

ខណៈដែលរដ្ឋាភិបាលតែម្នាក់ឯងជាអ្នកផ្តល់សម្បទានដីសេដ្ឋកិច្ចផង និងផ្តល់កម្មសិទ្ធិដីសមូហភាពផងនោះ សកម្មភាពរបស់ក្រុមហ៊ុនអាចរារាំងដល់ដំណើរការចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីសមូហភាព។ ក្រុមហ៊ុននៅកម្ពុជាច្រើនតែស៊ុមគ្រលុំជាមួយអាជ្ញាធរដើម្បីអនុញ្ញាតឲ្យពួកគេប្រតិបត្តិការសម្បទានដីសេដ្ឋកិច្ច ហើយបែរជាគេចវាសអនុវត្តតាមលក្ខខណ្ឌតម្រូវ។ ឧទាហរណ៍ នៅភូមិក្បាលរមាស សមាជិកក្រុមប្រឹក្សាឃុំបានពន្យល់ទៅកាន់ក្រុមការងារគម្រោងអំពីរបស់ដែលក្រុមហ៊ុនវិនិយោគស៊ីវហ៊្គិចទទួលបានសម្បទានដីសេដ្ឋកិច្ចក្នុងឆ្នាំ២០០៦

---

[85] ជាសកម្មជនបរិស្ថាននិងសហស្ថាបនិកអង្គការមាតាធម្មជាតិ អាឡិចបានធ្វើការដោយគ្មានភាពនឿយហត់ក្នុងការគាំទ្រដល់សហគមន៍មូលដ្ឋានដើម្បីការពារតំបន់អារ៉ែងពីការកាប់ឈើខុសច្បាប់និងទំនប់វារីអគ្គីសនីដែលបានស្នើឡើង។ គាត់ត្រូវបានគេបណ្តេញចេញពីប្រទេសកម្ពុជាក្នុងខែកុម្ភៈ ឆ្នាំ២០១៥ បន្ទាប់ពីរដ្ឋាភិបាលបដិសេធមិនបន្តទិដ្ឋាការដល់គាត់។

បន្ទាប់ពីស៊ុមគ្រលុំជាមួយអាជ្ញាធរមូលដ្ឋាន គឺថាក្រុមហ៊ុនបានឲ្យអាជ្ញាធរមូលដ្ឋានបោះត្រាលើផែនទីវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គមដើម្បីឲ្យពួកគេបានឆ្លងផុតដំណាក់ការអធិការកិច្ច និងឡើងទៅជំហានខាងមុខទៀតដល់រដ្ឋាភិបាល។ ក្រុមហ៊ុនក៏ប៉ុនប៉ងធ្វើឲ្យអាជ្ញាធរមូលដ្ឋានដកការគាំទ្រពីសហគមន៍ជនជាតិដើមភាគតិចតាមរយៈសំណូក។ ជារឿយៗ ពួកគេរួមគំនិតគ្នាដោយផ្ទាល់ក្នុងការធ្វើទុក្ខបុកម្នេញដល់សមាជិសហគមន៍ជនជាតិដើមភាគតិច ដោយការបណ្ដេញពួកគេចេញពីដីដោយបង្ខំ និងបំផ្លាញទំនុកចិត្តរបស់សហគមន៍ ដែលការធ្វើបែបនេះនឹងបំផ្លាញសមត្ថភាពតស៊ូមតិដើម្បីដីធ្លីរបស់ពួកគេ។ ជាងនេះទៀត ក្រុមហ៊ុនដែលកំពុងប្រតិបត្តិនៅក្នុងតំបន់ជនជាតិដើមភាគតិចនៅកម្ពុជា ច្រើនតែរារាំងដល់ដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពតាមរយៈការចាប់ច្បាមយកដី និងការសមគំនិតក្នុងការកាប់ឈើខុសច្បាប់នៅក្នុងសម្បទានរបស់ពួកគេនិងរារាំងសហគមន៍ក្នុងការទទួលបានការកំណត់ព្រំដីទៅលើដីជាដីប្រពៃណីរបស់ពួកគេ។ ការរារាំងក្នុងការកំណត់ព្រំដីជនជាតិដើមភាគតិចមានបង្ហាញជាឧទាហរណ៍នៅក្នុងភូមចក់ចារ។

**ករណីសិក្សា៖ ភូមិចក់ចារ**[86]

**ស្ថានភាពប័ណ្ណកម្មសិទ្ធិដីសមូហភាព៖** ទទួលបានការទទួលស្គាល់អត្តសញ្ញាណដីសមូហភាពផ្លូវការក្នុងឆ្នាំ ២០១០ បានចុះបញ្ជីជានីតិបុគ្គលក្នុងខែវិច្ឆិកា ឆ្នាំ២០១៣ និងបានដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពក្នុងខែធ្នូ ឆ្នាំ២០១៤។



ចាស់ទុំជនជាតិដើមភាគតិចព្នងនៅភូមិចក់ចារ

រូបថត៖ ម.ស.ម.ក

[86] សម្រាប់ព័ត៌មានបន្ថែមលើករណីនេះ សូមអាន៖ម.ស.ម.ក "មណ្ឌលគីរី-អ្នកភូមិជនជាតិដើមភាគតិចព្នងនិយាយថាការឈូសឆាយដីដោយក្រុមហ៊ុនចំការកៅស៊ូ គំរាមកំហែងដល់ជីវភាពរស់នៅនិងរបៀបរស់នៅតាមបែបប្រពៃណីរបស់ពួកគេ (ប្រវត្តិសកម្មជនដីធ្លី) http://bit.ly/1OWBit8

នៅក្នុងខេត្តដាច់ស្រយាលនិងមានព្រៃក្រាស់ក្នុងភាគឦសាននៃខេត្តមណ្ឌលគីរី អ្នករស់នៅដែលជាជនជាតិដើមភាគតិចព្នងនៅភូមិចក់ចារក្នុងស្រុកកែវសីមា បាននិយាយថា ដី ជីវភាព និងវប្បធម៌របស់ពួកគេកំពុងស្ថិតនៅក្រោមការគំរាមកំហែងពីសម្បទានដីសេដ្ឋកិច្ច ដែលកាន់កាប់ដោយក្រុមហ៊ុនចំការកៅស៊ូ ប៊ិញហ្វឿក១ក្រចេះ លីមិតធិត[87] ("ប៊ិញហ្វឿក១")។ ក្នុងខែតុលា ២០១១ ក្រុមហ៊ុនប៊ិញហ្វឿក១ ដែលជាក្រុមហ៊ុនឧបសម្ព័ន្ធរបស់ក្រុមហ៊ុនចំការកៅស៊ូរបស់រដ្ឋាភិបាលវៀតណាមទទួលបានសម្បទានដីសេដ្ឋកិច្ចនៅក្នុងតំបន់ដែលគ្របដណ្តប់លើផ្ទៃដីទំហំ ៨៨៩០ ហិកតាដែលក្នុងនោះ ៥១០០ ហិកតាត្រូវបានអនុញ្ញាតឲ្យប្រើសម្រាប់ដាំកៅស៊ូ។ សម្បទានដីសេដ្ឋកិច្ចបានទន្ទ្រានទៅលើដីសហគមន៍ និងនៅចុងឆ្នាំ២០១៣ ក្រុមហ៊ុនប៊ិញហ្វឿក១ បានចាប់ផ្តើមឈូសឆាយដីសហគមន៍នៅភូមិចក់ចារ ដោយរួមទាំងដីបញ្ចុះសពផង ទោះបីជាប្រជាជនប៉ុនប៉ងរារាំងក៏ដោយ។ អ្នកភូមិមួយចំនួនត្រូវបានគេចាប់ខ្លួនដោយសារវិវាទនៃការចូលរួមក្នុងការតវ៉ា ហើយក្រុមហ៊ុនប៊ិញហ្វឿក១ បានដាក់ពាក្យប្តឹងអ្នកភូមិដែលបានចូលរួមនៅក្នុងការតវ៉ាទាំងនោះ ដោយបានចោទពួកគេពីបទបំផ្លាញទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន។ អ្នកភូមិបានដាក់ពាក្យបណ្តឹងជាច្រើននៅតាមស្ថាប័នផ្សេងៗគ្នា ប៉ុន្តែករណីរបស់ពួកគេមិនត្រូវបានលើកយកមកដោះស្រាយឡើយ។ ក្នុងខែមិនា ២០១៥ ក្រុមហ៊ុននិងកងកម្លាំងប្រដាប់អាវុធ បានបំផ្លាញជម្រកនៅលើដីរបស់សហគមន៍ ដោយបានដុតបំផ្លាញជម្រកចំនួន ១៣០ខ្នង។

បន្ថែមពីលើនេះ អ្នកភូមិបានចោទថាក្រុមហ៊ុនប៊ិញហ្វឿក១ បានសម គំនិតក្នុងការកាប់ឈើខុសច្បាប់នៅក្នុងសម្បទានដី ដែលបណ្តាលឲ្យគេមិនអាចកំណត់ព្រំដីបាន។ ជំទប់ទីមួយ បានលើកឡើងថា ការកាប់ឈើខុសច្បាប់គឺជាឧបសគ្គមួយរារាំង ពួកគេក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព *"ពួកគេកាប់ឈើខុសច្បាប់ ហើយឥឡូវនេះគេមិនអាចធ្វើផែនទីដីបានទៀតទេ ប្រសិនបើគេសួរថា "ដីសហគមន៍នៅកន្លែងណា?" យើងមិនមានភស្តុតាងទេ ដោយសារតែយើងបាត់ព្រំកំណត់អស់ហើយ"*។ នេះជាឧបសគ្គដ៏ធំមួយសម្រាប់សហគមន៍និងជាការគំរាមកំហែងបន្ទាន់មួយទៅលើអត្តសញ្ញាណរបស់ពួកគេ ដូចដែលតំណាងសហគមន៍មួយរូបនៅភូមិចក់ចារបានលើកឡើងថា *"ប្រសិនបើយើងគ្មានដីទេ គេមិនអាចបានការទទួលស្គាល់ទេ ដូច្នេះតើយើងអាចនិយាយថាយើងជាជនជាតិព្នងទៀតយ៉ាងម៉េចទៅ?"* តំណាងម្នាក់មកពីរដ្ឋបាលព្រៃឈើដែលជាទីភ្នាក់ងាររដ្ឋាភិបាលមួយក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ដែលមានភារកិច្ចក្នុងការគ្រប់គ្រងព្រៃឈើនិងធនធានព្រៃឈើបានលើកយោបល់អំពីការកាប់ឈើខុសច្បាប់នៅភូមិចក់ចារ និងការខ្វះឆន្ទៈនយោបាយក្នុងការដោះស្រាយបញ្ហានេះថា [កាលពីមុន] *រដ្ឋាភិបាលមានការលើកឡើងខ្លាំងអំពីការកាប់ឈើខុសច្បាប់ និងមានការបង្ក្រាបជាច្រើនដើម្បីកាត់ទោសនិងបង្ក្រាបអ្នកកាប់ឈើខុសច្បាប់។ ប៉ុន្តែឥឡូវនេះរដ្ឋាភិបាលស្ងប់ស្ងាត់ណាស់។ ដូច្នេះ ការកាប់ឈើខុសច្បាប់កើតឡើងនៅស្ទើរគ្រប់ទីកន្លែង"*។

សហគមន៍បានបំពេញដំណាក់កាលដំបូងៗសព្វគ្រប់តាមដំណើរការទទួលបានកម្មសិទ្ធិដីសមូហភាពហើយ

[87] ក៏ត្រូវបានគេស្គាល់ឈ្មោះថា "ប៊ិញហ្វឿក១" "ក្រុមហ៊ុនចំការកៅស៊ូ ប៊ិញហ្វឿក១ក្រចេះលីមិតធិត" និងជាសាមញ្ញថា "ប៊ិញហ្វឿក"

តាមរយៈការទទួលបានការទទួលស្គាល់ជាផ្លូវការជាសហគមន៍ជានជាតិដើមភាគតិចក្នុងខែឧសភា ឆ្នាំ២០១០ និងតាមរយៈការចុះបញ្ជីជានីតិបុគ្គលក្នុងឆ្នាំ២០១៣។ ក្នុងខែធ្នូ ឆ្នាំ២០១៤ សហគមន៍បានដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ទន្ទឹមពេលគ្នានេះដែរ ការឈូសឆាយដីជាបន្តដោយក្រុមហ៊ុន ហើយការកាប់ឈើខុសច្បាប់ពាសពេញតំបន់ ជាការគំរាមកំហែងក្នុងការបំផ្លាញដីដែលនៅសល់ភាគច្រើន មុនពេលសហគមន៍អាចបំពេញដំណើរការនេះបានសព្វគ្រប់។

ក្រុមហ៊ុនប៊ិញហ្វឿក១ នេះ មិនត្រឹមតែរំលោភបំពានសិទ្ធិសហគមន៍ជនជាតិដើមភាគតិចនៅក្នុងករណីខាងលើនេះទេ ក្រុមហ៊ុនថែមទាំងបន្ថយលទ្ធភាពរបស់សហគមន៍ក្នុងការកំណត់ព្រំដីរបស់ពួកគេទៀតផង ហើយវាជាការរារាំងក្នុងដំណើរការទទួលបានកម្មសិទ្ធិដីសមូហភាព។ សកម្មភាពទាំងនេះ បង្ហាញអំពីបរាជ័យក្នុងការចាត់វិធានការចាំបាច់ដើម្បីជៀសវាងការរំលោភបំពានសិទ្ធិមនុស្ស ដែលផ្ទុយពីកាតព្វកិច្ចក្រោមគោលការណ៍ណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស។[88]

## ៤.៤ សហគមន៍

កត្តាផ្ទៃក្នុងនៅក្នុងសហគមន៍ខ្លួនឯងក៏អាចឧបសគ្គចំពោះដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពដែរ។ សហគមន៍ដែលរឹងមាំមានសិទ្ធិអំណាច និងមានការរួបរួមគ្នាហាក់ដូចជាមានលទ្ធភាពខ្ពស់ក្នុងការទាមទារសិទ្ធិនិងការពារដីរបស់ខ្លួន ។ ផ្ទុយមកវិញ កង្វះខាតចំណេះដឹង ទំនុកចិត្ត និងការរួបរួមគ្នាសុទ្ធតែអាចរួមចំណែកដល់ការបាត់បង់ដី ហើយនឹងមិនមានលទ្ធភាពក្នុងការទទួលបានបណ្ណកម្មសិទ្ធិដីសមូហភាពទេ ដូចករណីដែលបានកើតនៅភូមិចឹង។ ផ្នែកនេះរៀបរាប់អំពីចំណុចខ្សោយជាសក្តានុពលនៅក្នុងសហគមន៍ជនជាតិដើមភាគតិច ព្រមទាំងផ្តល់សំណូមពរមួយចំនួនដោយផ្អែកតាមការស្រាវជ្រាវនេះអំពីវិធីដើម្បីជម្រុះចោលទៅលើចំណុចខ្សោយទាំងអស់នេះ។

### ៤.៤.១ កង្វះខាតការយល់ដឹងអំពីសិទ្ធិ

បន្ថែមពីលើអ្វីដែលសមាជិកសហគមន៍បានបញ្ចេញឲ្យដឹង អំពីកង្វះខាតការយល់ដឹងអំពីភាពស្មុគស្មាញនៃដំណើរការទទួលបានបណ្ណកម្មសិទ្ធិដីសមូហភាពនេះ ជាទូទៅការស្រាវជ្រាវបានរកឃើញកាន់តែច្បាស់ថាមិនមែនសមាជិកសហគមន៍ទាំងអស់សុទ្ធតែបានយល់ដឹងអំពីសិទ្ធិរបស់ខ្លួនតាមផ្លូវច្បាប់ក្នុងការទទួលបានដីនោះទេ។

---

[88]ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា "គោលការណ៍ណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស" (ឆ្នាំ២០១១) http://bit.ly/18WbEUy




ជារួម កម្រិតនៃការយល់ដឹងក្នុងចំណោមសហគមន៍ អំពីច្បាប់ភូមិបាលមានមួយចំនួនប៉ុណ្ណោះគឺមាន ៦២% និងអំពីសិទ្ធិដីធ្លីមាន ៧៧%។ ទោះជាយ៉ាងណាក៏ដោយ សូមបញ្ជាក់ឲ្យច្បាស់ជាថ្មីម្តងទៀតថា សមាជិកសហគមន៍ដែលបានចូលរួមនៅក្នុងការស្រាវជ្រាវនេះ ដូចជាតំណាងសហគមន៍ សុទ្ធតែជាសមាជិកសហគមន៍ដែលភាគច្រើនសុទ្ធតែមានចំណេះដឹងនៅក្នុងវិស័យនេះ។ ដូច្នេះហើយ កម្រិតនៃការយល់ដឹងនេះមិនមែនជាតំណាងឲ្យសហគមន៍ទាំងអស់នោះទេ។ ជាងនេះទៀត អ្វីដែលសំខាន់នោះគឺក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិច សហគមន៍នៅភូមិចឹងគឺជាសហគមន៍ដែលមានចំណេះដឹងទូទៅអំពីច្បាប់ភូមិបាលនិងសិទ្ធិមនុស្សតិចតួចជាងគេ ហើយសហគមន៍នេះបានបាត់បង់ដីរបស់ខ្លួនទាំងស្រុងហើយ មានន័យថាសហគមន៍បាត់លទ្ធភាពទាំងស្រុងក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព។

**ករណីសិក្សា៖ ការបាត់បង់ដីសហគមន៍ជនជាតិដើមភាគតិចព្នងក្នុងភូមិចឹង**

**ស្ថានភាពកម្មសិទ្ធិដីសមូហភាព៖** មិនគ្រប់លក្ខណៈសម្រាប់កម្មសិទ្ធិដីសមូហភាពទេ ពីព្រោះគ្មានដីសហគមន៍នៅសល់សម្រាប់ចុះបញ្ជីទេ។



ដីនៅសល់តិចតួចក្នុងភូមិចឹង
រូបថត៖ ម.ស.ម.ក

ជនជាតិដើមភាគតិចព្នងបានរស់នៅនៅដីរបស់ខ្លួន ដែលមានទីតាំងនៅកន្លែងដែលបច្ចុប្បន្ននេះគេហៅថា ភូមិចឹង ឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ ចាប់តាំងពីដូនតារបស់ពួកគេមកម្ល៉េះ។ ក៏ប៉ុន្តែ ការចាប់ច្បាមយកដីដែលបានកើតឡើងក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ និងការដែលសហគមន៍មិនមានលទ្ធភាពការពារដីរបស់ខ្លួននោះបានធ្វើឲ្យសហគមន៍នេះនៅសល់ដីផ្ទាល់ខ្លួនតែបន្តិចបន្តួចតែប៉ុណ្ណោះ។ សហគមន៍បានឲ្យដឹងថា អ្នកមានអំណាចនិងមានខ្សែ ដោយរួមមានទាំងអធិការប៉ូលីសរង (ដែលសហគមន៍ស្គាល់ថាឈ្មោះ ម៉ៅ) និងមន្ត្រីជាន់ខ្ពស់ម្នាក់គឺឯកឧត្តម ឡេង អ៊ិន បានល្មើសក្នុងការចាប់ដីទាំងនេះ។ សហគមន៍បានដាក់ពាក្យបណ្ដឹងមួយចំនួនទៅអាជ្ញាធរដែរ ក៏ប៉ុន្តែ ពួកគេមិនបានទទួលអន្តរាគមន៍ចំពោះករណីនេះឡើយ។ ជាងនេះទៀត សមាជិកសហគមន៍បានប្រឈមនឹងការធ្វើទុក្ខបុកម្នេញពីប្រព័ន្ធតុលាការនិងប្រឈមនឹងការចាប់ខ្លួនដោយសារតែកិច្ចប្រឹងប្រែងការពារដី របស់ខ្លួនទៅវិញ។

អ្នកមកតាំងទីលំនៅថ្មីជាច្រើនក៏បានមករស់នៅលើដីទាំងនេះ ហើយគ្រួសារជនជាតិដើមភាគតិចមួយចំនួនបានលក់ដីផ្ទាល់ខ្លួនដែរ ហើយបានធ្វើឲ្យពួកគេក្លាយជាអ្នកគ្មានដី។ ជាងនេះទៀត ដីនេះបានទទួលរងការកាប់ឈើខុសច្បាប់យ៉ាងខ្លាំង។ ជាលទ្ធផលក្រោយពីការចាប់ដី ការលក់ផ្ទាល់ខ្លួន និងការកាប់ឈើខុសច្បាប់ សហគមន៍បានបាត់បង់ដីអារក្ស កន្លែងបញ្ចុះសព និងដីបម្រុងទុកសម្រាប់កសិកម្មវិលជុំ។

សហគមន៍ចង់បានការទទួលស្គាល់អត្តសញ្ញាណរបស់ខ្លួនជាផ្លូវការនិងចង់ឲ្យរដ្ឋាភិបាលផ្ដល់កម្មសិទ្ធិដីឯកជនឲ្យពួកគេ ដោយសារតែពួកគេមិនមាននៅសល់ដីសហគមន៍សម្រាប់ចុះបញ្ជីជាកម្មសិទ្ធិដីសមូហភាពទៀតទេ។ តំណាងសហគមន៍ម្នាក់បានលើកឡើងថា *"មិនមានដីតែសម្រាប់ជនជាតិដើមភាគតិចទៀតទេ ... អ្វីៗត្រូវបាត់បង់អស់ហើយ"*។

គួរឲ្យកត់សម្គាល់ផងដែរថាភូមិចឹងបានប្រឈមនឹងការដែលចំណូលស្រុក ជាងករណីផ្សេងទៀត ដោយសារតែភូមិនេះនៅជិតផ្លូវជាតិលេខ៧ ហើយមានទីប្រជុំជនក្នុងស្រុកស្នួល។ ប៉ុន្តែ បើទោះជាយើងមិនអាច

យើងនិយាយឲ្យពិតប្រាកដបានក៏ដោយ ក៏អាចនិយាយបានថាប្រសិនបើសហគមន៍បានទទួលព័ត៌មានច្រើនអំពីសិទ្ធិដីធ្លីរបស់ពួកគេ ពួកគេអាចនឹងត្រៀមខ្លួនក្នុងការតស៊ូមតិដើម្បីសិទ្ធិទាំងនោះនិងការពារដីរបស់ខ្លួន។ ទ្រឹស្តីនេះមានបង្ហាញជាភស្តុតាងដោយសមាជិកសហគមន៍នៅភូមិក្បាលរមាស ដែលគិតថាសមត្ថភាពរបស់ពួកគេក្នុងការការពារដីរបស់ខ្លួន គឺដោយសារតែចំណេះដឹងអំពីសិទ្ធិដីធ្លីដែលពួកគេបានទទួលតាមរយៈការបណ្តុះបណ្តាលរបស់អង្គការសង្គមស៊ីវិល។ ដូច្នេះហើយ ការបណ្តុះបណ្តាលនិងការផ្តល់ព័ត៌មានបន្ថែមអំពីសិទ្ធិដីធ្លីអាចនឹងធានាថាសហគមន៍ជនជាតិដើមភាគតិចបានត្រៀមខ្លួនបានល្អក្នុងការការពារដីរបស់ពួកគេ។

### ៤.៤. ២កង្វះខាតទំនុកចិត្ត

កង្វះខាតទំនុកចិត្ត ក៏ជាបញ្ហាប្រឈមមួយសម្រាប់សហគមន៍ក្នុងការប៉ុនប៉ងដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពផងដែរ។ ទំនុកចិត្តមានសារៈសំខាន់ណាស់ក្នុងការអនុវត្តយុទ្ធសាស្ត្រតស៊ូមតិដ៏រឹងមាំក្នុងដំណើរការចុះបញ្ជីនេះ ដោយស៊ូនឹងការធ្វើទុក្ខបុកម្នេញជាបន្តបន្ទាប់ពីអាជ្ញាធរ និងក្នុងការទប់ស្កាត់ការចាប់ដីនិងការបំភិតបំភ័យដោយក្រុមហ៊ុន។ ទំនុកចិត្តរបស់សហគមន៍អាចមានការលំបាកក្នុងការរក្សាឲ្យបានពេញលេញក្នុងរយៈពេលវែង។ តំណាងមកពីសង្គមអភិរក្សសត្វព្រៃនិងអង្គការមាតាធម្មជាតិបានលើកឡើងថា ដើម្បីជួយជ្រោមជ្រែងសហគមន៍ជនជាតិដើមភាគតិចឲ្យបានកាន់តែប្រសើរក្នុងដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះ អង្គការសង្គមស៊ីវិលគួរធ្វើទស្សនកិច្ចទៅសហគមន៍ជាប្រចាំ ដោយសារតែការធ្វើបែបនេះ មិនគ្រាន់តែជួយបង្កើនចំណេះដឹងអំពីសិទ្ធិដីធ្លីនិងដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពដែលជាការផ្តល់សិទ្ធិអំណាច ដល់ពួកគេប៉ុណ្ណោះ ថែមទាំងផ្តល់ដល់សហគមន៍ដែលកំពុងតស៊ូនោះនូវការបង្កើនទំនុកចិត្តដែលពួកគេកំពុងត្រូវការជាទីបំផុតនោះ។ តំណាងអភិរក្សសត្វព្រៃបានពន្យល់ថា *"យើងមិនអាចមកកន្លែងគាត់ឲ្យបានញឹកញាប់ទេ ដោយសារតែយើងធ្វើការនៅក្នុងភូមិជាង ២០ ដូច្នេះពួកគេបាត់បង់ទំនុកចិត្តដោយសារតែពួកគេមានអារម្មណ៍ថាមិនមានការយកចិត្តទុកដាក់ខ្លាំងពីបណ្តាអង្គការមិនមែនរដ្ឋាភិបាលទៅលើស្ថានភាពរបស់ពួកគេ ដូច្នេះពួកគេបាត់បង់ការប្តេជ្ញាចិត្ត។ អង្គការមិនមែនរដ្ឋាភិបាល គួរបង្កើនកិច្ចសហប្រតិបត្តិការនិងមកសួរសុខទុក្ខពួកគេឲ្យបានញឹកញាប់"។*

### ៤.៤.៣ កង្វះខាតឯកភាព

ទោះបីជាសមាជិកសហគមន៍ជនជាតិដើមភាគតិចជាច្រើនបង្ហាញអំពីការចង់បានប័ណ្ណកម្មសិទ្ធិដីសមូហភាពជាកម្មសិទ្ធិដីឯកជនក៏ដោយ ក៏ការស្រាវជ្រាវនេះបានបង្ហាញអំពីកង្វះឯកភាពក្នុងចំណោមសហគមន៍មួយចំនួន ដែលជាកត្តារាំងដល់ដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព។




មានតែភូមិចឹង ប៉ុណ្ណោះ ដែលតំណាងសហគមន៍ទាំងអស់បញ្ជាក់អំពីការប្រាថ្នាចង់បានកម្មសិទ្ធិដីឯកជន ក៏ប៉ុន្តែបានពន្យល់ថាពួកគេមិនមានដីសហគមន៍នៅសល់សម្រាប់ចុះបញ្ជីតាមដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពទេ ហេតុដូច្នេះហើយពួកគេគ្មានជម្រើសអ្វីក្រៅតែពីព្យាយាមឲ្យបានកម្មសិទ្ធិដីឯកជនដើម្បីការពារដីដ៏តិចតួចដែលនៅសល់ក្រោយពីត្រូវបានគេចាប់យកអស់នោះ។ តាមការបញ្ជាក់ដោយអនាមិកថា ប្រសិនបើមានដីនិងព្រៃនៅសល់នោះ សហគមន៍នឹងចង់បានកម្មសិទ្ធិដីសមូហភាពដើម្បីការពារដីនិងអត្តសញ្ញាណរបស់ពួកគេហើយ។ កង្វះឯកភាពក្នុងចំណោមសហគមន៍នៅភូមិចឹងត្រូវបានរកឃើញថាជាមូលហេតុចម្បងដែលធ្វើឲ្យសហគមន៍មិនមានលទ្ធភាពការពារដីរបស់ខ្លួនពីការចាប់ច្បាមយកដីពីអ្នកចំណូលថ្មី។ បើយោងតាមតំណាងសហគមន៍ សមាជិកសហគមន៍មួយចំនួនបានជំទាស់នឹងដំបូន្មានរបស់មេដឹកនាំ ដែលបានជំរុញពួកគេកុំឲ្យលក់ដីរបស់ខ្លួនដើម្បីរក្សាអត្តសញ្ញាណរបស់ខ្លួន។ ផ្ទុយទៅវិញ សមាជិកសហគមន៍បានលក់ដីរបស់ខ្លួនទៅឲ្យអ្នកចំណូលស្រុកថ្មី ដើម្បីដោះបន្ទុកហិរញ្ញវត្ថុដែលទង្វើនេះជាការរួមចំណែកធ្វើឲ្យបាត់បង់ដីសហគមន៍។

ក្រៅពីភូមិចឹង នៅភូមិចក់ចារ តំណាងសហគមន៍ម្នាក់បានថ្លែងពីការប្រាថ្នាចង់បានកម្មសិទ្ធិដីឯកជនដោយគាត់បានពន្យល់ថា គាត់នឹងអាចប្រើប័ណ្ណកម្មសិទ្ធិនោះទៅខ្ចីលុយពីធនាគារបាន។ ជាថ្មីម្តងទៀត វាជាការសំខាន់ក្នុងការកត់សម្គាល់ថាសមាជិកសហគមន៍ភាគច្រើនដែលបានចូលរួមនៅក្នុងការសម្ភាសនេះ ជាតំណាងសហគមន៍ដែលមានការប្តេជ្ញាចិត្តក្នុងការការពារដីសហគមន៍របស់ពួកគេ ដូច្នេះឆន្ទៈក្នុងការចង់បានកម្មសិទ្ធិដីសមូហភាពមិនឆ្លុះបញ្ចាំងអំពីសេចក្តីប្រាថ្នារបស់បុគ្គលគ្រប់រូបនៅក្នុងសហគមន៍របស់ពួកគេទេ។ ឧទាហរណ៍ នៅស្ទឹងអារ៉ែង តំណាងសហគមន៍ទាំងអស់ដែលចូលរួមក្នុងការស្រាវជ្រាវនេះ សម្តែងអំពីការប្រាថ្នាចង់បាន ប័ណ្ណកម្មសិទ្ធិដីសមូហភាព ប៉ុន្តែពួកគេក៏ទទួលស្គាល់ដែរថា ភូមិមួយក្នុងចំណោមភូមិរងផលប៉ះពាល់ទាំងប្រាំបី (ភូមិប្រឡាយ) មានសមាជិកសហគមន៍ដែលចង់បានកម្មសិទ្ធិដីឯកជនដែរ។ ប៉ុន្តែ តំណាងសហគមន៍បាន

បញ្ជាក់ថា មនុស្សភាគច្រើនក្នុងសហគមន៍នៅតែប្តេជ្ញាចិត្តចង់ទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព ដោយបានថ្លែងថា *"ប្រសិនបើយើងទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព អ្វីៗទាំងអស់ទាំងអត្តសញ្ញាណនិងវប្បធម៌របស់យើងអាចបន្ត ហើយគ្មានក្រុមហ៊ុនណាឬអ្នកមានអំណាចអាចលួចដីរបស់យើងបានឡើយ"*។

កង្វះឯកភាព ឬមិនមានភាពច្បាស់លាស់លើប្រភេទចុះបញ្ជីដី ប្រជាសហគមន៍អាចជាអ្នករួមចំណែកចំពោះការអូសបន្លាយពេលក្នុងដំណើរការនេះ។ យោងតាមក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ពួកគេបានអង្កេតថា ក្នុងអំឡុងពេលនៃដំណើរការចុះបញ្ជីដី ប្រជាសហគមន៍មួយចំនួនបានសម្រេចចិត្តឈប់ចូលរួមទាមទារប័ណ្ណកម្មសិទ្ធិដីសមូហភាពហើយត្រឡប់មកជាស្នើសុំប័ណ្ណកម្មសិទ្ធិឯកជនជំនួសវិញ។ ការបន្លាយពេលក្នុងដំណើរការនេះចំណាយពេលយូរ និងធនធានច្រើន ព្រោះក្រសួងរៀបចំដែនដី នគរូបនីយកម្មត្រូវត្រឡប់ទៅកាន់សហគមន៍ និងធ្វើការវាយតម្លៃដីនោះជាថ្មីឡើងវិញ។

បន្ថែមពីនេះ បើទោះបីជាការសម្រេចរបស់គ្រួសារមួយក្នុងការទទួលយកកម្មសិទ្ធិដីឯកជនមិនបានដកហូតសិទ្ធិរបស់អ្នកផ្សេងទៀតក្នុងសហគមន៍ក្នុងការទទួលបានកម្មសិទ្ធិដីសមូហភាពក៏ដោយ ក៏វាមានឥទ្ធិពលក្នុងការធ្វើឲ្យចំនួនប្រជាជននិងសាមគ្គីភាពមានសភាពរួមតូចផងដែរ។ ជាងនេះទៀត អ្នកដែលមានកម្មសិទ្ធិដីឯកជនត្រូវបានលក់ដីដែលពីមុនជាដីជនជាតិដើមភាគតិចទៅឲ្យអ្នកខាងក្រៅ ដែលនេះរឹតតែអាចមានសិទ្ធិដាក់បន្ទុកបន្ថែមទៀតដល់សហគមន៍ទាំងមូលដែលនៅប្តេជ្ញាចិត្តចង់អភិរក្សដីសមូហភាពរបស់ខ្លួន។[89]

ជាការពិត វាមានផលប្រយោជន៍សម្រាប់គ្រួសារជនជាតិដើមភាគតិចដែលបានទទួលប័ណ្ណកម្មសិទ្ធិដីឯកជនដោយស្របច្បាប់ព្រោះវាបានផ្តល់នូវការការពារភ្លាមៗទៅលើដីរបស់ពួកគេ ហើយវាអនុញ្ញាតឲ្យម្ចាស់អាចប្រើវាជារបស់បញ្ចាំក្នុងការខ្ចីលុយពីធនាគារ (ដែលផ្ទុយពីប័ណ្ណកម្មសិទ្ធិដីសមូហភាពដែលតាមច្បាប់មិនអាចយកមកប្រើប្រាស់សម្រាប់គោលបំណងបែបនេះឡើយ)។ ក៏ប៉ុន្តែ ជាញឹកញាប់គ្រួសារជនជាតិដើមភាគតិចសម្រេចចិត្តទទួលយកកម្មសិទ្ធិដីឯកជនក្រោមសម្ពាធពីអាជ្ញាធរមូលដ្ឋានឬយុវជនស្ម័គ្រចិត្ត ដោយមិនបានទទួលព័ត៌មានពេញលេញអំពីផលវិបាកឡើយ និងនៅចំពោះមុខនៃការទន្ទ្រានកាន់តែខ្លាំងឡើងទៅលើដីរបស់ពួកគេ។ នៅក្នុងបរិបទនេះ វាអាចជាការសមស្របក្នុងការសន្និដ្ឋានថា គ្រួសារទាំងនោះជាច្រើនបានព្រមទទួលយកកម្មសិទ្ធិដីឯកជនក្រោមការគំរាមកំហែង។ ក្រោមការបង្ខំបែបនេះ វាជាការគួរឲ្យកត់សម្គាល់ថាកម្មសិទ្ធិដីឯកជនអាចបញ្ចូលទៅក្នុងប័ណ្ណកម្មសិទ្ធិដីសមូហភាពបាន។ អនុក្រឹត្យ ៨៣ ពិតជាអនុញ្ញាតិឲ្យជនជាតិដើមភាគតិចដែលកាន់កាប់ប័ណ្ណកម្មសិទ្ធិដីឯកជនឲ្យប្តូរដីដែលកាន់កាប់ដោយឯកជនឲ្យបញ្ចូលទៅជាកម្មសិទ្ធិសហគមន៍បាន។[90] ប៉ុន្តែ វាជាដំណើរលំបាកនិងមានភាពស្មុគ្រស្មាញដែលពឹងផ្អែកខ្លាំងទៅលើឆន្ទៈរបស់អាជ្ញាធរមានសមត្ថកិច្ច។ ការបញ្ចូលដីមួយដុំចូលជាដីសហគមន៍ជនជាតិដើមភាគតិច តំណាងសហគមន៍ត្រូវតែស្នើសុំដល់រ

[89] *ដដែល*

[90] អនុក្រឹត្យលេខ ៨៣ មាត្រា១៣

ដ្ឋបាលសុរិយោដីឲ្យចុះបញ្ជីទៅលើរាល់ការផ្លាស់ប្តូរជាបន្តបន្ទាប់ទាំងអស់។[91] កង្វះជំនួយពីអាជ្ញាធរច្រើនតែជាឧបសគ្គចំពោះការចុះបញ្ជីកម្មសិទ្ធិដីសមូហភាពតាំងពីដើមដំបូង បន្ទាប់មកការបញ្ចូលឡើងវិញពេលក្រោយសម្រាប់កម្មសិទ្ធិដីឯកជន ហាក់ដូចជាគ្រាន់តែជាគំនិតសុទិដ្ឋិនិយមប៉ុណ្ណោះ។

ជាងនេះទៀត ការបាត់បង់ជំនឿចិត្តទៅលើរដ្ឋាភិបាលក្នុងការធានាឲ្យមានការការពារដល់សិទ្ធិដីធ្លីរបស់ពួកគេបាននាំឲ្យសមាជិកសហគមន៍ស្វែងរកដំណោះស្រាយរយៈពេលខ្លី ឧទាហរណ៍ ការទទួលយកកម្មសិទ្ធិដីឯកជនដើម្បីឲ្យពួកគេអាចលក់ដើម្បីសម្រាលការលំបាកផ្នែកហិរញ្ញវត្ថុ ជាជាងការអនុវត្តតាមប្រពៃណីជនជាតិដើមភាគតិច។[92] នៅពេលដែលសមាជិកសហគមន៍បានលក់ដីរបស់ខ្លួនហើយ ពួកគេមិនអាចចូលរួមឡើងវិញជាមួយសហគមន៍ជនជាតិដើមភាគតិចរបស់ពួកគេទៀតទេ។ នេះជាការពិតមួយសម្រាប់គ្រួសារសហគមន៍ជាច្រើននៅក្នុងឃុំប៊ូស្រាដែលបានព្យាយាមក្នុងការចូលរួមឡើងវិញជាមួយសហគមន៍ក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនោះ។ ក៏ប៉ុន្តែ សហគមន៍ថ្លែងថាពួកគេនឹងមិនទទួលសមាជិកទាំងនេះត្រឡប់ចូលមកក្នុងសហគមន៍វិញទេ ដូចមានចែងក្នុងបទបញ្ញាផ្ទៃក្នុងរបស់ពួកគេ។

ខណៈដែលការកើនឡើងនូវចំណេះដឹងនិងទំនុកចិត្តពិតជាបានពង្រឹងសមត្ថភាពរបស់សហគមន៍នានាក្នុងការការពារសិទ្ធិរបស់ពួកគេក៏ដោយ ក៏ការគាបសង្កត់ជាច្រើនទៅលើសហគមន៍ជនជាតិដើមភាគតិចបានបង្ហាញថាឯកភាពរបស់សហគមន៍ក៏ប្រហែលជាមានសារៈសំខាន់ដូចគ្នាផងដែរ។ រឿងនេះជាការពិត រហូតដល់តំណាងសហគមន៍ម្នាក់នៅភូមិចឹងបានសំណូមពរដល់អង្គការមិនមែនរដ្ឋាភិបាលទាំងឡាយថា *"សូមរៀបចំវគ្គបណ្តុះបណ្តាលអំពីរបៀបកែលម្អសាមគ្គីភាពរបស់សហគមន៍"*។

## ៤.៥ អង្គការមិនមែនរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍

ជាការពិតណាស់ សហគមន៍ជនជាតិដើមភាគតិចត្រូវការជំនួយពីខាងក្រៅដើម្បីចុះបញ្ជីដីសហគមន៍របស់ពួកគេ ដោយសារតែបញ្ហាជាច្រើនដែលពួកគេប្រឈមចំពោះដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពដែលមានស្រាប់។ ក៏ប៉ុន្តែ នៅពេលដែលអង្គការមិនមែនរដ្ឋាភិបាលនិងស្ថាប័នផ្សេងៗទៀតដែលធ្វើការគាំទ្រកម្មសិទ្ធិដីសហគមន៍សម្រាប់សហគមន៍ជនជាតិដើមភាគតិចមានចេតនាល្អក៏ដោយ ក៏ពួកគេអាចមានឥទ្ធិពលបណ្តាលឲ្យមានឧបសគ្គដោយអចេតនា និងអាចបង្កផលលំបាកដល់អ្នកដែលពួកគេមានបំណងចង់ជួយថែមទៀតផង។ អង្គការសង្គមស៊ីវិលដែលត្រូវបានសម្ភាសន៍ក្នុងការស្រាវជ្រាវនេះអាចជួយបំភ្លឺចំពោះបញ្ហានេះ។ បញ្ហាចម្បងដែលត្រូវបានលើកឡើងនេះគឺការប្រកួតប្រជែង ជាជាងការសហការក្នុងចំណោមអង្គការទាំងនោះ។ តំណាងម្នាក់ពីសមាគមអាដហុក បានទទួលស្គាល់ដោយត្រង់ថា *"យើងតែងតែរិះគន់ចំណុចខ្សោយរបស់រដ្ឋាភិបាល ប៉ុន្តែយើងកម្ររិះគន់ខ្លួនឯងណាស់ ដែលនេះជាការខ្វះចន្លោះរបស់សង្គមស៊ីវិល... ឧបសគ្គមួយក្នុង*

---

[91] *ដដែល* មាត្រា១៤

[92] វេទិកាអង្គការមិនមែនរដ្ឋាភិបាលនៃកម្ពុជា "ជនជាតិដើមភាគតិចនៅកម្ពុជា" (ខែមេសា ឆ្នាំ២០០៦) http://bit.ly/21tZ1rr

*ចំណោមឧបសគ្គចម្បងៗគឺការខ្វះចន្លោះក្នុងកិច្ចសហប្រតិបត្តិការរវាងអង្គការសង្គមស៊ីវិល។* តំណាងម្នាក់មកពីមជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍បញ្ជាក់បន្ថែមថាកង្វះកិច្ចសហប្រតិបត្តិការគឺជាបញ្ហា *"ខ្ញុំបានសង្កេតឃើញថា អង្គការមួយចំនួនប្រកួតប្រជែងជាមួយគ្នា ឧទាហរណ៍ ពួកគេនិយាយថា "ទោះជាគម្រោងរបស់ខ្ញុំ" គឺថាពួកគេមិនមានសាមគ្គីភាពនិងមិនសហការល្អដើម្បីជំរុញដល់ដំណើរការចុះបញ្ជីដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពទេ។* កង្វះខាតកិច្ចសហប្រតិបត្តិការនេះត្រូវបានរំលេចឡើងជាពិសេសទៅលើអង្គការមួយចំនួនដែលកំពុងធ្វើការក្នុងឃុំប៊ូស្រាដែលសហគមន៍មិនទាន់បានទទួលប័ណ្ណកម្មសិទ្ធិដីសមូហភាពនៅឡើយទេ ទោះបីជាមានអង្គការជាច្រើនកំពុងធ្វើការលើករណីនេះក៏ដោយ ៖

**ករណីសិក្សា៖ ជនជាតិដើមភាគតិចព្នងក្នុងឃុំប៊ូស្រា[93] និងកិច្ចសហការរបស់អង្គការមិនមែនរដ្ឋាភិបាល**

**ស្ថានភាពប័ណ្ណកម្មសិទ្ធិដីសមូហភាព៖** បានទទួលការទទួលស្គាល់អត្តសញ្ញាណផ្លូវការក្នុងឆ្នាំ២០១១ បានចុះបញ្ជីជានីតិបុគ្គលក្នុងខែឧសភា ឆ្នាំ២០១២។ បានដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពក្នុងឆ្នាំ២០១២ ប៉ុន្តែមិនទាន់បានទទួលការឆ្លើយតបនៅឡើយទេ

សហគមន៍ជនជាតិព្នងក្នុងឃុំប៊ូស្រា ស្រុកពេជ្រាដា បាននិយាយថាចំការកៅស៊ូដែលមានក្រុមហ៊ុនសុកហ៊ីនខេស៊ីឌី ជាម្ចាស់បានទន្ទ្រានចូលក្នុងដីដែលពួកគេពឹងផ្អែកការរស់រានមានជីវិតទៅលើដីនោះ ហើយវាបានប៉ះពាល់ដល់គ្រួសារចំនួន ៧៨៨។ ប្រជាជនដែលទទួលរងការប៉ះពាល់ភាគច្រើនគឺជនជាតិដើមភាគតិចព្នង ដែលមានចំណងយ៉ាងខ្លាំងទៅនឹងដី ដែលពួកគេបានរស់នៅច្រើនជំនាន់មកហើយ។

ក្រុមហ៊ុនសុកហ៊ីនខេស៊ីឌី រួមជាមួយនឹងក្រុមហ៊ុនវ៉ាណាស៊ីនិងសេធីកូឡា ប្រតិបត្តិការទៅលើសម្បទានដីសេដ្ឋកិច្ចចំនួនពីរនៅក្នុងឃុំប៊ូស្រា។ មកដល់ឆ្នាំ២០១២ សម្បទានដីសេដ្ឋកិច្ចមានចំនួនសរុប ៦.៩៧៨ ហិកតា ដែលក្នុងនោះ គេដាំកៅស៊ូចំនួន ៤.០៦២ ហិកតា។ ក្រុមហ៊ុនសុកហ៊ីនខេស៊ីឌី បានចាប់ផ្តើមឈូសឆាយដីធ្វើចំការនេះក្នុងខែមេសាឆ្នាំ២០០៨ មុនពេលបញ្ចប់ការវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គមឲ្យបានជាក់លាក់ ឬសម្រេចបញ្ចប់ទៅលើសំណងនានា។ ទោះបីជាមានការដាក់ពាក្យបណ្តឹងច្រើននិងការតវ៉ាកំពុងកើតមានជាបន្តបន្ទាប់ក៏ដោយ ក៏ក្រុមហ៊ុនសុកហ៊ីនខេស៊ីឌី នៅតែបន្តការឈូសឆាយដីនិងបានបំផ្លាញដីដែលបានដាំដុះរួចហើយ ដីបម្រុងទុកសម្រាប់ធ្វើកសិកម្មវិលជុំ ទីតាំងបញ្ចុះសពតាមប្រពៃណីនិងព្រៃអារក្ស ដោយបង្កឲ្យមានការប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរទៅលើជីវភាពសេដ្ឋកិច្ចនិងព្រលឹងរបស់អ្នកភូមិ។ រហូតមកដល់ពេលនេះសំណងដែលផ្តល់ដល់អ្នកភូមិ គឺមិនគ្រប់គ្រាន់ទាល់តែសោះ។

[93] សម្រាប់ព័ត៌មានបន្ថែមលើករណីនេះ សូមអាន៖ម.ស.ម.ក "ឃុំប៊ូស្រា ខេត្តមណ្ឌលគីរី" (ប្រវត្តិសកម្មជនដីធ្លី) http://bit.ly/1Q5PldR



ចំការកៅស៊ូនៅឃុំប៊ូស្រា របស់ក្រុមហ៊ុនសុកហ៊្វីនខេស៊ីឌី
រូបថត៖ ម.ស.ម.ក

បន្ថែមពីលើសម្ពាធពីចំការរបស់ក្រុមហ៊ុនសុកហ៊្វីនខេស៊ីឌីមកលើសហគមន៍នោះសម្បទានដីសង្គមកិច្ច ដែលនៅជិត (ដែលគេជឿថាត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១០ ឬ២០១១) ជាយភូមិឡាំមេះក៏កំពុងបណ្តាលឲ្យមានភាពតានតឹងយ៉ាងច្រើនដែរ។ សម្បទានដីសង្គមកិច្ចបានទន្ទ្រានលើទីតាំងបញ្ចុះសព ព្រៃអារក្ស ដីកសិកម្មវិលជុំ និងដីលំនៅដ្ឋានដែលបានធ្វើឲ្យជនជាតិដើមភាគតិច ១០០ គ្រួសារត្រូវផ្លាស់ប្តូរលំនៅដ្ឋាន បន្ថែមពីលើការហូរចូលជាច្រើនពីអ្នកចំណូលស្រុកក្នុងតំបន់នេះ។

សហគមន៍ជនជាតិដើមភាគតិចក្នុងឃុំប៊ូស្រាបានចូលរួមនៅក្នុងដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពអស់រយៈពេលជាច្រើនឆ្នាំមកហើយ ហើយអង្គការសង្គមស៊ីវិលមួយចំនួនបានកំពុងជួយដល់ពួកគាត់នៅក្នុងដំណើរការនេះ។ ក្នុងឆ្នាំ២០១១ សហគមន៍មូលដ្ឋានទទួលបានការទទួលស្គាល់អត្តសញ្ញាណជាផ្លូវការពីក្រសួងអភិវឌ្ឍន៍ជនបទ ហើយក្នុងខែឧសភា ឆ្នាំ២០១២ ក្រសួងមហាផ្ទៃបានចុះបញ្ជីពួកគេជានីតិបុគ្គល។ ក្នុងឆ្នាំ២០១២ ដែរពួកគេបានដាក់ពាក្យសុំចុះបញ្ជីជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ប៉ុន្តែរហូតមកដល់ពេលនេះ ពួកគេកំពុងតែរងចាំការឆ្លើយតប។ ការដែលសម្បទានដីសង្គមកិច្ច ទន្ទ្រានចូលដីដែលសហគមន៍បានបោះព្រំដីសម្រាប់ចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីសមូហភាព ដូចដែលសហគមន៍បានរកឃើញថាជាឧបសគ្គចម្បងមួយចំពោះដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព។ ក៏ប៉ុន្តែ កិច្ចសហប្រតិបត្តិល្អរវាងអង្គការសង្គមស៊ីវិលដែលកំពុងធ្វើការលើករណីនេះ អាចនឹងផ្តល់ប្រយោជន៍យ៉ាងខ្លាំងដល់សហគមន៍នៅក្នុងដំណើរការនេះ។ សហគមន៍អះអាងថា កាលពីចាប់ផ្តើមដំណើរការនេះដំបូង អង្គការដែលគាំទ្រពួកគេ *"មានភាពសកម្មខ្លាំងមែនទែន"* ប៉ុន្តែថ្មីៗនេះ ពួកគេ *"មិនសូវសកម្មទេ"*។ សហគមន៍នៅតែត្រូវការជំនួយដើម្បីសម្រេចការធ្វើផែនទីមេ។

សមាគមអាដហុក បានលើកឡើងអំពីតម្រូវការឲ្យអង្គការមិនមែនរដ្ឋាភិបាលនៅឃុំប៊ូស្រា *"រៀបចំកិច្ចប្រជុំជាមួយគ្នានិងបែងចែកការទទួលខុសត្រូវ"*។ បើយោងតាមមជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍ កិច្ចសហប្រតិបត្តិការបែបនេះ អាចសម្រេចបានដោយងាយស្រួល *"អង្គការគួររៀបចំកិច្ចប្រជុំជាមួយគ្នា ដើម្បីស្វែងរកដំណោះស្រាយនិងដើម្បីបែងចែកការទទួលខុសត្រូវ ឧទាហរណ៍តើអង្គការណាគួរជួយលើដំណើរការទទួលបានការទទួលស្គាល់អត្តសញ្ញាណជាដើម? តើអង្គការណាមានអ្នកឯកទេសធ្វើផែនទី? តើអង្គការណាអាចផ្តល់ជំនួយផ្នែកច្បាប់?"* គាត់បានបន្ថែមទៀតថា *"យើងគួរមានវេទិការួមគ្នារវាងអង្គការផ្សេងៗ ដើម្បីឲ្យយើងអាចដំណើរការចុះបញ្ជីជាមួយគ្នាបាន"*។ ដូចដែលបានរកឃើញពីមុនរួចហើយថាការចំណាយខ្ពស់ពាក់ព័ន្ធនឹងដំណើរការចុះបញ្ជីនេះអាចជាបន្ទុកសម្រាប់អង្គការនានាដែលកំពុងជួយដល់សហគមន៍ជនជាតិដើមភាគតិចទាំងនេះ។ តាមរយៈកិច្ចសហប្រតិបត្តិការជាមួយគ្នា អង្គការទាំងឡាយអាចជំនះលើបញ្ហាហិរញ្ញវត្ថុបាន ដូច្នេះវានឹងជានាការជួយជ្រោមជ្រែងដល់សហគមន៍ជនជាតិដើមភាគតិចនឹងមិនកាត់ផ្តាច់ភ្លាមៗទេ នៅពេលអស់មូលនិធិនោះ។

សមាជិកសហគមន៍ដែលទទួលរងការប៉ះពាល់ចង់ឲ្យរដ្ឋាភិបាលលុបចោលសម្បទានដីសង្គមកិច្ច និងធានាថាសម្បទានដីសេដ្ឋកិច្ចមិនទន្ទ្រានចូលដីរបស់ពួកគេ។ បន្ថែមពីលើនេះ ពួកគេសំណូមពរឲ្យអង្គការមិនមែនរដ្ឋាភិបាល *"ពន្លឿនដំណើរការសម្រាប់ចុះបញ្ជីសម្រាប់ប័ណ្ណកម្មសិទ្ធិដីសមូហភាព បើមិនដូច្នេះទេ យើងនឹងគ្មានដីសម្រាប់ការពារទៀតទេ"*។

កង្វះកិច្ចសហប្រតិបត្តិការរវាងអង្គការនានា ក៏ត្រូវបានសហគមន៍មួយចំនួនលើកឡើងដែរ។ នៅភូមិក្បាលរមាស សហគមន៍បានអំពាវនាវឲ្យអង្គការដែលកំពុងជួយពួកគាត់ឲ្យមានកិច្ចសហការកាន់តែខ្លាំង ដោយគាត់បានថ្លែងថា *"យើងចង់ឲ្យអង្គការសហការជាមួយគ្នា មកភូមិដើម្បីគាំទ្រពួកយើងក្នុងការតស៊ូមតិ និងក្នុងដំណើរការចុះបញ្ជី"*។ វាជាការសំខាន់ណាស់ដែលអង្គការត្រូវចាំថា សូម្បីតែនៅពេលដែលករណីមួយដែលហាក់ដូចជាមានការគាំទ្រល្អពីអង្គការមិនមែនរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ជាចំនួនច្រើនហើយក៏ដោយក្តី ក៏វានៅតែមានកង្វះខាតក្នុងការសម្របសម្រួលនិងការគាំទ្រដើម្បីឲ្យកាន់តែមានភាពប្រសើរជាងនេះផងដែរ។

## ៥. មេរៀនថ្នាក់តំបន់

ផលប៉ះពាល់ពីការចាប់ច្បាមយកដីទៅលើប្រពៃណីនិងវប្បធម៌របស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជាគឺមានសភាពធ្ងន់ធ្ងរនិងច្រើនតែមិនអាចស្តារត្រឡប់ក្រោយវិញបាន។ នៅពេលដែលសហគមន៍ជនជាតិដើមភាគតិចមិនអាចពឹងផ្អែកទៅលើដីនិងសកម្មភាពប្រពៃណីដើម្បីបន្តនិរន្តរភាពរបស់ពួកគេទេ ពួកគេសឹងតែមិនមានជម្រើសអ្វីក្រៅពីប្រើកម្លាំងដើម្បីប្រាក់ឈ្នួលមកចិញ្ចឹមជីវិតឲ្យរស់។ ឧទាហរណ៍ នៅភូមិចឹងដែលបាត់បង់ដីស្ទើរតែទាំងអស់ទៅហើយនោះ ឥឡូវនេះសមាជិកសហគមន៍ជាច្រើនមានជម្រើសតិចតួចបំផុត ហើយត្រូវធ្វើការឲ្យអ្នកមកនៅថ្មីនិងអ្នកកាប់ឈើខុសច្បាប់។ ស្រដៀងគ្នានេះដែរ នៅក្នុងភូមិចក់ចារនិងឃុំប៊ូស្រា ដោយសារតែការបាត់បង់ដីធ្លី សមាជិកសហគមន៍មួយចំនួនត្រូវតែបង្ខំចិត្តទទួលយកការងារជាមួយក្រុមហ៊ុនដែលមានការពាក់ព័ន្ធនឹងវិវាទដីធ្លី។ ការងារយកប្រាក់ឈ្នួលនេះ មិនត្រឹមតែជាការបង្ហាញអំពីភាពបែកបាក់ក្នុងវប្បធម៌ប្រពៃណីរបស់ជនជាតិដើមភាគតិចប៉ុណ្ណោះទេ ហើយដោយសារតែកង្វះការអប់រំ ជនជាតិដើមភាគតិចច្រើនត្រូវជាប់ធ្វើការងារក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធដោយមិនអាចគេចរួចឡើយ។ ប្រការនេះធ្វើឲ្យពួកគេស្ថិតក្នុងភាពងាយរងគ្រោះកាន់តែខ្លាំងពីការបំពានសិទ្ធិមនុស្សមួយចំនួនបន្ថែមទៀត។ លើសពីនេះ ដោយសារតែអត្តសញ្ញាណរបស់ពួកគេមានចំណងជិតស្និទ្ធទៅនឹងដីធ្លីនោះ ទីបំផុតការបាត់បង់ដីធ្លីនឹងនាំទៅដល់ការបាត់បង់អត្តសញ្ញាណក្នុងចំណោមពួកគេ។ ដូចដែលតំណាងសហគមន៍ម្នាក់នៅក្នុងភូមិក្បាលរមាសមានប្រសាសន៍ថា *"ប្រសិនបើយើងផ្លាស់ទៅរស់នៅទីតាំងថ្មី យើងនឹងបាត់បង់ដីធ្លីរបស់យើង ហើយគេនឹងឲ្យកម្មសិទ្ធិដីឯកជនដល់យើង។ វាមិនមែនជាវប្បធម៌របស់យើងទេ។ ប្រសិនបើយើងបាត់បង់អ្វីៗគ្រប់យ៉ាង អត្តសញ្ញាណរបស់យើងនឹងបាត់បង់ដែរ យើងនឹងមិនមែនជាជនជាតិដើមពួងទៀតទេ យើងនឹងក្លាយជាពលរដ្ឋខ្មែរទូទៅ"*។

ប្រទេសជាច្រើននៅជុំវិញពិភពលោក ដោយរាប់ទាំងប្រទេសមួយចំនួននៅក្នុងតំបន់អាស៊ីខាងត្បូងដែរ បានចាប់ផ្តើមអនុវត្តវិធានការកាត់បន្ថយការប៉ះពាល់បែបនេះ និងការពារសិទ្ធិជនជាតិដើមភាគតិច។ ប្រទេសកម្ពុជាអាចទាញយកបទពិសោធន៍របស់ប្រទេសនៅក្នុងតំបន់ដែលបានចាត់វិធានការដើម្បីធានាឲ្យមានការការពារជនជាតិដើមភាគតិច។ ឧទាហរណ៍ ប្រទេសហ្វីលីពីនគឺជាប្រទេសមួយក្នុងចំណោមប្រទេសតិចតួច និងជាប្រទេសទីមួយនៅអាស៊ី ដែលបានបង្កើតប្រព័ន្ធច្បាប់ច្បាស់លាស់មួយសម្រាប់ការពារសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច តាមរយៈការទទួលស្គាល់ជនដែលមានសម្លេងភាគតិចក្នុងប្រវត្តិសាស្ត្រ និងតាមរយៈការផ្តល់នូវលទ្ធភាពទទួលបានយន្តការសំណង។

**ករណីសិក្សា៖ ប្រទេសហ្វីលីពីននិងច្បាប់សិទ្ធិជនជាតិដើមភាគតិច**

មានការប៉ាន់ប្រមាណថាប្រជាជនហ្វីលីពីនចន្លោះពី១០ ទៅ ២០% នៃប្រជាជនសរុប១០២.៩លាននាក់ ជាជនជាតិដើមភាគតិច។[94] តាមរយៈការរស់នៅជាទូទៅនៅតាមទីតាំងភូមិសាស្ត្រដាច់ដោយឡែកពីគ្នា ប៉ុន្តែជាតំបន់ដែលសម្បូរធនធាននោះ សហគមន៍ជនជាតិដើមភាគតិចក្នុងប្រទេសហ្វីលីពីនបន្តស្ថិតក្នុងសភាពងាយរងគ្រោះដោយសារការចាប់ច្បាមដីនិងគម្រោងអភិវឌ្ឍន៍ដែលមានការរំលោភសិទ្ធិមនុស្សរបស់ពួកគេ។

ក្រោមអាណានិគមរបស់សហរដ្ឋអាមេរិចនិងអេស្ប៉ាញ ការអនុម័តច្បាប់សម័យអាណានិគមផ្សេងៗគ្នានៅក្នុងប្រទេសហ្វីលីពីនបានធ្វើឲ្យមានការប៉ះពាល់ដែលយាយីដល់ជនជាតិដើមភាគតិចនិងដីធ្លីរបស់ពួកគេ។[95] នៅសម័យក្រោយអាណានិគម រដ្ឋាភិបាលហ្វីលីពីនបានណែនាំឲ្យមានច្បាប់ដែលទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការទទួលបានដីធ្លីដែលពួកគេកាន់កាប់ ហើយរដ្ឋាភិបាលបានណែនាំឲ្យមានច្បាប់សម្រាប់អ្វីដែលផ្ទុយពីនេះដែរ។ ការណែនាំឲ្យមានច្បាប់សាធារណរដ្ឋលេខ ៨៣៧០ ដែលត្រូវគេស្គាល់ថាជាច្បាប់ស្តីពីសិទ្ធិជនជាតិដើមភាគតិចក្នុងឆ្នាំ១៩៩៧ ត្រូវបានគេចាត់ទុកថាជាច្បាប់ដ៏មានសារៈសំខាន់បំផុតមួយ ដែលទទួលស្គាល់ការកាន់កាប់ដីសហគមន៍របស់ជនជាតិដើមភាគតិច ជាសិទ្ធិស្របច្បាប់។ ច្បាប់ស្តីពីសិទ្ធិជនជាតិដើមភាគតិច រួមបញ្ចូលបទប្បញ្ញត្តិដែលផ្តោតលើគោលការណ៍ស្នូលចំនួន៤គឺ សិទ្ធិទទួលបានអត្តសញ្ញាណវប្បធម៌ សិទ្ធិទទួលបានអភិបាលកិច្ចនិងពង្រឹងសិទ្ធិអំណាចខ្លួនឯង សិទ្ធិទទួលបានយុត្តិធម៌សង្គមនិងសិទ្ធិមនុស្ស ព្រមទាំងសិទ្ធិទទួលបានដីកេរ្តិ៍ដូនតា។

ច្បាប់ស្តីពីសិទ្ធិជនជាតិដើមភាគតិចត្រូវបានគេសាទរ ចំពោះការការពារដែលផ្តល់ឲ្យជនជាតិដើមភាគតិច[96] និងមានបញ្ចូលវិធានការក្នុងការផ្តល់ឲ្យមានការទទួលស្គាល់ពីរដ្ឋចំពោះប័ណ្ណកម្មសិទ្ធិដីកំណើតក៏ដូចជាការផ្តល់ការហាមឃាត់តាមផ្លូវច្បាប់ចំពោះការអភិវឌ្ឍដីរបស់ជនជាតិដើមភាគតិចដោយរដ្ឋ ឬដោយអង្គភាពមកពីក្រៅដោយមិនមានការយល់ព្រមពីសហគមន៍ទទួលរងផលប៉ះពាល់នោះឡើយ។ បន្ថែមពីលើនេះ ច្បាប់ស្តីពីសិទ្ធិជនជាតិដើមភាគតិច ក៏ផ្តល់អាណត្តិក្នុងការបង្កើតគណៈកម្មាធិការជាតិដើម្បីជនជាតិដើមភាគតិច ដែលមានភារកិច្ចក្នុងការឃ្លាំមើលការអនុវត្តច្បាប់ស្តីពីសិទ្ធិជនជាតិដើមភាគតិចនិងក្នុងការការពារនិងលើកកម្ពស់ផលប្រយោជន៍និងសុខមាលភាពរបស់ជនជាតិដើមភាគតិច ដោយគោរពឲ្យបានត្រឹមត្រូវចំពោះវប្បធម៌និងប្រព័ន្ធ

---

[94] ក្រុមការងារអន្តរជាតិកិច្ចការជនជាតិដើមភាគតិច "ពិភពជនជាតិដើមភាគតិច២០១៥៖ ប្រទេសហ្វីលីពីន" (ឆ្នាំ២០១៥) http://bit.ly/1RItbTA

[95] ធនាគារអភិវឌ្ឍន៍អាស៊ី "ដីនិងការរស់រានវប្បធម៌៖ សិទ្ធិដីសហគមន៍របស់ជនជាតិដើមភាគតិចនៅអាស៊ី" (ឆ្នាំ២០០៩) http://bit.ly/1OX5QLg

[96] ក្រុមការងារអន្តរជាតិកិច្ចការជនជាតិដើមភាគតិច "ពិភពជនជាតិដើមភាគតិច២០១៥៖ ប្រទេសហ្វីលីពីន" (ឆ្នាំ២០១៥) http://bit.ly/1RItbTA

ជំនឿរបស់ពួកគេ។

ក្នុងឆ្នាំ២០០៧ ធនាគារពិភពលោកបានធ្វើការស្រាវជ្រាវលម្អិតមួយ[97] ដើម្បីពិនិត្យមើលឡើងវិញអំពីភាពជោគជ័យនិងភាពបរាជ័យនៃច្បាប់ស្តីពីសិទ្ធិជនជាតិដើមភាគតិចនេះ។ ការរិះគន់សំខាន់ ផ្តោតទៅលើភាពទន់ខ្សោយនៃការអនុវត្តច្បាប់ស្តីពីសិទ្ធិជនជាតិដើមភាគតិចនេះ ដែលភាគច្រើនពាក់ព័ន្ធនឹងកង្វះភាពស៊ីសង្វាក់ជាមួយច្បាប់ដទៃទៀត ព្រមទាំងការប្រឈមផ្នែករៀបចំ ដូចជាកង្វះខាតសមត្ថភាពរបស់គណៈកម្មាធិការជាតិដើម្បីជនជាតិដើមភាគតិចនិងស្ថាប័នច្បាប់ផ្សេងៗទៀតក្នុងការបំពេញតួនាទីរបស់ខ្លួនឲ្យបានគ្រប់គ្រាន់។ម្យ៉ាងវិញទៀត ធនាគារពិភពលោក បានចាត់ទុកក្របខណ្ឌស្ថាប័ននិងក្របខណ្ឌផ្នែកច្បាប់នៃច្បាប់ស្តីពីសិទ្ធិជនជាតិដើមភាគតិចនេះ ថាមានលក្ខណៈគ្រប់គ្រាន់និងអនុលោមតាមស្តង់ដារសាកលដែលគេបានទទួលយក។ នៅក្នុងរយៈដប់ឆ្នាំដំបូងចាប់តាំងពីអនុម័តរួចមក វិញ្ញាបនប័ត្រចំនួន៥៧ អំពីប័ណ្ណកម្មសិទ្ធិតំបន់បុព្វបុរស ដែលគ្របដណ្តប់លើផ្ទៃដី១/៥ នៃផ្ទៃដីប៉ាន់ស្មានសរុបប្រហែល ៦ លានហិកតានៃតំបន់ដីកេរ្តិ៍ដូនតាត្រូវបានចេញឲ្យតាមរយៈច្បាប់ស្តីពីសិទ្ធិជនជាតិដើមភាគតិច ហើយវាបានផ្តល់ផលប្រយោជន៍ដល់ប្រជាជន ៣០០.០០០ គ្រួសារ បន្ថែមពីលើវិញ្ញាបនប័ត្រចំនួន ១៧២ អំពីប័ណ្ណកម្មសិទ្ធិដីបុព្វបុរសដែលគ្របដណ្តប់លើផ្ទៃដី ៤.៨៣៨ ហិកតា។[98]

ទោះបីជាមិនទាន់មានភាពល្អឥតខ្ចោះក៏ដោយ ក៏គេមិនអាចឲ្យបន្ទាបតម្លៃក្របខណ្ឌដែលច្បាប់ស្តីពីសិទ្ធិជនជាតិដើមភាគតិចផ្តល់ឲ្យព្រមទាំងសក្តានុពលដែលមានក្នុងការការពារសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចដែរ។ ទោះបីជាប្រសិទ្ធិភាពនៃច្បាប់នេះត្រូវបានបង្អាក់ដោយការអនុវត្តអន់ខ្សោយក៏ដោយ ក៏វាមិនមែនមានន័យថាវានឹងជាបញ្ហាក្នុងប្រទេសផ្សេងទៀត ប្រសិនបើមានការអនុម័តច្បាប់ស្រដៀងគ្នានេះនោះឡើយ។ តាមពិតទៅ ចំនួនជនជាតិដើមភាគតិចដ៏ច្រើនក្នុងចំណោមប្រជាជនក្នុងប្រទេសហ្វីលីពីន ទំនងជាកត្តាដែលនាំឲ្យមានការអនុវត្តច្បាប់ស្តីពីសិទ្ធិជនជាតិដើមភាគតិចនេះមានភាពទន់ខ្សោយគឺថាប្រទេសហ្វីលីពីនមានជនជាតិដើមភាគតិចចំនួន ១២ លាននាក់ ចេញមកពីក្រុមជនជាតិដើមភាគតិចចំនួនច្រើនជាង១០០ ដែលបានរស់នៅក្នុងប្រទេសនេះ។ ទីបំផុត ច្បាប់ស្តីពីសិទ្ធិជនជាតិដើមភាគតិចនេះ បង្ហាញពីសេចក្តីប្រាថ្នារបស់រដ្ឋាភិបាលហ្វីលីពីន ក្នុងការលើកកម្ពស់ភាពចម្រុះនៅក្នុងប្រទេស ហើយអាចត្រូវបានគេមើលឃើញថាជាឧបករណ៍ដ៏ជាក់លាក់និងរស់រវើកមួយក្នុងការការពារសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច។ ច្បាប់ស្តីពីសិទ្ធិជនជាតិដើមភាគតិចនេះតំណាងឲ្យគោលប្រវត្តិដ៏សំខាន់មួយទ្វីបអាស៊ីក្នុងការក្លាយទៅជាច្បាប់មួយក្នុងចំណោមច្បាប់ដំបូងៗដែលផ្តល់ជាពិសេសនូវប្រព័ន្ធដ៏ជាក់លាក់សម្រាប់ការការពារសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច។

[97] ក្រុមធនាគារពិភពលោក "ច្បាប់ស្តីពីសិទ្ធិជនជាតិដើមភាគតិចៈ ក្របខណ្ឌច្បាប់និងស្ថាប័ន ការអនុវត្ត និងការប្រឈម" (ខែមិថុនា ឆ្នាំ ២០០៧) http://bit.ly/1HYJ5r8

[98] រ៉ូរី អ រ៉ាចាដូ "នៅតែជាជនចម្លែកនៅលើដីរបស់ខ្លួនឯង" មជ្ឈមណ្ឌលសារព័ត៌មានស៊ើបអង្កេតហ្វីលីពី (របាយការណ៍) (ខែកក្កដា ឆ្នាំ ២០០៧) http://bit.ly/1GvNUBJ

ទោះបីជាច្បាប់ស្តីពីសិទ្ធិជនជាតិដើមភាគតិច ជួបប្រទះនឹងការប្រឈមមួយចំនួន មួយផ្នែកដោយសារតែចំនួនជនជាតិដើមភាគតិចដ៏ច្រើនក្នុងប្រទេសហ្វីលីពីនក៏ដោយ ក៏សមាមាត្រនៃចំនួនជនជាតិដើមភាគតិចនៅកម្ពុជាក្នុងចំណោមប្រជាជនទាំងអស់ មានចំនួនតិចជាងនៅប្រទេសហ្វីលីពីនឆ្ងាយណាស់ ដែលតាមការប៉ាន់ប្រមាណមានពី១ ទៅ ២ ភាគរយប៉ុណ្ណោះ[99]ក្នុងប្រទេសកម្ពុជា ដែលតួលេខនេះមានប្រហែល១/១០ នៃតួលេខក្នុងប្រទេសហ្វីលីពីន។ ដូច្នេះ បន្ទុករដ្ឋបាលនៃការអនុវត្តច្បាប់បែបនេះនៅកម្ពុជា នឹងមានភាពធូរស្រាលជាង។ ដូច្នេះ ឧទាហរណ៍នៃច្បាប់ស្តីពីសិទ្ធិជនជាតិដើមភាគតិច និងបណ្តុំនៃការការពារដែលច្បាប់នេះបានចែងក្នុងទម្រង់សិទ្ធិដីធ្លីសម្រាប់សហគមន៍ជនជាតិដើមភាគតិច នៅតែអាចត្រូវបានគេមើលឃើញថាជាគំរូដ៏មានសារៈប្រយោជន៍មួយសម្រាប់ប្រទេសកម្ពុជាអនុវត្តតាម។

ប្រទេសនេប៉ាល់ផ្តល់ជាឧទាហរណ៍មួយទៀតពីថ្នាក់តំបន់ ដែលរដ្ឋបានប្តេជ្ញាចិត្តក្នុងការកែលម្អសិទ្ធិជនជាតិដើមភាគតិច តាមរយៈការក្លាយទៅជាប្រទេសទីមួយក្នុងអាស៊ីខាងត្បូងដែលបានផ្តល់សច្ចាប័នអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៦៩ស្តីពីជនជាតិដើមភាគតិចនិងប្រជាជនកុលសម្ព័ន្ធ ("អង្គការពលកម្មអន្តរជាតិ ១៦៩")។

**ករណីសិក្សា៖ ប្រទេសនេប៉ាល់និងអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៦៩ស្តីពីជនជាតិដើមភាគតិចនិងប្រជាជនកុលសម្ព័ន្ធ**

បើយោងតាមជំរឿនជាតិចុងក្រោយក្នុងឆ្នាំ២០១១ សហគមន៍ជនជាតិដើមភាគតិចមានប្រហែល៣៦% នៃប្រជាជននេប៉ាល់សរុប ២៦.៥លាននាក់ ហើយដែលអាចបែងចែកជាក្រុមផ្សេងគ្នាដែលមានការទទួលស្គាល់តាមច្បាប់ ចំនួន៥៩ក្រុម។[100] ក្នុងខែកញ្ញា ឆ្នាំ២០០៧ ប្រទេសនេប៉ាល់បានក្លាយជាប្រទេសទីមួយក្នុងអាស៊ីខាងត្បូងដែលបានផ្តល់សច្ចាប័នអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៦៩ ដូច្នេះត្រូវជាប់កាតព្វកិច្ចក្នុងការអនុម័តគោលនយោបាយដើម្បីធានាឲ្យមានការការពារជនជាតិដើមភាគតិចនិងដីធ្លីរបស់ពួកគេ។

សហគមន៍ជនជាតិដើមភាគតិចនៅនេប៉ាល់ បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះការផ្តល់សច្ចាប័នអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៦៩ ក៏ប៉ុន្តែការអនុវត្តត្រូវបានរារាំងដោយសារតែកង្វះការយល់ដឹងដោយជនជាតិដើមភាគតិចនិងប្រជាជនដែលមិនមែនជាជនជាតិដើមភាគតិច ដែលមានសមាសភាពសំខាន់[101]នៅក្នុងការអនុវត្ត។ ទោះបីជាយ៉ាងណាក៏ដោយ កិច្ចខិតខំប្រឹងប្រែងនាពេលថ្មីៗស្តីពីការកែលម្អទាំងការយល់ដឹងនិងការអនុវត្តគោលការណ៍ស្នូលរបស់អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៦៩ ត្រូវបានដឹកនាំដោយអង្គការភាពជាដៃគូ

---

[99] ក្រុមការងារអន្តរជាតិកិច្ចការជនជាតិដើមភាគតិច "ពិភពជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា" (ឆ្នាំ២០១៥) http://bit.ly/1Qj4FsT

[100] ក្រុមការងារអន្តរជាតិកិច្ចការជនជាតិដើមភាគតិច "ជនជាតិដើមភាគតិចក្នុងប្រទេសនេប៉ាល់" (ឆ្នាំ២០១៤) http://bit.ly/1McCjZB

[101] ភាពជាដៃគូជាមួយជនជាតិដើមភាគតិច "រឿងរ៉ាវជោគជ័យរបស់ភាពជាដៃគូជាមួយជនជាតិដើមភាគតិច៖ សហការដើម្បីលើកកម្ពស់និងការពារសិទ្ធិជនជាតិដើមភាគតិច" (ខែឧសភា ឆ្នាំ២០១៤) http://bit.ly/1lHQfpP

របស់ជនជាតិដើមភាគតិចរបស់អង្គការសហប្រជាជាតិ ដែលជាគំនិតផ្តួចផ្តើមរបស់អង្គការសហប្រជាជាតិដែលមានគោលបំណងស្នូលក្នុងការលើកកម្ពស់ការរីកចម្រើននៃសិទ្ធិរបស់ជនជាតិដើមភាគតិច និងការចូលរួមរបស់ពួកគេក្នុងការធ្វើការសម្រេចចិត្ត។ តាមការពិចារណាទៅទស្សនៈដែលបានមកពីភាគីពាក់ព័ន្ធជាច្រើន ដោយរាប់បញ្ចូលទាំងសហគមន៍ជនជាតិដើមភាគតិច តាមរយៈកិច្ចសហការជាមួយនឹងរដ្ឋាភិបាលប្រទេសនេប៉ាល់នោះ អង្គការភាពជាដៃគូរបស់ជនជាតិដើមភាគតិចរបស់អង្គការសហប្រជាជាតិ និងអង្គការពលកម្មអន្តរជាតិ បានបង្កើតកូនសៀវភៅ "សំណួរដែលគេចូលចិត្តសួរ" ស្តីពីអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៦៩ និងបានបកប្រែសៀវភៅរបស់អង្គការពលកម្មអន្តរជាតិស្តីពីការយល់ដឹងអំពីអនុសញ្ញាស្តីពីជនជាតិដើមភាគតិចនិងប្រជាជនកុលសម្ព័ន្ធ ឆ្នាំ១៩៨៩ (លេខ ១៦៩)[102] ទៅជាភាសានេប៉ាល់។ ឧបករណ៍ទាំងនេះ ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយពេញឆ្នាំ២០១៥ ហើយគេសង្ឃឹមថា ជាលទ្ធផល នឹងមានការកែលម្អក្នុងការអនុវត្តអនុសញ្ញា ១៦៩នេះ នៅក្នុងប្រទេសនេប៉ាល់។

ទោះបីជាមានបញ្ហាផ្សេងៗជាមួយនឹងការអនុវត្តក៏ដោយ ក៏ការផ្តល់សច្ចាប័នទៅលើអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៦៩ ដោយប្រទេសនេប៉ាល់ គឺជាព្រឹត្តិការណ៍គោលប្រវត្តិមួយ ដែលជាការផ្តល់សញ្ញាអំពីការប្តេជ្ញាចិត្តរបស់ប្រទេសនេះ ក្នុងការទទួលស្គាល់និងដើម្បីភាពរីកចម្រើននៃសិទ្ធិជនជាតិដើមភាគតិច។ គេសង្ឃឹមថា ការអនុវត្តអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៦៩នេះ នឹងមានការកែលម្អ ហើយគោលការណ៍ស្នូលរបស់វានឹងមានការផ្សារភ្ជាប់នៅក្នុងច្បាប់ជាតិរបស់ប្រទេសនេប៉ាល់។ ការអនុម័តអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៦៩ គោលប្រវត្តិដ៏សំខាន់មួយត្រូវបានសម្រេចឡើង និងក្លាយជាក្របខណ្ឌសំខាន់សម្រាប់ការការពារតាមផ្លូវច្បាប់ទៅលើសិទ្ធិជនជាតិដើមភាគតិច។

ទោះបីជាការអនុវត្តអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៦៩ ដោយប្រទេសនេប៉ាល់ មិនទាន់បានល្អឥតខ្ចោះនៅឡើយក៏ដោយ ក៏ប្រទេសនេប៉ាល់ បានបង្កើតជាឧទាហរណ៍ដ៏សំខាន់មួយដល់ប្រទេសនៅអាស៊ីដែលជនជាតិដើមភាគតិចក្នុងប្រទេសកំពុងទទួលរងការរំលោភបំពានសិទ្ធិ និងកំពុងមានបញ្ហាអសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី។ ទោះបីប្រទេសកម្ពុជាបានបោះឆ្នោតគាំទ្រ សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិចក៏ដោយ ប្រសិនបើប្រទេសកម្ពុជាពិតជាប្តេជ្ញាចិត្តក្នុងការការពារដីរបស់ជនជាតិដើមភាគតិចមែននោះ ប្រទេសកម្ពុជាគួរធ្វើតាមការឈានមុខរបស់ប្រទេសនេប៉ាល់ និងផ្តល់សច្ចាប័នទៅលើអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៦៩។ ប្រសិនបើរដ្ឋាភិបាលកម្ពុជាចង់ទទួលបានប្រយោជន៍ពីបទពិសោធន៍និងមេរៀនពីប្រទេសហ្វីលីពីននិងប្រទេសនេប៉ាល់ បន្ថែមពីលើប្រទេសផ្សេងៗទៀត នៅជុំវិញពិភពលោកនោះ ប្រទេសកម្ពុជាអាចចាប់ផ្តើមបានកាន់តែមានប្រសិទ្ធភាពក្នុងការការពារសហគមន៍ជនជាតិដើមភាគតិចនិងដីរបស់ពួកគេបាន។

---

[102] វេទិកាអចិន្ត្រៃយ៍របស់អង្គការសហប្រជាជាតិស្តីពីបញ្ហាជនជាតិដើមភាគតិច "បច្ចុប្បន្នភាពនៃសកម្មភាពអង្គការពលកម្មអន្តរជាតិទាក់ទងនឹងជនជាតិដើមភាគតិច" សម័យប្រជុំទី១៤ ក្រុងញូយ៉ក ថ្ងៃទី២០ មេសា ដល់ ១ ឧសភា ២០១៥ http://bit.ly/1NrZHUT

# ៦. សេចក្តីសន្និដ្ឋាននិងអនុសាសន៍

ដូចការស្រាវជ្រាវបានលាតត្រដាងថា មានឧបសគ្គជាច្រើនដែលកំពុងប្រឈមសម្រាប់សហគមន៍ជនជាតិដើមភាគតិចដែលបានមានបំណងក្នុងការចុះបញ្ជីដីសហគមន៍របស់ពួកគេ តាមរយៈដំណើរការចុះបញ្ជីដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព។ ការប្រឈមទាំងនេះ កើតឡើងដោយសារតែលក្ខណៈស្មុគស្មាញនិងប្រើប្រាស់ពេលវេលាវែងក្នុងដំណើរការដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះ ដោយសារកង្វះឆន្ទៈនយោបាយ និងដោយសារតែសកម្មភាពរបស់ភាគីពាក់ព័ន្ធដែលបានចូលរួម ដោយក្នុងនោះរួមមានទាំងអាជ្ញាធរមូលដ្ឋាននិងក្រុមហ៊ុន និងសូម្បីតែនៅក្នុងចំណោមអង្គការសង្គមស៊ីវិលដែលកំពុងធ្វើការជួយជ្រោមជ្រែងដល់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍ខ្លួនឯងផ្ទាល់។ ខណៈពេលដែលភាគីពាក់ព័ន្ធទាំងអស់ត្រូវផ្តល់អាទិភាពទៅលើការការពារសិទ្ធិជនជាតិដើមភាគតិច និងគាំទ្រដល់ដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនោះ ទីបំផុតភារកិច្ចទទួលខុសត្រូវស្ថិតនៅលើរដ្ឋាភិបាលក្នុងការការពារសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច និងក្នុងការធានាថាសហគមន៍អាចចុះបញ្ជីដីធ្លីរបស់ពួកគេបានទាន់ពេលវេលា។ ប៉ុន្តែ កង្វះឆន្ទៈនយោបាយនៅតែជាបញ្ហាប្រឈមក្នុងការការពារដីរបស់ជនជាតិដើមភាគតិច ដែលមានភស្តុតាងច្បាស់ដោយសារតែមានការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះតែមួយចំនួនតូចប៉ុណ្ណោះរហូតមកទល់នឹងពេលបច្ចុប្បន្ននេះ។ ក្នុងពេលអវត្តមានការការពារជាផ្លូវការដែលផ្តល់ឲ្យតាមរយៈប័ណ្ណកម្មសិទ្ធិដីធ្លី និងក្នុងពេលដែលវិធានការការពារបណ្តោះអាសន្នមានសភាពមិនគ្រប់គ្រាន់នោះ ពេលវេលាជាកត្តាដែលមានសារៈសំខាន់បំផុត ដោយសារតែដីជនជាតិដើមភាគតិចកំពុងតែបាត់បង់យ៉ាងឆាប់រហ័ស ហើយវាជាការគំរាមកំហែងដល់អត្តិភាពរបស់ជនជាតិដើមភាគតិចនៅកម្ពុជា។

ប៉ុន្តែ ថ្វីត្បិតតែហាក់ដូចជាមានឧបសគ្គយ៉ាងច្រើនដែលពួកគាត់កំពុងប្រឈមក៏ដោយ ក៏សហគមន៍ជនជាតិដើមភាគតិច នៅតែកិច្ចគាំពារដីធ្លីរបស់ពួកគេ។ ឧទាហរណ៍ សហគមន៍នៅភូមិក្បាលរមាស បានរៀបរាប់ប្រាប់ក្រុមការងារស្រាវជ្រាវថា *"ស្ទើរតែរាល់ថ្ងៃ ប្រសិនបើយើងឮអំពីការកាប់ឈើខុសច្បាប់ឬការឈូសឆាយក្នុងតំបន់នេះគ្នាយើង៤០-៥០ នាក់ចេញទៅបញ្ឈប់សកម្មភាពនោះភ្លាម"*។ ដោយសារធនធាននិងការគាំទ្រមានកម្រិតតិចតួច វាទំនងជាមិនអាចទៅរួចទេដែលថាសហគមន៍ជនជាតិដើមភាគតិចនឹងអាចមានលទ្ធភាពក្នុងការបន្តទ្រាំទ្រឲ្យមានប្រសិទ្ធភាពនូវការតវ៉ាមិនចេះចប់ទាំងនេះ ក្នុងខណៈពេលដែលត្រូវបន្តជីវភាពរស់នៅរបស់ខ្លួនដែរនោះ។ ទោះជាយ៉ាងណាក៏ដោយ សហគមន៍ជនជាតិដើមភាគតិចដែលបានចូលរួមក្នុងការស្រាវជ្រាវនេះចង់សង្កត់ធ្ងន់អំពីការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការបន្តការការពារដីរបស់ខ្លួន ដូចដែលសហគមន៍មួយបានប្រកាសដោយម៉ឺងម៉ាត់ថា *"យើងនៅតែមានភាពរឹងមាំក្នុងការការពារដីរបស់យើងពីការចាប់ច្បាមយក ហើយយើងនឹងតស៊ូការពារវារហូតទាល់តែយើងស្លាប់"*។

ជាងនេះទៀត ការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព មិនបានធានាថានឹងបញ្ចប់ការរំលោភបំពានសិទ្ធិដីធ្លីនោះទេ ដោយសារតែមានរបាយការណ៍ថាសហគមន៍ជនជាតិដើមភាគតិចដែលបានទទួលប័ណ្ណកម្មសិទ្ធិដីសមូហភាពរួចហើយនោះ នៅតែទទួលរងការទន្ទ្រានចូលដីសហគមន៍ តាមរយៈការចាប់ច្បាមដីនិងការកាប់ឈើខុសច្បាប់ ដោយសារតែកង្វះខាតការអនុវត្តច្បាប់ពីអាជ្ញាធរ។ បន្ថែមពីលើនេះ មានការបង្ហាញការព្រួយបារម្ភ ទាក់ទងនឹងភាពពាក់ព័ន្ធផ្នែកនយោបាយនៃច្បាប់ជុំវិញដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព គឺថាដើម្បីបានការទទួលស្គាល់ពីក្រសួងអភិវឌ្ឍន៍ជនបទក្នុងឋានៈជាសហគមន៍ជនជាតិដើមភាគតិចសហគមន៍ត្រូវតែបង្ហាញបញ្ជាក់អំពី "ភាពជាជនជាតិដើមភាគតិច" និងរបៀបរស់នៅបែបប្រពៃណីដែលប្រការនេះមានសក្តានុពលក្នុងការ *"ធ្វើឲ្យពួកគេស្ថិតក្នុងស្ថានភាពមួយចំនួនដែលអាចដាក់កំហិតទៅលើឱកាសរបស់ពួកគេក្នុងការផ្លាស់ប្តូរអ្វីមួយដែលអាចចំណេញដល់ពួកគេ"*។[103]

ទោះជាយ៉ាងណាក៏ដោយ ប័ណ្ណកម្មសិទ្ធិដីសមូហភាពពិតជាផ្តល់ដល់សហគមន៍ជនជាតិដើមភាគតិចនូវការការពារមួយកម្រិត ដែលពួកគេបានធ្វើឲ្យសិទ្ធិដីធ្លីមានភាពផ្លូវការ និងជាមធ្យោបាយមួយសម្រាប់ការពារប្រសិនបើវិវាទដីធ្លីកើតមានឡើង។ សុវត្ថិភាពកាន់កាប់ដីធ្លី និងការអភិរក្សទំនៀមទម្លាប់ ប្រពៃណីនិងធនធានធម្មជាតិកាន់តែរឹងមាំ គឺជាផលវិជ្ជមានដែលសហគមន៍ជនជាតិដើមភាគតិចដែលបានទទួលប័ណ្ណកម្មសិទ្ធិដីសមូហភាព។ ដូច្នេះ សារៈសំខាន់នៃប័ណ្ណកម្មសិទ្ធិដីសមូហភាពសម្រាប់សហគមន៍ជនជាតិដើមភាគតិចក្នុងការការពារសិទ្ធិដីធ្លីរបស់ពួកគេ និងអត្តិភាពរបស់ពួកគេក្នុងឋានៈជាជនជាតិដើមភាគតិច មិនអាចមើលស្រាលបានឡើយ។

ជាមួយគ្នានេះ ម.ស.ម.ក សូមផ្តល់នូវអនុសាសន៍ដល់ភាគីពាក់ព័ន្ធនានា ដោយផ្អែកទៅការស្រាវជ្រាវដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ ដូចតទៅ ៖

## ៦.១ រាជរដ្ឋាភិបាលកម្ពុជា

- ផ្តល់សច្ចាប័នអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៦៩ ស្តីពីជនជាតិដើមភាគតិចនិងប្រជាជនកុលសម្ព័ន្ធ ជាផ្នែកមួយនៃការប្តេជ្ញាចិត្តក្នុងការការពារសិទ្ធិជនជាតិដើមភាគតិច
- កែប្រែគោលនយោបាយដែលមានស្រាប់ ស្តីពីការប្រើប្រាស់និងការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច តាមរយៈការលុបចោលនូវប្រយោគឬមាត្រាណាដែលមានអត្ថន័យ កំណត់ថាដីសហគមន៍ជនជាតិដើមភាគតិចជាទ្រព្យសម្បត្តិរដ្ឋ ឬដាក់កំណត់ទៅលើទំហំដីបញ្ចុះសពនិងព្រៃអារក្សដែលអាចចុះបញ្ជីតាមដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព
- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ដើម្បីធានាឲ្យមានការអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវ។

---

[103] អាន បែត "ជនជាតិដើមភាគតិចនិងដីធ្លី៖ ការប្រៀបធៀបប័ណ្ណកម្មសិទ្ធិដីសហគមន៍និងឥទ្ធិពលនៅក្នុងប្រទេសកម្ពុជានិងឡាវ" *ទស្សនៈអាស៊ីប៉ាស៊ីហ្វិក* វ៉ុល ៥៤ លេខ ៣ (ខែធ្នូ ឆ្នាំ២០១៣)។

- បង្កើនការយល់ដឹងអំពីប័ណ្ណកម្មសិទ្ធិដីសមូហភាពនិងប័ណ្ណកម្មសិទ្ធិដីឯកជន ដើម្បីឲ្យជនជាតិដើមភាគតិចអាចធ្វើការសម្រេចចិត្តដោយឯករាជ្យនិងមានព័ត៌មានគ្រប់គ្រាន់ ថាតើការការពារផ្លូវច្បាប់ណាមួយដែលពួកគេត្រូវស្វែងរកសម្រាប់ដីរបស់ពួកគេ
- ផ្សព្វផ្សាយព័ត៌មានអំពីដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព ដើម្បីឲ្យសហគមន៍បានដឹងច្បាស់អំពីរបៀបចុះបញ្ជីដីសមូហភាព
- បែងចែកកញ្ចប់ថវិកាជាតិសម្រាប់គ្រប់ដំណើរការនីមួយៗនៃការចុះបញ្ជីដីសមូហភាព និងពង្រឹងសមត្ថភាពរបស់ស្ថាប័នពាក់ព័ន្ធ
- បញ្ឈប់ការអនុម័តសម្បទាននិងគម្រោងអភិវឌ្ឍន៍បន្ថែមទៀតនៅក្នុងតំបន់ជនជាតិដើមភាគតិច រហូតទាល់តែព្រំប្រទល់ដីជនជាតិដើមភាគតិចទាំងអស់បានកំណត់រួចស្រេចហើយ
- កែប្រែវិធានការការពារបណ្តោះអាសន្ន ដើម្បីធានាសុវត្ថិភាពក្នុងការកាន់កាប់សម្រាប់ដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពសម្រាប់សហគមន៍តាំងពីដំណាក់ដំបូងនៅក្នុងការដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព និងមិនត្រូវកាត់ចេញនូវដីដែលបានព្រមព្រៀងរួចហើយសម្រាប់សហគមន៍ទៅឲ្យគម្រោងវិនិយោគណាមួយ មុនការវាស់វែងចូលជាធរមាននោះឡើយ
- ផ្តល់អាទិភាពដល់ការកំណត់ព្រំប្រទល់ដីជនជាតិដើមភាគតិច ក្រោមការសង្កេតការណ៍ពីអង្គការមិនមែនរដ្ឋាភិបាល និងដោយមានកិច្ចសហប្រតិបត្តិការរបស់សហគមន៍
- ពិនិត្យឡើងវិញនិងលុបចោលកិច្ចសន្យាជាមួយក្រុមហ៊ុនដែលបានធ្វើខុសច្បាប់ ក្នុងការទទួលបានដីពីសហគមន៍ជនជាតិដើមភាគតិច
- ចាត់វិធានការដើម្បីបញ្ឈប់ជាបន្ទាន់ចំពោះការកាប់ឈើខុសច្បាប់ ដែលកំពុងកើតឡើងក្នុងសហគមន៍ជនជាតិដើមភាគតិច និងកន្លែងផ្សេងទៀតក្នុងប្រទេស
- បញ្ឈប់ការដាក់គំនាបដោយបង្ខំទៅលើជនជាតិដើមភាគតិចឲ្យទទួលយកកម្មសិទ្ធិដីឯកជន ព្រមទាំងនាំជនល្មើសមកកាត់ទោសតាមសកម្មភាពដែលបានប្រព្រឹត្ត និង
- បញ្ឈប់ការគំរាមកំហែងនិងការធ្វើទុក្ខបុកម្នេញទៅលើសកម្មជនសហគមន៍ជនជាតិដើមភាគតិច ដែលតស៊ូមតិដើម្បីការពារសិទ្ធិដីធ្លីរបស់ខ្លួន

## ៦.២ ក្រុមហ៊ុន

- គោរពឲ្យបានខ្ជាប់ខ្ជួនតាមច្បាប់កម្ពុជានិងច្បាប់អន្តរជាតិនៅក្នុងប្រតិបត្តិទាំងអស់ និងត្រូវធានាឲ្យមានការអនុលោមតាមលក្ខខណ្ឌតម្រូវក្នុងអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៦៩ និង សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច ក៏ដូចជាការយល់ព្រមដោយសេរីនិងដោយមានព័ត៌មានគ្រប់គ្រាន់ជាមុនសិន
- តាមច្បាប់ជាតិ ត្រូវធានាឲ្យមានការធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គមសមស្របមួយ មុននឹងចាប់ផ្តើមប្រតិបត្តិការអាជីវកម្ម

- ប្តេជ្ញាឲ្យមានគោលនយោបាយសិទ្ធិមនុស្សមួយដែលការពារសិទ្ធិជនជាតិដើមភាគតិច និងស្របតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស ក៏ដូចជាធានាថារាល់បុគ្គលិកទាំងអស់ ទទួលបានការបណ្តុះបណ្តាលអំពីគោលនយោបាយនោះ
- ជៀសវាងការបង្កឬរួមចំណែកដល់ការប៉ះពាល់សិទ្ធិមនុស្សកំឡុងពេលប្រតិបត្តិការ តាមរយៈការចូលរួមដោយអត្ថន័យរបស់សហគមន៍ជនជាតិដើមភាគតិចនៅគ្រប់ដំណាក់កាលទាំងអស់នៃគម្រោងដែលបានស្នើឡើង ដោយរាប់បញ្ចូលទាំងការរចនា ការវាយតម្លៃផលប៉ះពាល់ជាសក្តានុពល និងការអនុវត្តព្រមទាំងធានាឲ្យមានតម្លាភាពពេញលេញ និង
- ដោះស្រាយនិងផ្តល់សំណងសមរម្យសម្រាប់ការប៉ះពាល់បែបនេះ នៅពេលដែលវាកើតឡើង តាមរយៈការបង្កើតយន្តការដោះស្រាយនៅកម្រិតប្រតិបត្តិការ ដែលទទួលស្គាល់អភិបាលកិច្ចនិងច្បាប់ប្រពៃណីរបស់ជនជាតិដើមភាគតិច។

## ៦.៣ អង្គការសង្គមស៊ីវិលនិងដៃគូអភិវឌ្ឍន៍

- កែលម្អកិច្ចសហប្រតិបត្តិការជាមួយអង្គការដទៃទៀតដែលកំពុងធ្វើជួយជ្រោមជ្រែងដល់សហគមន៍ជនជាតិដើមភាគតិចដូចគ្នា តាមរយៈការបែងចែកការទទួលខុសត្រូវ និងបញ្ចូលធនធានហិរញ្ញវត្ថុរួមគ្នាដើម្បីធានាថាសហគមន៍ទទួលបានការគាំទ្រល្អបំផុតតាមដែលអាចធ្វើទៅបាន
- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសនិងជំនួយចាំបាច់ដល់ស្ថាប័នរដ្ឋពាក់ព័ន្ធ ដើម្បីពង្រឹងសមត្ថភាពឲ្យស្ថាប័នទាំងនោះគាំទ្រសហគមន៍ជនជាតិដើមភាគតិចឲ្យបានកាន់តែប្រសើរក្នុងដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព
- ជាពិសេស ត្រូវជួយជ្រោមជ្រែងដល់សហគមន៍ ក្នុងការកំណត់ព្រំប្រទល់ដីនិងការបង្កើតផែនទីបឋម
- ធានាឲ្យមានកិច្ចសហប្រតិបត្តិការក្នុងការងារតស៊ូមតិ ក្នុងគោលបំណងពន្លឿនដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព
- ផ្តល់កម្មវិធីពង្រឹងសមត្ថភាពសម្រាប់សហគមន៍ជនជាតិដើមភាគតិចអំពីច្បាប់ភូមិបាលសិទ្ធិដីធ្លី យន្តការដោះស្រាយវិវាទដែលអាចរកបាន ដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព និងបច្ចេកទេសតស៊ូមតិ ដើម្បីបង្កើនចំណេះដឹងនិងទំនុកចិត្ត
- ធានាថាអ្នកទទួលបានពីការបណ្តុះបណ្តាល រួមមានសមាជិកសហគមន៍ ជាជាងមានតែតំណាងសហគមន៍
- ធ្វើទស្សនកិច្ចទៅសហគមន៍ជនជាតិដើមភាគតិចឲ្យបានទៀងទាត់ ដើម្បីយល់ច្បាស់និងកសាងទំនុកចិត្តជាមួយសហគមន៍ និង
- សម្រួលនិងគាំទ្រការចងបណ្តាញរវាងសហគមន៍ជនជាតិដើមភាគតិចនានា ដើម្បីពង្រឹងសាមគ្គីភាព

## ៦.៤ សហគមន៍

- ពង្រឹងឯកភាពសហគមន៍ តាមរយៈការរៀបចំកិច្ចប្រជុំទៀងទាត់រវាងសមាជិកសហគមន៍ តាមរយៈការជំរុញយុវជនជំនាន់ក្រោយឲ្យចូលរួមនៅក្នុងសកម្មភាពសហគមន៍ តាមរយៈឲ្យមានការចូលរួមជាមួយមេភូមិនិងក្រុមប្រឹក្សាឃុំ និងតាមរយៈការចងបណ្តាញជាមួយសហគមន៍ជនជាតិដើមភាគតិចផ្សេងៗ
- លើកទឹកចិត្តនិងគាំទ្រដល់សមាជិកសហគមន៍ ដែលប្រឈមនឹងការលំបាកឬការគាបសង្កត់ពីប្រភពខាងក្រៅ
- ជានាថាសមាជិកសហគមន៍ដែលចង់ទទួលយកកម្មសិទ្ធិដីឯកជន បានដឹងអំពីផលវិបាកនៃការចាកចេញពីសហគមន៍ ប៉ុន្តែត្រូវធ្វើដោយការគោរពគ្នាទៅវិញទៅមក
- លើកទឹកចិត្តសមាជិកសហគមន៍ ជាជាងតែតំណាងសហគមន៍ ឲ្យចូលរួមការបណ្តុះបណ្តាលពីអង្គការសង្គមស៊ីវិល និង
- ជានាថាសមាជិកសហគមន៍ដែលចូលរួមការបណ្តុះបណ្តាលរបស់អង្គការសង្គមស៊ីវិល ផ្សព្វផ្សាយចំណេះដឹងដែលទទួលបានដល់សមាជិកសហគមន៍ដទៃទៀត ដើម្បីបង្កើនការយល់ដឹងជាទូទៅអំពិសិទ្ធិក្នុងចំណោមសហគមន៍។

# ឯកសារយោង

## ច្បាប់ ក្រឹត្យ ដីកា សេចក្តីសម្រេច កម្ពុជា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ (១០ ខែកក្កដា ២០០៧)

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣ វិសោធនកម្មក្នុងឆ្នាំ២០០៦) http://bit.ly/1hcJqYV

សេចក្តីសម្រេចលេខ ១២៥ សសរ ១៨ ខែសីហា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការអន្តរក្រសួងដើម្បីធ្វើអធិការកិច្ច កំណត់ព្រំប្រទល់ និងប៉ាន់ប្រមាណសម្បទានដីសេដ្ឋកិច្ច

ច្បាប់ភូមិបាល ក្រឹត្យ-ច្បាប់/១០០ (១០ ខែសីហា ឆ្នាំ១៩៩២)

ច្បាប់ភូមិបាល នស/រកម/០៨០១/១៤ (២០ ខែកក្កដា ឆ្នាំ២០០១)

ច្បាប់ស្តីពីព្រៃឈើ នស/រកម/០៨០២/០១៦ (ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០២) http://bit.ly/1tbrB3i

ក្រសួងមហាផ្ទៃនិងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សារាចរអន្តរក្រសួងស្តីពីវិធានការការពារបណ្តោះអាសន្ន ក្នុងការការពារដីធ្លីជនជាតិដើមភាគតិច (២០០១)

បទបញ្ជាស្តីពីការពង្រឹងវិធានការនិងប្រសិទ្ធភាពគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច លេខ ០១បប (ខែឧសភា ឆ្នាំ ២០១២)

អនុក្រឹត្យលេខ ២២ ស្តីពីវិមជ្ឈការអំណាច តួនាទី និងភារកិច្ច ទៅដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ អនក/បក (២៥ ខែមិនា ឆ្នាំ២០០២)

អនុក្រឹត្យ៨៣ ស្តីពីនីតិវិធីចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច អនក/បក (ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៩)

អនុក្រឹត្យ ១៤៦ ស្តីពីសម្បទានដីសេដ្ឋកិច្ច អនក/បក (ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥)

## ច្បាប់និងអនុសញ្ញាអន្តរជាតិ

### *សន្ធិសញ្ញានិងសេចក្តីប្រកាសអន្តរជាតិ*

អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រី (១៨ ខែធ្នូ ១៩៧៩) http://bit.ly/1jkl3IM

អនុសញ្ញាស្តីពីសិទ្ធិកុមារ (ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩) http://bit.ly/1fGCcXV

អង្គការពលកម្មអន្តរជាតិលេខ១៦៩ ស្តីពីជនជាតិដើមភាគតិចនិងក្រុមកុលសម្ព័ន្ធ សម័យប្រជុំលើកទី៧៦ (២៧ ខែមិថុនា ឆ្នាំ១៩៨៩) (ចូលជាធរមាននៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩៩១) http://bit.ly/1O0X1Dc

កតិកាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (សេចក្តីសម្រេចមហាសន្និបាត 2200A (XXI) នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៦ ចូលជាធរមាននៅថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៦) http://bit.ly/15WUwtO

អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ http://bit.ly/1k1MoiX

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (សេចក្តីសម្រេចមហាសន្និបាត 217A III ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨) http://bit.ly/1O8f0nS

សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច (សេចក្តីសម្រេចមហាសន្និបាត ៦១/២៩៥ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧) http://bit.ly/1bKIrMs

## លិខិតុបករណ៍អន្តរជាតិផ្សេងទៀត

សេចក្តីពន្យល់ទូទៅលេខ៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ "សិទ្ធិទទួលបានលំនៅដ្ឋានសមរម្យ" (មាត្រា១១(១) (ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៩១) http://bit.ly/1NREsLV

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស "សលាកប័ត្រព័ត៌មាន លេខ២៥ ការបណ្តេញចេញដោយបង្ខំ និងសិទ្ធិមនុស្ស" (ខែឧសភា ឆ្នាំ១៩៩៦) http://bit.ly/1NKzQKM

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស"គោលការណ៍ណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស" (២០១១) http://bit.ly/18WbEUy

ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ចរបស់អង្គការសហប្រជាជាតិ "គោលការណ៍ណែនាំស្តីពីការផ្លាស់ទីលំនៅក្នុងប្រទេស" គោលការណ៍ទី៩ (១១ ខែកុម្ភៈ ឆ្នាំ១៩៩៨) http://bit.ly/1GxBOfU

## របាយការណ៍និងការបោះពុម្ពផ្សាយ

ធនាគារអភិវឌ្ឍន៍អាស៊ី "ដីនិងការរស់រានវប្បធម៌៖ សិទ្ធិដីសហគមន៍របស់ជនជាតិដើមភាគតិចនៅអាស៊ី" (២០០៩) http://bit.ly/1OX5QLg

អង្គការអាដហុក "ដីរបស់អ្នកណា? របាយការណ៍ស្តីពីស្ថានភាពសិទ្ធិដីធ្លីក្នុងប្រទេសកម្ពុជាឆ្នាំ២០១៤ និងពាក់កណ្តាលឆ្នាំ២០១៥" (ខែកក្កដា ឆ្នាំ២០១៥) http://bit.ly/1Hhk4qe

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "តំបន់អារ៉ែង ៖ ដីរបស់ជនជាតិដើមភាគតិចរងការគំរាមពីការសាងសង់ទំនប់វារីអគ្គិសនី" (ប្រវត្តិសកម្មជនដីធ្លី) http://bit.ly/1GvNUBJ

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "ឃុំប៊ូស្រា ខេត្តមណ្ឌលគីរី" (ប្រវត្តិសកម្មជនដីធ្លី) http://bit.ly/1Q5PIdR

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "កម្ពុជា៖ ដីទំនាស់ ទិដ្ឋភាពទូទៅនៃស្ថានភាពដីធ្លី" (របាយការណ៍ (ខែធ្នូ ឆ្នាំ ២០១៣) http://bit.ly/1KtPNVy

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "ឋានានុក្រមច្បាប់ក្នុងប្រទេសកម្ពុជា" (សលាកប័ត្រព័ត៌មាន) (ខែមករា ឆ្នាំ ២០១៤) http://bit.ly/1IKTN4m

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "ភូមិក្បាលរមាស ប្រវត្តិទំនប់ទន្លេសេសានក្រោម២" (ប្រវត្តិសកម្មជនដីធ្លី) http://bit.ly/21U8oB4

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "ប្រវត្តិសកម្មជនដីធ្លី" (ខែកញ្ញា ឆ្នាំ២០១៥) http://bit.ly/21b6V96

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "របាយការណ៍ស្តីពីគោលនយោបាយកំណែទម្រង់ដីធ្លី៖ លទ្ធផលចេញពីការពិភាក្សាតុមូលនិងវេទិកាគោលនយោបាយ" (ខែកក្កដា ឆ្នាំ២០១៣) http://bit.ly/1O6PcvT

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់" (សលាកប័ត្រព័ត៌មាន ម.ស.ម.ក) (ខែមិថុនា ឆ្នាំ២០១២) http://bit.ly/1QvgfiZ

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "មណ្ឌលគីរី-អ្នកភូមិជនជាតិដើមភាគតិចព្នងនិយាយថាការឈូសឆាយដីដោយក្រុមហ៊ុនចំការកៅស៊ូ គំរាមកំហែងដល់ជីវភាពរស់នៅនិងរបៀបរស់នៅតាមបែបប្រពៃណីរបស់ពួកគេ (ប្រវត្តិសកម្មជនដីធ្លី) http://bit.ly/1OWBit8

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "បរាជ័យនៃយន្តការដោះស្រាយវិវាទដីធ្លី" (កំណត់សម្គាល់សង្ខេប) (ខែកក្កដា ឆ្នាំ២០១៤) http://bit.ly/12zx4nE

ក្លូបិលវីតណេស "ក្រុមអភិជនជំនួញកៅស៊ូ៖ មធ្យោបាយដែលបណ្តាក្រុមហ៊ុនវៀតណាមនិងអ្នកផ្តល់ហិរញ្ញប្បទានអន្តរជាតិកំពុងដឹកនាំទៅកាន់វិបត្តិនៃការប្លន់យកដីក្នុងប្រទេសកម្ពុជានិងប្រទេសឡាវ (ខែឧសភា ឆ្នាំ ២០១៣) http://bit.ly/1HgC1V8

អង្គការឃ្លាំមើលសិទ្ធិមនុស្ស "កម្ពុជា៖ យុទ្ធនាការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី បើកឲ្យមានការបំពាន" (១២ ខែមិថុនា ឆ្នាំ២០១៣) http://bit.ly/1U5ECUL

អ៊ាន បៃត "ជនជាតិដើមភាគតិចនិងដីធ្លី៖ ការប្រៀបធៀបប័ណ្ណកម្មសិទ្ធិដីសហគមន៍និងឥទ្ធិពលនៅក្នុងប្រទេសកម្ពុជានិងឡាវ" *ទស្សនៈអាស៊ីប៉ាស៊ីហ្វិក* វ៉ុល៥៤ លេខ ៣ (ខែធ្នូ ២០១៣)

ក្រុមការងារអន្តរជាតិកិច្ចការជនជាតិដើមភាគតិច "ជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា" (២០១៥) http://bit.ly/1Qj4FsT

ក្រុមការងារអន្តរជាតិកិច្ចការជនជាតិដើមភាគតិច"ជនជាតិដើមភាគតិចក្នុងប្រទេសនេប៉ាល់"(២០១៥) http://bit.ly/1McCjZB

ក្រុមការងារអន្តរជាតិកិច្ចការជនជាតិដើមភាគតិច"ពិភពជនជាតិដើមភាគតិច២០០៦"(២០០៦) http://bit.ly/21bgrsZ

ក្រុមការងារអន្តរជាតិកិច្ចការជនជាតិដើមភាគតិច "ពិភពជនជាតិដើមភាគតិច២០១៥៖ ប្រទេសហ្វីលីពីន" (២០០៦) http://bit.ly/1RItbTA

ដេហ្វវ៉ាយ និង មែនព្រេដ ហ៊ិននុង មូលនិធិហ៊ែនរិចបូល "ជនជាតិដើមភាគតិចនិងប័ណ្ណកម្មសិទ្ធិដីធ្លីក្នុងប្រទេសកម្ពុជា" សន្និសីទប្រចាំឆ្នាំរបស់ធនាគារពិភពលោកស្តីពីដីធ្លីនិងភាពក្រីក្រឆ្នាំ២០១៣ ៨-១១ ខែមេសា ឆ្នាំ២០១៣ http://bit.ly/1XntSBe

ឡូវ៉ាម៉ាកឃើចណឺ "រស់នៅជាយសង្គម៖ អំពីស្ថានភាពនិងទីតាំងរបស់និគមជននិងជនជាតិដើមភាគតិចនៅកម្ពុជា" មូលនិធីហ៊ែនរិចបូលស្ទីហ្វស្ទង់ កម្ពុជា (ខែមិថុនា ឆ្នាំ២០១៥) http://bit.ly/1XFN911

លីកាដូ "ការផ្តល់ដ៏ច្រើនក្នុងប្រទេសកម្ពុជា៖ ការផ្តល់សម្បទានដីពីពេលមួយទៅពេលមួយ" (១ មិនា២០១៣) http://bit.ly/HxpSOV

វេទិកាអង្គការមិនមែនរដ្ឋាភិបាលនៃកម្ពុជា"ជនជាតិដើមភាគតិចនៅកម្ពុជា"(ខែមេសា ឆ្នាំ២០០៦) http://bit.ly/21tZ1rr

អុកហ្វាម "ការយល់ព្រមដោយសេរី និងដោយបានប្រាប់ឲ្យដឹងជាមុន ក្នុងប្រទេសហ្វីលីពីន៖ បទប្បញ្ញត្តិនិងតថភាព" (ខែកញ្ញា ឆ្នាំ២០១៣) http://bit.ly/1jU3Eco

រ៉ូរី អ រ៉ាចាដូ "នៅតែជាជនចម្លែកនៅលើដីរបស់ខ្លួនឯង" មជ្ឈមណ្ឌលសារព័ត៌មានស៊ើបអង្កេតហ្វីលីពី (របាយការណ៍) (ខែកក្កដា ឆ្នាំ២០០៧) http://bit.ly/1GvNUBJ

សារ៉ា មីលីន "និស្សារណកម្ម៖ ការកាប់ឈើដោយខុសច្បាប់ នៅក្នុងស្រមោលនៃអភិបាលនិងការវិនិយោគឆ្លងប្រទេស" *ការសិក្សាវិភាគអាស៊ី* វ៉ុល៤៧ លេខ២ (ខែឧសភា ឆ្នាំ២០១៥)

សារ៉ា មីលីន "ក្រោមស្បែកខ្លា៖ ការធ្វើជំនួញដីធ្លីនិងទ្វេគ្រោះនៃប័ណ្ណកម្មសិទ្ធិសហគមន៍ជនជាតិដើមភាគតិចនៅតំបន់ខ្ពង់រាបប្រទេសកម្ពុជា" *ការសិក្សាវិភាគអាស៊ី* វ៉ុល៤៥ លេខ៣ (ខែធ្នូ ឆ្នាំ២០១៣)

សារ៉ា មីលីន និង ប៊ីលអាដាម "របាំងមុខទីផ្សារ៖ ការលោតត្រដាងអំពីនយោបាយនៃការចំណាយនៅថ្នាក់ឃុំសម្រាប់សេវាបរិស្ថានក្នុងប្រទេសកម្ពុជា" *ការអភិវឌ្ឍន៍និងការផ្លាស់ប្តូរ* វ៉ុល៤៣ លេខ១ (ខែកុម្ភៈ ឆ្នាំ២០១២)

សេបាស្ទៀនស្រ្ទេងជីអ្វ "កម្ពុជារបស់លោកហ៊ុនសែន" (២០១៤)

សូរិយាស៊ូប៊ីឌី "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា" (ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១២) http://bit.ly/1kUyGln

អង្គការតម្លាភាពអន្តរជាតិ "សន្ទស្សន៍នៃការយល់ឃើញអំពីអំពើពុករលួយ២០១៤" (២០១៤) http://bit.ly/1AgRivL

ភាពជាដៃគូជាមួយជនជាតិដើមភាគតិច "រឿងរ៉ាវជោគជ័យរបស់ភាពជាដៃគូជាមួយជនជាតិដើមភាគតិច៖ សហការដើម្បីលើកកម្ពស់និងការពារសិទ្ធិជនជាតិដើមភាគតិច" (ខែឧសភា ឆ្នាំ២០១៤) http://bit.ly/1lHQfpP

វេទិកាអចិន្ត្រៃយ៍របស់អង្គការសហប្រជាជាតិស្តីពីបញ្ហាជនជាតិដើមភាគតិច សម័យប្រជុំលើកទី៥ សលាកប័ត្រព័ត៌មានលេខ១៖ ជនជាតិដើមភាគតិចនិងអត្តសញ្ញាណ" http://bit.ly/1mOcHLo

វេទិកាអចិន្ត្រៃយ៍របស់អង្គការសហប្រជាជាតិស្តីពីបញ្ហាជនជាតិដើមភាគតិច "សំណួរដែលត្រូវបានសួរញឹកញាប់៖ សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច http://bit.ly/1QNk9Wq

វេទិកាអចិន្ត្រៃយ៍របស់អង្គការសហប្រជាជាតិស្តីពីបញ្ហាជនជាតិដើមភាគតិច "បច្ចុប្បន្នភាពនៃសកម្មភាពអង្គការពលកម្មអន្តរជាតិទាក់ទងនឹងជនជាតិដើមភាគតិច"សម័យប្រជុំទី១៤ ក្រុងញូយ៉ក ថ្ងៃទី២០ ខែមេសា ដល់ ១ ខែឧសភា ឆ្នាំ២០១៥ http://bit.ly/1NrZHUT

អនុគណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីការលើកកម្ពស់និងការការពារសិទ្ធិមនុស្ស "ជនជាតិដើមភាគតិចនិងទំនាក់ទំនងជាមួយដី៖ អត្ថបទចុងក្រោយរៀបចំដោយអ្នករាយការណ៍ពិសេស លោកស្រី អេរីកាអាយរីណែ អេ ដេស E/CN.4/Sub.2/2001/21 (ខែមិថុនា ឆ្នាំ២០០១) http://bit.ly/1MJYUy7

ក្រុមធនាគារពិភពលោក "ច្បាប់ស្តីពីសិទ្ធិជនជាតិដើមភាគតិច៖ ក្របខណ្ឌច្បាប់និងស្ថាប័ន ការអនុវត្ត និងការប្រឈម" (ខែមិថុនា ឆ្នាំ២០០៧) http://bit.ly/1HYJ5r8

វេទិការសេដ្ឋកិច្ចពិភពលោល "របាយការភាពប្រកួតប្រជែងសកល ២០១៤-២០១៥" (ខែកញ្ញា ឆ្នាំ២០១៥) http://bit.ly/1pnKzuv

## អត្ថបទសារព័ត៌មាននិងសេចក្តីប្រកាសព័ត៌មាន

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជារៀបចំកិច្ចពិភាក្សាតុមូលស្តីពីដីនិងសិទ្ធិជនជាតិដើមភាគតិច" (ប្រកាសព័ត៌មាន) (ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៣) http://bit.ly/1QWvlJE

ដេវីដសែន "ក្រុមជនជាតិដើមភាគតិចជំរុញសកម្មភាពទាក់ទងនឹងដីធ្លី" សារព័ត៌មាន*ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៤)http://bit.ly/1lKThDy

ហ៊ុលរស្មី "នាយករដ្ឋមន្ត្រី គំរាមប្រើប្រាស់គ្រាប់រ៉ុក្កែតនៅតំបន់អារ៉ែង" *ឌឹខេមបូឌាដេលី* (ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០១៥) http://bit.ly/1IZ1kYm

សមាជិសកម្មសិទ្ធិជនជាតិដើមភាគតិច (IRAM) "ជនជាតិដើមភាគតិចនៅកម្ពុជាកំពុងប្រឈមនឹងវិបត្តិ" សារណាដោយជនជាតិដើមភាគតិចនៅកម្ពុជា ដាក់ទៅកិច្ចប្រជុំរៀបចំសម្រាប់វេទិកាអចិន្ត្រៃយ៍របស់អង្គការសហប្រជាជាតិស្តីពីបញ្ហាជនជាតិដើមភាគតិច ដែលបានរៀបចំឡើងនៅក្នុងប្រទេសម៉ាឡេស៊ី នៅថ្ងៃទី ៤-៦ ខែមិនា ឆ្នាំ២០០៩។ http://bit.ly/1Ufbvi3

អង្គការលីកាដូ "សម្បទាននៅក្នុងប្រទេសកម្ពុជា" (ខែឧសភា ឆ្នាំ២០១៥) http://bit.ly/1LdkawE

អង្គការលីកាដូ "ការកើនឡើងជាថ្មីនៃជម្លោះដីធ្លី គួរតែត្រូវបានដោះស្រាយជាបន្ទាន់" (ខែកុម្ភៈ ឆ្នាំ២០១៥) http://bit.ly/1DG8IaO

ម៉ាលីយ៉ា ហ្គុយើ ស្វេវេន និង គុចណារ៉េន "មូលនិធិសម្រាប់គម្រោងលើកកម្ពស់សិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច ត្រូវបញ្ចប់" *ឌឹខេមបូឌាដេលី* (ខែកុម្ភៈ ឆ្នាំ២០១៥)http://bit.ly/1VB50qn

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស "សម្បទានដីសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា៖ ទស្សនៈសិទ្ធិមនុស្ស" (ខែមិថុនា ឆ្នាំ២០០៧) http://bit.ly/1a47Sss

អង្គការប្រឆាំងទារុណកម្មពិភពលោក "ប្រទេសកម្ពុជា៖ ការឃុំខ្លួនតាមទំនើងចិត្ត និងការធ្វើទុក្ខបុកម្នេញពីប្រព័ន្ធតុលាការអំពីបណ្តឹងឧទ្ធរណ៍លោក វន់ ពៅ- ឌឹអប់សឺវេថូរី (៩ តុលា ២០១៥) http://bit.ly/1Qe9pjq

ផាក សៀងលី និង ដានីញែល ផាយ "ឈើប្រណិតត្រូវរកឃើញកប់ទុក" (ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤) http://bit.ly/1QiweCH